ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ជប៉ុនផ្តល់ឱកាសមួយក្នុងការជួយលើកកម្ពស់យុត្តិធម៌នៅកម្ពុជា
- តាំង គីម ៖ ការឆ្លើយតបទៅនឹងការរំលោភផ្លូវភេទនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

ដើម្បីការចងចាំ និងយុត្តិធម៌

លេខ ៦៨ ខែសីហា ឆ្នាំ២០០៥

លេខ៦៥ ខែឧសភា ឆ្នាំ២០០៥

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រៈ ជប៉ុនខកខានឱកាសមួយ.......................................... ១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ ទ្រី ស៊ីន..........................................២

◆ កម្ពុជាប្រជាធិបតេយ្យនិងថៃ.......................................... ៤

◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១.................... ៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ក្លាយជាអ្នកទោសខ្មែរក្រហម..........................................១០

◆ ជីវិតគ្រួសារខ្មែរ-វៀតណាម..........................................១២

◆ មិនចង់បំភ្លេច ហើយក៏មិនចង់ជួបទៀត.................................. ១៥

**ផ្នែកច្បាប់**

◆ តាំង គីម.......................................................... ១៨

**វេទិកាពិភាក្សាសាធារណៈ**

◆ សិទ្ធិមនុស្សនិងកម្ពុជាប្រជាធិបតេយ្យ..................................៣០

◆ បួនចំណុចដែលអង្គជំនុំជម្រះវិសាមញ្ញ.................................. ៣៣

◆ វិវឌ្ឍន៍ថ្មីៗជុំវិញបញ្ហាថវិកា..........................................៣៦

◆ ការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា..................................៣៨

◆ សេចក្តីថ្លែងការណ៍ស្តីអំពីការចូលជាជាធរមាន..........................៤៦

◆ កិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា..........៤៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ឪពុកខ្ញុំ..........................................................៤៨

◆ ជីវិតក្នុងភាពនឹងថ្កល់..........................................៥៤






នារីកម្មាភិបាលខ្មែរក្រហម

## រក្សាសិទ្ធិ


មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្មេរលេខនេះ*** *យិន នាន, សឹម សុរិយ៉ា, គីម កែវកន្និដ្ឋា, ព្រំ សាម៉ុន, ស៊ិរិ សាវីណា, សាយមិន អូ ខនណែល, ខាមីឡា សារុត, ខេទ្រីណា អាន់ដឺសុន,* ***អ្នកនិពន្ធនិងស្រាវជ្រាវៈ*** *លី សុផល, សូ ហ្វារីណា* ***អ្នកបកប្រែៈ*** *ដី ទេវិទ្ធិ* ***និពន្ធនាយករងៈ*** *សាន់ កល្យាណ* ***និពន្ធនាយកទូទៅៈ*** *ឆាំង យុ* ***ក្រាហ្វិកកុំព្យូទ័រៈ*** *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយៈ*** *មាស ប៊ុនថាន*


Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# ជប៉ុនខកខានឱកាសមួយក្នុងការជួយលើកកម្ពស់នីតិរដ្ឋនៅកម្ពុជា

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៥ មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្នើសុំឲ្យរដ្ឋាភិបាលជប៉ុនបញ្ជាក់អំពីគោលជំហររបស់ខ្លួនទាក់ទងនឹងការធ្វើសម្បទាន «វាលពិឃាតជើងឯក» ដោយក្រុមហ៊ុនឯកជនមួយរបស់ជប៉ុនឈ្មោះ JC Royal ។ មួយខែក្រោយមក ស្ថានទូតជប៉ុនបានចេញសេចក្តីថ្លែងការណ៍មួយដែលនិយាយថា ១) ការសម្រេចអំពីការចាត់ចែង «វាលពិឃាតជើងឯក» គឺជាសមត្ថកិច្ចរបស់អាជ្ញាធរកម្ពុជា ២) រដ្ឋាភិបាលជប៉ុនមិនពាក់ព័ន្ធនៅក្នុងការធ្វើសម្បទាននេះទេ ហើយក៏មិនបានពិគ្រោះយោបល់ជាមួយក្រុមហ៊ុន JC Royal ជុំវិញបញ្ហានេះដែរ ៣) ជំនួយអភិវឌ្ឍរបស់ជប៉ុនមិនមានទំនាក់ទំនងនឹងការធ្វើសម្បទាន «វាលពិឃាតជើងឯក» ទេ ៤) រដ្ឋាភិបាលជប៉ុនគាំទ្រយ៉ាងសកម្មដល់ការបង្កើត «អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» ដែលនឹងជួយលើកកម្ពស់នីតិរដ្ឋនៅកម្ពុជា ។


បូជនីយដ្ឋានជើងឯក

ជាទូទៅប្រជាជនកម្ពុជាពេញចិត្តចំពោះជំនួយឧបត្ថម្ភរបស់ប្រទេសជប៉ុនដល់ «អង្គជំនុំជម្រះវិសាមញ្ញ» ប៉ុន្តែដោយអូសបន្លាយពេលវេលារហូតដល់កិច្ចសន្យាឲ្យជួល «វាលពិឃាតជើងឯក» ត្រូវបានធ្វើរួចរាល់ ទើបបញ្ចេញនូវសេចក្តីថ្លែងការណ៍របស់ខ្លួននោះ ស្ថានទូតឲ្យជប៉ុន «បានខកខាន» ឱកាសមួយដើម្បីជួយប្រជាជនកម្ពុជាក្នុងការលើកកម្ពស់នីតិរដ្ឋ ។ ការអូសបន្លាយពេលវេលានេះហាក់បីដូចជាបានជួយលើកទឹកចិត្តមន្ត្រីដែលពាក់ព័ន្ធបញ្ហានេះឲ្យសាបព្រោះការព្រួយបារម្ភនៅក្នុងចំណោមប្រជាជនកម្ពុជាថា ជំនួយរបស់រដ្ឋាភិបាលជប៉ុននឹងត្រូវបញ្ឈប់ប្រសិនបើកម្ពុជាមិនធ្វើសម្បទាន «វាលពិឃាតជើងឯក» ទៅឲ្យក្រុមហ៊ុន JC Royal ។

ជប៉ុនអាចប្រើប្រាស់ឥទ្ធិពលដ៏ខ្លាំងរបស់ខ្លួនធ្វើឲ្យមន្ត្រីទាំងនោះដកខ្លួនចេញពីកិច្ចសន្យាដែលមិនច្បាស់លាស់ដើម្បីក្លាយទៅជាជើងឯកនៃការគ្រប់គ្រងដ៏មានតម្លាភាព ។ ផ្ទុយមកវិញជប៉ុនបានជ្រើសរើសយកការដកខ្លួនចេញពីកិច្ចការនេះ ហើយការធ្វើដូច្នេះបានលើកទឹកចិត្តបន្ថែមទៀតដល់អ្នកដែលលក់កេរដំណែលវប្បធម៌របស់កម្ពុជា ។

ឥឡូវនេះ បូជនីយដ្ឋានមិត្តភាពកម្ពុជា-វៀតណាមនៅក្នុងខេត្តសៀមរាបកំពុងតែត្រូវបានរុះរើ ហើយមន្ត្រីដែលធ្វើកិច្ចសន្យា«លក់» កន្លែងនោះមិនចាំសូម្បីតែឈ្មោះក្រុមហ៊ុនដែលទិញកន្លែងនោះផង ។ ហេតុអ្វីបានជារដ្ឋាភិបាលគួរតែទទួលខុសត្រូវ? សូមក្រឡេកមើលអ្វីដែលបានកើតឡើងនៅជើងឯក ។ យើងបានត្រឹមតែឆ្ងល់ថាតើបូជនីយដ្ឋានប្រល័យពូជសាសន៍មួយណាដែលនឹងក្លាយជាជនរងគ្រោះបន្ទាប់ទៀត ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ទី ស្រ៊ីន អតីតប្រធានពិធីការនៅក្រសួងការបរទេស

ទី ស្រ៊ីន ហៅ មុត ជាអតីតប្រធានពិធីការនៅក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យនៅក្នុងឆ្នាំ១៩៧៧ ។ នៅឆ្នាំ ១៩៧៥ ស្រ៊ីន ជាលេខាតំបន់២២ ។ នៅថ្ងៃទី១ ខែ៦ ឆ្នាំ ១៩៧៧ ស្រ៊ីន ត្រូវអង្គការចាប់ខ្លួនហើយបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ ។

ស្រ៊ីន បួសបានពីរវស្សាក្នុងអាយុ១៥-១៦ឆ្នាំ ហើយក្រោយមកក៏លាចាកសិក្ខាបទដើម្បីជួយរកត្រីឪពុកម្តាយនៅភូមិចក សង្កាត់មៀន ស្រុកអូររាំងឪ តំបន់២២ ភូមិភាគបូព៌ា ។ នៅឆ្នាំ១៩៥៧ បុរសម្នាក់ឈ្មោះ ស៊ាង ហ៊ី បានណែនាំឲ្យ ស្រ៊ីន ដឹកនាំប្រជាជនតវ៉ាទាមទារដីធ្លីពីរដ្ឋាភិបាល ។ ក្រោយមក ស្រ៊ីន ឈប់ទាក់ទងជាមួយ ស៊ាង ហ៊ី ដោយសារដឹងថា ស៊ាង ហ៊ី ជាខ្មែរក្រហម ។

ឆ្នាំ១៩៦០ ស្រ៊ីន បានស្គាល់ឈ្មោះ កុល តាមការណែនាំរបស់ ស៊ាង ហ៊ី ។ ដំបូង កុល បានអប់រំ ស្រ៊ីន អំពីបដិវត្តន៍ ដូចជាការឃោសនាប្រជាជនឲ្យបង្កើតជាក្រុមប្រវាស់ដៃក្នុងការធ្វើស្រែចម្ការ ប៉ុន្តែក្រោយមក កុល បែរជាលើកសរសើររបបសេរី ហើយបណ្តុះបន្ទាប់របបកុម្មុយនិស្ត ដោយលើកយកកុម្មុយនិស្តចិនមកធ្វើជាឧទាហរណ៍ប្រាប់ដល់ ស្រ៊ីន ព្រមទាំងស្នើឲ្យគាត់ជួយឃោសនាប្រជាជន អំពីរបបសេរីទៀតផង ។

ចុងឆ្នាំ១៩៦០ ស្រ៊ីន ត្រូវបានទទួលស្គាល់ជាសមាជិកខ្មែរសេរី ហើយ កុល ណែនាំឲ្យស្គាល់ យោន និង សាយ ។ ជារឿយៗ យោន អប់រំឲ្យ ស្រ៊ីន បំផុសប្រជាជនដើម្បីទាមទាររបបសេរី ។ ឆ្នាំ១៩៦៤ យោន លាលែងពីការងារហើយមកប្រកបរបររកស៊ីចិញ្ចឹមគ្រួសារ ចំណែក កុល ត្រូវផ្លាស់ទៅធ្វើការនៅខេត្តកំពង់ចាម ។ ស្រ៊ីន បានទាក់ទងជាមួយ សារ៉ាយ និង ជា នៅភូមិថ្មី ស្រុកតំបែរ ដើម្បីពង្រីកឥទ្ធិពលសេរីនៅក្នុងខេត្ត ។

ឆ្នាំ១៩៦៥ មុត ចាត់តាំងឲ្យ ចៅ សឿង ធ្វើជាជំទប់នៅសង្កាត់ព្រះធាតុដើម្បីជាបផ្នែកក្នុងការតាមដានចលនាបដិវត្តន៍ដែលបង្កប់ខ្លួននៅតាមមូលដ្ឋាន ។ ដើមឆ្នាំ១៩៦៦ នៅពេលត្រឡប់មកធ្វើការនៅក្នុងភូមិវិញ កុល និយាយវែកញែកអំពីបដិវត្តនិងអំពីរបបសេរីប្រាប់ ស្រ៊ីន ហើយសម្រេចបញ្ចូល ស្រ៊ីន ជាសមាជិកសេ.អ៊ី.អាដោយមានវត្តមានរបស់ ទុំ នៅក្នុងពិធីនោះផង ។ ទុំ ណែនាំឲ្យ ស្រ៊ីន ខិតខំកសាងកម្លាំងឲ្យបានច្រើនដើម្បីវាយកម្ទេចបដិវត្ត ។ ស្រ៊ីន កសាងកម្លាំងបាន២នាក់នៅភូមិមេសប្រច័ណ្ឌ ។

ឆ្នាំ១៩៦៨ ស្រ៊ីន ត្រូវបានបញ្ជូនទៅធ្វើចម្ការនៅភ្នំពាមជាំងដើម្បីពង្រឹងនិងពង្រីកគោលនយោបាយរបស់ខ្លួនឲ្យកាន់តែខ្លាំងឡើង ។ ក្រោយមក ទុំ ណែនាំឲ្យ ស្រ៊ីន ទៅដឹកកាំភ្លើងនៅអូឡាំពិក ដើម្បីបញ្ជូនបន្តទៅឲ្យ ពាម ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ទុំ បានតែងតាំង ស្រ៊ីន ជាលេខាស្រុកកោះសូទិន ។ ស្រ៊ីន បានបញ្ចេញទំនិញ ដូចជាសំឡី គ និងសណ្តែកគ្រប់ប្រភេទ លក់ឲ្យតំបន់ដែលគ្រប់គ្រងដោយរដ្ឋការលន់នល់ ហើយគាត់អប់រំនិងកសាងកម្លាំងបាន៨នាក់ដែលជាមនុស្សចូលចិត្តសប្បាយហ៊ឺហា ។ ឆ្នាំ១៩៧២ ដើម្បីទប់ស្កាត់ការរីកលូតលាស់របស់អង្គការបដិវត្តន៍ខ្មែរក្រហម នៅពេលកាន់ក្តាប់យោធាតំបន់២២ ស្រ៊ីន បានដកយកកម្លាំងដែលទន់ខ្សោយទៅប្រយុទ្ធនៅសមរភូមិដែលជាហេតុបណ្តាលឲ្យទ័ពស្លាប់និងរបួសជាច្រើន ។ ឆ្នាំដដែល ស្រ៊ីន កសាងកម្លាំងបាន២នាក់បន្ថែមទៀត ។ នៅពេលវាយខ្លាំងនៅសមរភូមិវិហារសួគ៌ ស្រ៊ីន បានបំផ្លាញគ្រាប់រំសេវ កាំភ្លើង និងស្បៀងអស់ជាច្រើន ។

ឆ្នាំ១៩៧៣ នៅពេលវាយនៅសមរភូមិរកាកោង ទុំ និង ស្រ៊ីន បញ្ជាទ័ពចូលសមរភូមិប្រយុទ្ធទាំងក្តាប់មិនបានសភាពការណ៍ជាមុន បណ្តាលឲ្យទ័ពស្លាប់និងរបួសជាច្រើន ។

ឆ្នាំ១៩៧៤ ស្រ៊ីន ណែនាំឲ្យកម្លាំងធ្វើសកម្មភាពដើម្បីបំបាក់ស្មារតីយុទ្ធជននិងកងទ័ពបដិវត្តជាប់រហូតដល់ចុងឆ្នាំ ស្រ៊ីន ត្រូវអង្គការចាត់តាំងឲ្យមកធ្វើការនៅសមរភូមិក្រោយវិញ ។

ស្រ៊ីន បានប្រជុំគ្នាជាមួយកម្មាំងទាំងអស់ដើម្បីដាក់ផែនការបន្តទំនាស់ខាងនយោបាយរវាងប្រជាជននិងបដិវត្ត ។ វិធានការគឺបង្កើនការឃ្លាមកាមនិងឆែកឆេរប្រជាជននៅស្រុកមុខកំពូលយ៉ាងតឹងរ៉ឹង ដែលធ្វើឲ្យប្រជាជនមិនសប្បាយចិត្តនិងលែងទុកចិត្តអង្គការ ។

ឆ្នាំ១៩៧៥ ពេលដែលអង្គការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ស្រ៊ីន បំផុសប្រជាជនឲ្យប្រឆាំងនឹងគោលការណ៍របស់អង្គការ ធ្វើឲ្យយឺតយ៉ាវក្នុងការដឹកជញ្ជូនប្រជាជននិងសម្ភារទៅកាន់ទីជនបទ ហើយថែមទាំងមិនបានចែកស្បៀងអាហារដល់ប្រជាជនជម្លៀស បណ្តាលឲ្យប្រជាជនអត់ឃ្លានយ៉ាងខ្លាំង ។

នៅខែ៦ ឆ្នាំដដែល ក្នុងការប្រជុំផ្លាស់ប្តូរគណៈតំបន់ចាស់សោ យ៉ាន់ លេខាភូមិភាគបូព៌ា បានតែងតាំង ស្រ៊ីន ជាលេខាតំបន់២២ និង សំបុក ជាអនុលេខា ។

នៅខែ៨ ស្រ៊ីន បានប្រជុំដាក់ផែនការធ្វើរដ្ឋប្រហារដើម្បីផ្តួលរំលំបដិវត្តន៍ ដោយមានសមាសភាពចូលរួមប្រជុំចំនួន១២នាក់នៅព្រែកតាមាក់ ។ អង្គប្រជុំបានកំណត់ពេលវេលាធ្វើបាតុកម្មនៅខែ១០ ឆ្នាំ១៩៧៥ នៅស្រុកមុខកំពូល ហើយត្រៀមពង្រឹងកម្លាំងប្រជាជនមូលដ្ឋានប្រជាជនថ្មីនិងយុទ្ធជនកម្មាភិបាលនៅតាមក្រសួងមន្ទីរ ។ ស្រ៊ីន បានសម្រាំងកម្លាំងទ័ពជាស្រេចប្រមូលផ្តុំនៅស្រុកមុខកំពូល ។

ដល់ថ្ងៃកំណត់ បាតុកម្មនេះត្រូវអាក់ខានដោយសារកម្មាភិបាលនៅតាមតំបន់ត្រូវអង្គការចាត់តាំងឲ្យទៅរៀននយោបាយ ។ ស្រ៊ីន និងកម្លាំងក៏បន្តរៀបចំផែនការបាតុកម្មថ្មីមួយទៀតដែលនឹងធ្វើឡើងនៅខែ១១ ឆ្នាំ១៩៧៥ ។ ផែនការបាតុកម្មទីពីរនេះក៏ត្រូវអាក់ខានទៀត ដោយសារមានទំនាស់ផ្ទៃក្នុងរវាង ស្រ៊ីន និង សំបុក ។

ឆ្នាំ១៩៧៦ ស្រ៊ីន ត្រូវអង្គការទម្លាក់ពីតំណែងមកជាអនុលេខាតំបន់២២ ហើយតែងតាំង ឈាន ជាលេខាតំបន់២២ជំនួសវិញ ។ ស្រ៊ីន បានរាយការណ៍ពីកម្លាំងដែលខ្លួនកសាងបាននិងសកម្មភាពកន្លងមកប្រាប់ ឈាន ។ ស្រ៊ីន ទទួលការណែនាំពី ឈាន ឲ្យចែករបស់របរប្រើប្រាស់និងការហូបចុកមិនឲ្យស្មើគ្នាដល់ប្រជាជនដើម្បីឲ្យប្រជាជនមានការថ្នាំងថ្នាក់នឹងអង្គការ ។

នៅពេលអង្គការចាត់តាំងឲ្យប្រមូលកម្លាំងប្រជាជនពីស្រុកមុខកំពូលនិងស្រុកកោះសូទិន ទៅធ្វើការនៅស្រុកអូររាំងឪនិងស៊ីធរកណ្តាល ស្រ៊ីន, ឈាន, ចៅ សឿង (គណៈស្រុកអូររាំងឪ) ធន (គណៈស្រុកស៊ីធរកណ្តាល) និង សំបុក បានដឹកនាំកម្លាំងធ្វើសកម្មភាពបំផ្លាញផលស្រូវដើម្បីកុំឲ្យគ្រប់តាមផែនការរបស់អង្គការដែលកំណត់៣តោនក្នុងមួយហិកតា ។

ស្រ៊ីន ត្រូវអង្គការដកទៅធ្វើការនៅក្រសួងការបរទេសនៅឆ្នាំ១៩៧៧ ។ ឈាន បានផ្តាំផ្ញើឲ្យ ស្រ៊ីន ខិតខំកសាងកម្លាំងនៅក្រសួងឲ្យបានច្រើន ។ នៅខែ១ ឆ្នាំ១៩៧៧ វ៉ាន់ បានចាត់តាំងឲ្យ ស្រ៊ីន ធ្វើជាប្រធានពិធីការនៅក្រសួងការបរទេស ហើយក្រោយមកតែងតាំង ស្រ៊ីន ជាកម្មាភិបាលពិធីការ ។ តាំងពីពេលចូលមកធ្វើការនៅក្នុងក្រសួងការបរទេស ស្រ៊ីន ដាច់ខ្សែរយៈទាក់ទងជាមួយ ឈាន រហូតដល់ថ្ងៃទី១ ខែ៦ ឆ្នាំ១៩៧៧ ស្រ៊ីន ត្រូវអង្គការចោទប្រកាន់ថាក្បត់បដិវត្តន៍និងត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរឃុំឃាំងស-២១ ព្រមទាំងស្នូរចម្លើយដោយឈ្មោះ អុន លី ។ នៅក្នុងឯកសារចម្លើយសារភាពរបស់ ស្រ៊ីន មានភ្ជាប់ជាមួយបញ្ជីឈ្មោះអ្នកចូលរួមសកម្មភាពជាមួយគាត់ចំនួន៦៤នាក់ ។

**សុ ហ្វារីណា**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# កម្ពុជាប្រជាធិបតេយ្យនិងថៃៈ ទំនាក់ទំនងដ៏ប្រេះស្រាំ

ប្រទេសថៃជាប្រទេសមិនមែនកុម្មុយនិស្តដំបូងបង្អស់ដែលកម្ពុជាប្រជាធិបតេយ្យស្ថាបនាចំណងទាក់ទងការទូតបន្ទាប់ពីជ័យជម្នះរបស់ខ្លួននៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ពីដំបូងទំនាក់ទំនងរបស់ប្រទេសទាំងពីរហាក់ល្អប្រសើរ ប៉ុន្តែចាប់ពីឆ្នាំ១៩៧៦ ដោយសារជម្លោះព្រំដែននិងបញ្ហានយោបាយនៅក្នុងប្រទេសថៃបណ្តាលឲ្យទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យនិងថៃមានភាពល្អក់កករនិងមានការប្រឈមមុខប្រដាប់អាវុធដាក់គ្នាយ៉ាងខ្លាំងក្លា ។ ឥទ្ធិពលនៃជម្លោះនេះបានធ្វើឲ្យស្លាប់ប្រជាជនថៃនិងប្រជាជនកម្ពុជាអស់ជាច្រើននាក់ ។ ភាគីទាំងពីរព្យាយាមចរចាបញ្ចប់ជម្លោះជាច្រើនលើកច្រើនសា ប៉ុន្តែការវាយប្រហារនៅតាមព្រំដែននៅតែកើតមាន ហើយទំនាក់ទំនងការទូតនៅតែមិនត្រូវបានភ្ជាប់ឡើងវិញទេ ។

ទីភ្នាក់ងារសារពត៌មានវ៉ាស៊ីនតោនប៉ុស្តិ៍ចេញផ្សាយថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៥ បានឲ្យដឹងថា រដ្ឋមន្ត្រីការបរទេសកម្ពុជាប្រជាធិបតេយ្យ អៀង សារី បានមកដល់ទីក្រុងបាងកកនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៥ ដើម្បីស្វែងរកជំនួយសេដ្ឋកិច្ចនិងពិភាក្សាអំពីការរួមរស់ដោយសន្តិភាពជាមួយប្រទេសថៃ ។ ដោយផ្អែកលើគោលនយោបាយរបស់រដ្ឋាភិបាលថ្មីដើម្បីស្ថាបនាប្រទេសដែលបានហែកហួរដោយសង្គ្រាម អៀង សារី បានថ្លែងថា បក្សកុម្មុយនិស្តកម្ពុជាកំពុងតែប្រឹងប្រែងជំរុញវិស័យផលិតកម្ម និងកសាងប្រទេសដោយរក្សាឲ្យបាននូវឯករាជ្យភាពនិងអធិបតេយ្យភាពដើម្បីភាពម្ចាស់ការលើខ្លួនឯង ។ នៅក្នុងដំណើរទស្សនកិច្ចនោះ ទោះបីជា អៀង សារី មិនបានលើកឡើងដោយត្រង់ៗអំពីតម្រូវការស្បៀងក៏ដោយ ក៏នាយករដ្ឋមន្ត្រីថៃ គុក្រឹត ប្រាមោជ្ជ បានផ្តល់ស្បៀងដល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដោយមើលឃើញថា ប្រទេសកម្ពុជាកំពុងជួបប្រទះការខ្វះខាតស្បៀងយ៉ាងខ្លាំង ម្យ៉ាងទៀតប្រទេសថៃមានបរិមាណស្រូវលើសតម្រូវការប្រើប្រាស់នៅក្នុងស្រុក ។ មេដឹកនាំថៃរូបនេះរំពឹងថានឹងបង្កើតការទំនាក់ទំនងការទូតជាថ្នូរនឹងជំនួយស្បៀងអាហារទាំងនេះ ។ ក្រុមអ្នកវិភាគជឿជាក់ថា ភាគីទាំងពីរមានលទ្ធភាពបង្កើតចំណងការទូតជាមួយគ្នា ដែលលទ្ធភាពមួយគឺការស្ថាបនាការទូតដោយគ្មានតំណាងអគ្គទូតប្រចាំនៅក្នុងប្រទេសទាំងពីរ ។

កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍បានបន្តទៀតថា ដើម្បីបង្កើនទំនាក់ទំនងឲ្យកាន់តែស្អិតល្មួតថែមទៀត អៀង សារី បានអនុញ្ញាតឲ្យជើងហោះហើររបស់ក្រុមហ៊ុន ឆាទីឆៃ ឈុនហាវ៉ាន រដ្ឋមន្ត្រីការបរទេសថៃ ប្រតិបត្តិការហោះហើរមកប្រទេសកម្ពុជាមួយជើងក្នុងមួយថ្ងៃដើម្បីនាំភ្ញៀវបរទេសមកទស្សនាខេត្តសៀមរាប ។ ឆាទីឆៃ ឈុនហាវ៉ាន នាយកក្រុមហ៊ុនហោះហើរ ឆាទីឆៃ ឈុនហាវ៉ាន បានប្រាប់អ្នកយកពត៌មាននៅឯព្រលានយន្តហោះទីក្រុងបាងកកបន្ទាប់ពីការដំណើរទស្សនកិច្ចរយៈពេល២ថ្ងៃរបស់គាត់មកកាន់ទីក្រុងភ្នំពេញថា នេះជាលើកទីមួយហើយដែលបក្សកុម្មុយនិស្តកម្ពុជាអនុញ្ញាតឲ្យក្រុមហ៊ុនអាកាសចររបស់លោកនាំភ្ញៀវបរទេសមកទស្សនាខេត្តសៀមរាបបន្ទាប់ពីរបបនេះឡើងកាន់អំណាចនៅកម្ពុជា ។

កាសែតញូយ៉កថែមស៍ចេញផ្សាយថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៥បានបរិយាយថា ចំនួនជនភៀសខ្លួនកម្ពុជាកាន់តែកើនឡើងនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃចាប់ពីឆ្នាំ១៩៧៥ ។ បក្សកុម្មុយនិស្តកម្ពុជាមានគោលការណ៍ដោះស្រាយបញ្ហានេះជាមួយប្រទេសថៃ ដោយជំរុញឲ្យមានការដាក់ប៉ុស្តិ៍ត្រួតពិនិត្យនៅតាមព្រំដែនកម្ពុជានិងចរចាជាមួយរដ្ឋមន្ត្រីការបរទេសថៃដើម្បីបញ្ជូនជនភៀសខ្លួនមកកាន់ប្រទេសកម្ពុជាវិញ ។ បក្សកុម្មុយ-និស្តកម្ពុជានិងប្រទេសថៃបានឈានដល់ការសម្រេចលើការកសាងចំណងការទូតជាមួយគ្នាបន្ទាប់ពីជំនួបចរចាររបស់គណៈប្រតិភូបក្សកុម្មុយនិស្តកម្ពុជាចំនួន៨រូបដែលដឹកនាំដោយរដ្ឋមន្ត្រីការបរទេស អៀង សារី ជាមួយរដ្ឋមន្ត្រីការបរទេសថៃ ឆាទីឆៃ ឈុនហាវ៉ាន ។ ភាគីទាំងពីរមិនទាន់បានកំណត់ពេលវេលាច្បាស់លាស់ដើម្បីផ្លាស់ប្តូរអគ្គរដ្ឋទូតរបស់ខ្លួនទេ ដោយរង់ចាំពេលវេលាអំណោយផល ប៉ុន្តែភាគីទាំងពីរបានសម្រេចដាក់មន្ត្រី

សម្ព័ន្ធប្រចាំការនៅព្រំដែនរបស់ខ្លួនមុននឹងឈានដល់ការបញ្ជូនគំណាងអគ្គទូតមកប្រចាំការនៅក្នុងទីក្រុងភ្នំពេញនិងទីក្រុងបាងកក ។

ការយល់ច្រឡំមួយបានកើតឡើងរវាងបក្សកុម្មុយនិស្តកម្ពុជានិងប្រទេសថៃនៅខែកុម្ភៈ ។ ទីភ្នាក់ងារ "អាសូស៊ីអេតប្រេស" ដែលចេញផ្សាយថ្ងៃទី២៨ ខែកុម្ភៈ ឲ្យដឹងថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចោទប្រកាន់យន្តហោះបីគ្រឿងប្រភេទF-១១១ របស់អាមេរិកថាបានទម្លាក់គ្រាប់បែកលើខេត្តសៀមរាបកាលពីថ្ងៃពុធដោយបានសម្លាប់មនុស្ស១៥នាក់និងរបួស៣០នាក់ ។ វិទ្យុទីក្រុងភ្នំពេញបានផ្សាយថា យន្តហោះប្រភេទនេះបានចុះចតនៅប្រទេសថៃបន្ទាប់ពីទម្លាក់គ្រាប់បែកលើខេត្តសៀមរាប ។ នាយករដ្ឋមន្ត្រីថៃ គូគ្រីត ប្រាមោជ្ជ បដិសេធចោលការចោទប្រកាន់នេះដោយអះអាងថាគ្មានយន្តហោះអាមេរិកណាមួយនៅលើទឹកដីថៃនៅថ្ងៃនោះទេ ។ ជាងនេះទៅទៀត ទាំងយោធាអាមេរិកនិងអ្នកនាំពាក្យស្ថានទូតសហរដ្ឋអាមេរិកបាននិយាយថា ការចោទប្រកាន់របស់បក្សកុម្មុយនិស្តកម្ពុជាពិតជាប្រាសចាកពីការពិតទាំងស្រុង ។

ទស្សនាវដ្តី "សេដ្ឋកិច្ចចុងបូព៌ា" ចេញផ្សាយឆ្នាំ១៩៧៨ បានសរសេរថា សង្គ្រាមព្រំដែនរវាងកម្ពុជា-ថៃឆេះកាន់តែសន្ធោរសន្ធៅនៅឆ្នាំ១៩៧៧-៧៨ ។ យន្តហោះOV-១០ របស់ថៃបានចូលមកជួយសង្គ្រោះប៉ុស្តិ៍ប្រចាំការព្រំដែនរបស់ថៃដែលកំពុងទទួលរងការបាញ់ប្រហារយ៉ាងខ្លាំងដោយកងទ័ពខ្មែរក្រហម ត្រូវបានបាញ់ឲ្យធ្លាយធុងប្រេងបណ្តាលឲ្យធ្លាក់ ប៉ុន្តែមិនបណ្តាលឲ្យមនុស្សនៅក្នុងយន្តហោះនោះស្លាប់ឡើយ ។ ក្រោយមកមានយន្តហោះប្រភេទដដែលចូលមកជួយនាំអ្នករបួសទៅព្យាបាលនៅមន្ទីរពេទ្យប្រទេសថៃ ។ ៦ថ្ងៃមុនការធ្លាក់យន្តហោះ កងទ័ពខ្មែរក្រហមប្រមាណ២០០ទៅ៣០០នាក់បានវាយប្រហារភូមិបាន់សាន់នៅជិតប៉ុស្តិ៍ប៉ូលិសប្រចាំការនៅតាមព្រំដែនបណ្តាលឲ្យស្លាប់អ្នកភូមិ១៤នាក់និងប៉ូលិសម្នាក់ ហើយអ្នកភូមិ៤នាក់ទៀតរងរបួស ។ មុនការធ្លាក់យន្តហោះមួយថ្ងៃគឺនៅថ្ងៃទី២០ខែធ្នូ មានការបាញ់ប្រហារគ្នាទៅវិញទៅមករវាងទាហានខ្មែរក្រហមនិងទាហានថៃដែលប្រចាំការនៅតាមព្រំដែនចាប់ពីភាគខាងត្បូងអារញ្ញប្រាថេតដល់ប៉ោយប៉ែតប្រទេសកម្ពុជា ។ ប្រភពពត៌មានពីប្រទេសថៃបានឲ្យដឹងថាចាប់តាំងពីដើមខែវិច្ឆិកា ការវាយប្រហារនៅតាមព្រំដែនបានសម្លាប់ជនជាតិថៃ៥៥នាក់និង៧៨នាក់រងរបួស ។ ដូច្នេះគោលនយោបាយរបស់នាយករដ្ឋមន្ត្រីថ្មី គ្រៀងសាក់ ឆាម៉ាណន (អតីតនាយករដ្ឋមន្ត្រី គូគ្រីត ប្រាមោជ្ជ ត្រូវបានទម្លាក់ចេញពីតំណែងដោយរដ្ឋប្រហារកាលពីឆ្នាំ១៩៧៦) គឺផ្សះផ្សាជាមួយបណ្តាប្រទេសនៅតំបន់ឥណ្ឌូចិនដើម្បីឲ្យមានអន្តរាគមន៍ពីប្រទេសទាំងនោះ ប៉ុន្តែហាក់ដូចជាមិនឃើញមានសញ្ញាវិជ្ជមានពីប្រទេសណាមួយឡើយ ។ នៅវេលាព្រឹកបន្ទាប់ពីការបាញ់ប្រហារយន្តហោះ នាយករដ្ឋមន្ត្រីថៃ គ្រៀងសាក់ ឆាម៉ាណន អមដំណើរដោយរដ្ឋមន្ត្រីការបរទេស ឧបឌិត បញ្ញារាំងគុន បានទៅពិនិត្យមើលតំបន់នៅតាមព្រំដែនដែលរងការប៉ះទង្គិចគ្នា ។ ឧបឌិត បញ្ញារាំងគុន បានជួបនិងបរិភោគអាហារថ្ងៃត្រង់ជាមួយអគ្គរាជទូតស៊ុយអែដប្រចាំនៅប្រទេសថៃឈ្មោះ ហ្សង់គ្រីស្តូប អូប៊ែរ និងភរិយារបស់គាត់ ។ អគ្គរាជទូតរូបនេះមាននាទីកាត់បន្ថយអំពើហិង្សានៅតាមព្រំដែនកម្ពុជា-ថៃ ។ ប្រភពមួយចំនួនពីប្រទេសថៃឲ្យដឹងថាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ក៏បានអញ្ជើញអគ្គរដ្ឋទូត អូប៊ែរ ចូលជួបនិងពិភាក្សាការងារដែរ ។

មូលហេតុដែលបង្កឲ្យមានការប្រយុទ្ធគ្នានេះគឺមកពីខ្សែបន្ទាត់ព្រំដែនរវាងប្រទេសថៃនិងកម្ពុជាមិនច្បាស់លាស់ ។ មានផែនទី៣ដែលបង្ហាញអំពីការកម្រិតព្រំដែនប្លែកៗពីគ្នា ។ ផែនទីទីមួយធ្វើឡើងដោយសន្ធិសញ្ញាបារាំង-ថៃឆ្នាំ១៩០៦មិនដូចគ្នានឹងផែនទីដែលបារាំងកំណត់ឡើងនៅពេលខ្លួនគ្រប់គ្រងតំបន់ឥណ្ឌូចិន ហើយផែនទីទាំងពីរនេះខុសគ្នានឹងផែនទីដែលកំណត់ដោយអាមេរិក ។ ប្រទេសថៃនិយាយថា ខ្លួនមានការលំបាកក្នុងការថែរក្សាស្រុកកូងយ៉ៃនៅក្នុងខេត្តត្រាតដែលជាតំបន់ខស្សាហកម្មរុក្ខាប្រមាញ់ដ៏សំខាន់ពីខ្ទាមខ្មែរក្រហម ។

ដំណើរទស្សនកិច្ចរយៈពេល២ថ្ងៃមកកាន់ព្រំដែនកម្ពុជា-ថៃធ្វើឲ្យ គ្រៀងសាក់ ឆាម៉ាណន ទោរទន់ទៅរកការស្វាគមន៍ខ្មែរក្រហម ។ ជាការពិតនៅមុនពេលមានការពិភាក្សាគ្នារវាងប្រទេសទាំងពីរ គ្រៀងសាក់ ឆាម៉ាណន បង្កើតឲ្យមានបទឈប់បាញ់គ្នាមួយជាមួយលក្ខខណ្ឌមួយចំនួន ។

ទស្សនាវដ្តី«សេដ្ឋកិច្ចចុងបូព៌ា»ចេញផ្សាយកាល ពីខែកុម្ភៈ ឆ្នាំ១៩៧៨ ឲ្យដឹងថា ទាំងភាគីថៃនិងកម្ពុជាព្យាយាមផ្សះផ្សាគ្នា ដើម្បីកុំឲ្យមានការបាត់បង់ជីវិតមនុស្សនិងខូចខាតទ្រព្យសម្បត្តិតទៅទៀត ។ រដ្ឋមន្ត្រីការបរទេស ឧបឌិត បញ្ចារាំងគុន បានមកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញដើម្បីពិភាក្សាពីសង្គ្រាមព្រំដែនតំបន់ឥណ្ឌូចិន ដោយបានសង្កត់ធ្ងន់ថា គ្មានប្រយោជន៍អ្វីដែលប្រទេសនីមួយៗប្រើងប្រែងធ្វើសង្គ្រាមឡើយ ។ គាត់សុំឲ្យប្រទេសកម្ពុជាបំភ្លេចចោលអតីតកាលនិងធ្វើឲ្យចំណងទាក់ទងជាមួយថៃប្រសើរឡើង ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យស្វាគមន៍បេសកកម្មការទូតរបស់ថៃដើម្បីដោះស្រាយបញ្ហាជម្លោះដោយសន្តិវិធី ។ នៅក្នុងពិធីលៀងភោជន៍ អៀង សារី បំបាត់ចោលនូវការសង្ស័យមួយចំនួនដែលបណ្តាលឲ្យមានការល្អក់កករដល់ទំនាក់ទំនងការទូតរវាងកម្ពុជានិងថៃដោយបាននិយាយថា ប្រសិនបើកម្ពុជាប្រជាធិតេយ្យជាប្រទេសល្មោភសង្គ្រាម ប្រទេសដទៃទៀតនៅក្នុងតំបន់អាស៊ីក៏មិនមានសន្តិភាពនិងសន្តិសុខដែរ ។ ក្នុងន័យនេះ អៀង សារី ចង់បង្ហាញភាគីថៃថា កម្ពុជាប្រជាធិតេយ្យមិនដែលឈ្លានពានទឹកដីប្រទេសជិតខាងឡើយ ។

ជម្លោះនៅតាមព្រំដែនហាក់ដូចជាមានសភាពស្ងប់ស្ងាត់ បន្ទាប់ពីដំណើរទស្សនកិច្ចរបស់អគ្គរាជទូតស៊ុយអែដ អូប៉ែរ មកកាន់ប្រទេសកម្ពុជា ។ ទោះយ៉ាងណាក៏ដោយ ក្រុមអ្នកវិភាគរបស់ថៃបានចោទប្រកាន់កងទ័ពកម្ពុជាប្រជាធិបតេយ្យថាបានឈ្លានពានទឹកដីថៃបន្ទាប់ពីក្រុមអ្នកវិភាគទាំងនោះបានរកឃើញសហប្រតិ-បត្តិការរវាងកងទ័ពកម្ពុជាប្រជាធិបតេយ្យនិងបក្សកុម្មុយនិស្តថៃ ដែលជាក្រុមប្រឆាំងរដ្ឋាភិបាល គ្រៀងសាក់ ឆាម៉ាណន ។

ទស្សនាវដ្តី «សេដ្ឋកិច្ចចុងបូព៌ា» ចេញផ្សាយថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៨ ការវាយឆ្មក់តាមព្រំដែនបានសម្លាប់មន្ត្រីថៃជាបន្តបន្ទាប់ រហូតរដ្ឋាភិបាលថៃទទួលស្គាល់ថាខ្លួនបានបាត់បង់ជីវិតមនុស្សនិងទ្រព្យសម្បត្តិជាច្រើន ។ ក្រុមបះបោរកុម្មុយនិស្តនៅខេត្តត្រាតបានសម្លាប់ឧត្តមសេនីយ៍ រ៉ាំងស៊ី ស៊ូវ៉ាណាទន់ និងប៉ូលិសពនាក់ ព្រមទាំងធ្វើឲ្យរបួសមន្ត្រីមួយចំនួននៅពេលកំពុងធ្វើដំណើរដោយរថយន្តឆ្លងកាត់ខេត្តត្រាត ។ ការវាយប្រហារថ្មីៗនេះជាឧបសគ្គចម្បងមួយដែលធ្វើឲ្យរាំងស្ទះដល់គោលនយោបាយផ្សះផ្សារបស់ គ្រៀងសាក់ ឆាម៉ាណន ជាមួយកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះទាំងរដ្ឋាភិបាលទីក្រុងភ្នំពេញនិងទីក្រុងបាងកកបានទម្លាក់កំហុសលើ«អង្គការស៊ីយ៉ាម» ដែលគាំទ្រដោយបក្សកុម្មុយនិស្តថៃ ។ មិនមានភ័ស្តុតាងណាមួយដែលបញ្ជាក់ច្បាស់អំពីកំណើតអង្គការនេះទេ ប៉ុន្តែក្រុមអ្នកសង្កេតការណ៍ឯករាជ្យបានសន្និតថា អង្គការនេះបង្កើតឡើងដោយក្រុមជ្រុលនិយមថៃដែលបានរត់ចូលព្រៃបន្ទាប់ពីមានរដ្ឋប្រហារទម្លាក់រដ្ឋាភិបាលលោក គូគ្រិត ប្រាមោជ្ជ នៅប្រទេសថៃ កាលពីខែតុលា ឆ្នាំ១៩៧៦ ហើយក្រុមនេះមានទំនោរប្រឆាំងរដ្ឋាភិបាល គ្រៀងសាក់ ឆាម៉ាណន ។

កាសែតញូវយ៉កថែមស៍ចេញផ្សាយកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៨ បាននិយាយថា ការចរចាគ្នារវាងកម្ពុជាប្រជាធិបតេយ្យនិងថៃបានប្រព្រឹត្តទៅជាច្រើនលើកច្រើនសា ដោយភាគីថៃបានចាត់ទុកជម្លោះនោះថាមកពីការយល់ច្រឡំគ្នាទៅវិញទៅមករវាងកម្ពុជានិងថៃ ។ រដ្ឋមន្ត្រីការបរទេសថៃ ឧបឌិត បញ្ចារាំងគុន បានប្រាប់អ្នកយកពត៌មានអំពីសេចក្តីសម្រេចលើបទឈប់បាញ់គ្នាមួយជាមួយកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីការប្រជុំចំនួនពីរលើកជាមួយរដ្ឋមន្ត្រីការបរទេស អៀង សារី នៅក្នុងដំណើរទស្សនកិច្ចមកកាន់ប្រទេសថៃ ។

កាសែតវ៉ាស៊ីងតោនប៉ុស្តិ៍ចេញផ្សាយថ្ងៃទី២៨ ខែកញ្ញា បាននិយាយថា អ្នកសង្កេតការជាច្រើនទាក់ជឿជាក់ថា អៀង សារី នឹងជួបពិភាក្សាជាមួយរដ្ឋមន្ត្រីការបរទេស ឧបឌិត បញ្ចារាំងគុន នៅក្នុងសម័យប្រជុំរបស់អង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉កនៅខែតុលាដើម្បីបញ្ចប់ជម្លោះព្រំដែននិងដោះស្រាយបញ្ហាជនភៀសខ្លួននៅក្នុងទឹកដីថៃ ។

ការផ្លាស់ប្តូរអគ្គរដ្ឋទូតរវាងប្រទេសកម្ពុជានិងប្រទេសថៃ ហាក់ដូចជាស្ងប់ស្ងាត់តាំងពីនាយករដ្ឋមន្ត្រី គូគ្រិត ប្រាមោជ្ជ ត្រូវបានទម្លាក់ពីតំណែងដោយរដ្ឋប្រហារកាលពីឆ្នាំ១៩៧៦និងដោយសារជម្លោះព្រំដែនដ៏ក្តៅគគុកចាប់ពីឆ្នាំ១៩៧៧ ។ ភាគីទាំងពីរមិនអាចកសាងទំនាក់ទំនងការទូតដ៏ល្អមួយបានទេរហូតដល់របបកម្ពុជាប្រជាធិបតេយ្យត្រូវផ្តួលរំលំនៅឆ្នាំ១៩៧៩ ។

**ស៊ូ ហ្សារីណា**

# មជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរករូបថតជនរងគ្រោះ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្ដាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្ដីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ *FM102MHz* ទីក្រុងភ្នំពេញ វិទ្យុ *FM93.25MHz* ខេត្តកំពត វិទ្យុ *FM99MHz* ខេត្តព្រះវិហារ និងវិទ្យុ*FM* ១០៣.២៥*MHz* ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជួទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្ដីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះ យើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួន ។ រូបថតទាំងនោះ ចាំបាច់ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នកបន្ទាប់មកនឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។


បាន សារឿន និងក្មួយៗ

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រ លេខ១១១០ ភ្នំពេញឬទាក់ទងតាមអ៊ីមែល *truthwynne@dccam.org* ឬ *truthpivoine@dccam.org* ។

សូមអរគុណ ។

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២០១៨ | ព្រាប ទូត ហៅ ទូន (ស្រី) | ម្តាយ សំបូរ | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០១៥ | យស់ ប៉ុល (ស្រី) | ម្តាយ កង សីណា | ស-២១យ | ២៥-៣-៧៧ | ២៥-៣-៧៧ |
| ២០១៦ | ញ៉ឹក ឆិច ហៅ ផាត (ស្រី) | យុទ្ធនារី | ឃ្លាំងរដ្ឋ | ២៣-៣-៧៧ | ២៥-៣-៧៧ |
| ២០១៧ | ឡេង ទូច ហៅ វៀន (ស្រី) | យុទ្ធនារី | ផាមពល | ២៣-៣-៧៧ | ២៥-៣-៧៧ |
| ២០១៨ | គីន ហេង (ស្រី) | យុទ្ធនារី | ផាមពល | ២៣-៣-៧៧ | ២៥-៣-៧៧ |
| ២០១៩ | ស៊ាង លី (ស្រី) | យុទ្ធនារី | ផាមពល | ២៣-៣-៧៧ | ២៥-៣-៧៧ |
| ២០២០ | អែម ឡៃ ហៅ ស៊ីណា | សមាជិកក្រុម | ផាមពល | ២៥-៣-៧៧ | ៣០-៣-៧៧ |
| ២០២១ | ខ្ញុត សោម ហៅ លួក | អនុក្រុម | ផាមពល | ២១-២-៧៧ | ៣០-៣-៧៧ |
| ២០២២ | អ៊ឹម សំអឿន ហៅ រិត | មេក្រុម | ផាមពល | ២៦-១-៧៧ | ៣០-៣-៧៧ |
| ២០២៣ | ម៉ៃ ម៉េត ហៅ ហុក | យុទ្ធជន | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០២៤ | ស៊ឹន ខេន ហៅ ណាន | យុទ្ធជន | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០២៥ | អួង យ៉ាវ | មេពួក | ផាមពល | ៣០-២-៧៧ | ៣០-៣-៧៧ |
| ២០២៦ | អ៊ុំ ងន ហៅ យន | មេក្រុម | ផាមពល | ?-?-៧៧ | ៣០-៣-៧៧ |
| ២០២៧ | ម៉េង ស្រ៊ិន | មេពួក | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០២៨ | សាន ជឹង ហៅ ខា | មេក្រុម | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០២៩ | សូ ឃួន ហៅ លី | សមាជិកក្រុម | ផាមពល | ១០-៣-៧៧ | ៣០-៣-៧៧ |
| ២០៣០ | សំ យាត | យុទ្ធជនបើកបរ | ផាមពល | ១០-៣-៧៧ | ៣០-៣-៧៧ |
| ២០៣១ | ទក សួម ហៅ សា | យុទ្ធជន | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៣២ | យឹម ជ្រឹន ហៅ ផាយ | យុទ្ធជន | ផាមពល | ?-២-៧៧ | ៣០-៣-៧៧ |
| ២០៣៣ | ម៉ាញ់ សឿន | មេក្រុម | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៣៤ | ម៉ក់ ម៉េង ហៅ ជាតិ | យុទ្ធជន | ផាមពល | ១០-៣-៧៧ | ៣០-៣-៧៧ |
| ២០៣៥ | ប៊ុន សយ | កម្មករចាស់ | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៣៦ | យឹម សារឿន ហៅ ស្រិល | យុទ្ធជន | ផាមពល | ២៧-៣-៧៧ | ៣០-៣-៧៧ |
| ២០៣៧ | ពុំ ឈួន | មេពួក | ផាមពល | ២៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៣៨ | ប៊ុន ស៊ឹម | យុទ្ធជន | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៣៩ | ហ៊ឹង ហ៊ាង ហៅ រ៉ុម | យុទ្ធជន | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៤០ | ង៉ែត គុណ ហៅ វឿន | យុទ្ធជន | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២០៤១ | ទូត ស្រ៊ុន ហៅ សយ | យុទ្ធជន | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៤២ | អ៊ុត ខឿន ហៅ ខា | យុទ្ធជន | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៤៣ | ញឹម គឹមលាត ហៅ លាត | យុទ្ធជន | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៤៤ | នូ ហ៊ុម ហៅ ហម | មេក្រុម | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៤៥ | ប្រុក ឡុញ ហៅ លឹម | យុទ្ធជន | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៤៦ | ទឹម ស៊ុន ហៅ ស៊ិន | យុទ្ធជន | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៤៧ | ព្រុំ ម៉ៅ | យុទ្ធជន | ផាមពល | ៣-៣-៧៧ | ៣០-៣-៧៧ |
| ២០៤៨ | វ៉ាន់ ណូ ហៅ ចិត្ត | អនុក្រុម | ផាមពល | ៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៤៩ | លុយ លឹម | យុទ្ធជន | ផាមពល | ៥-៣-៧៧ | ៣០-៣-៧៧ |
| ២០៥០ | គាំ សំអុល ហៅ អន | យុទ្ធជនបើកបរ | ផាមពល | ៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៥១ | ភោគ ហ៊ិន | កម្មករចាស់ | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៥២ | ប៉ាច សុក | ជាងឈើ | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៥៣ | ហាំង ម៉ាន់ ហៅ ចេក | មេពួក | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៥៤ | សុត យ៉េ | មេពួក | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៥៥ | ឡម គាន | យុទ្ធជន | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៥៦ | ហុន ជា | យុទ្ធជន | ផាមពល | ១០-២-៧៧ | ៣០-៣-៧៧ |
| ២០៥៧ | គង់ ហ៊ិន ហៅ ហួត | កងហា | ផាមពល | ១០-២-៧៧ | ៣០-៣-៧៧ |
| ២០៥៨ | នាង គឹមសុក | យុទ្ធជន | ផាមពល | ២៥-៣-៧៧ | ៣០-៣-៧៧ |
| ២០៥៩ | ពៅ សន ហៅ ហៃ | យុទ្ធជន | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៦០ | អ៊ុន អេន ហៅ ផន | មេពួក | ផាមពល | ២៥-៣-៧៧ | ៣០-៣-៧៧ |
| ២០៦១ | អេង អ៊ុល ហៅ អន | យុទ្ធជន | ផាមពល | ២-៣-៧៧ | ៣០-៣-៧៧ |
| ២០៦២ | ទេព ភឿន ហៅ ស៊ា | មេក្រុម | ផាមពល | ១៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៦៣ | តែវ ណាយ ហៅ ណៃ | មេក្រុម | ផាមពល | ១៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៦៤ | ប៉ាន់ ខេមរា ហៅ ណង់ | យុទ្ធជន | ផាមពល | ១៥-៣-៧៧ | ៣០-៣-៧៧ |
| ២០៦៥ | គឹម ឈិត | យុទ្ធជន | ផាមពល | ១៦-៣-៧៧ | ៣០-៣-៧៧ |
| ២០៦៦ | សំរិត ជឿន ហៅ ឈឿន | មេក្រុម | ផាមពល | ១៦-៣-៧៧ | ៣០-៣-៧៧ |
| ២០៦៧ | បិន បឿត ហៅ ម៉េត | មេពួក | ផាមពល | ១៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៦៨ | ណៅ នី ហៅ យ៉ន | មេក្រុម | ផាមពល | ១៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៦៩ | សួស ផល | យុទ្ធជន | ផាមពល | ១៥-៣-៧៧ | ៣០-៣-៧៧ |
| ២០៧០ | ថ្វាង យុន ហៅ យ៉ាន់ | កងហា | ផាមពល | ១៤-៣-៧៧ | ៣០-៣-៧៧ |
| ២០៧១ | ងួន ស៊ិន | មេក្រុម | ផាមពល | ១៤-៣-៧៧ | ៣០-៣-៧៧ |

**(នៅមានត)**

# ក្លាយជាអ្នកទោសខ្មែរក្រហម

អតីតកាលដូរចត់បានកន្លងទៅប្រមាណ៣០ឆ្នាំហើយ ប៉ុន្តែហេតុការណ៍ដែល កែវ ម៉ៅ ធ្លាប់បានជួបប្រទះនៅក្នុងរបបខ្មែរក្រហមនៅតែស្ថិតនៅក្នុងអារម្មណ៍របស់គាត់ជានិច្ច ។ អារម្មណ៍ឈឺចាប់លាយឡំនឹងការភ័យខ្លាចនៅពេល ម៉ៅ ជាប់គុករបស់ខ្មែរក្រហមបានជិតជាមលុបលើអារម្មណ៍សប្បាយរីករាយនិងមោទកភាពដែល ម៉ៅ ធ្លាប់មាននៅពេលដែលគាត់ធ្វើជាកងទ័ពរបស់ខ្មែរក្រហមនៅអំឡុងពេលសង្គ្រាមក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ម្ល៉េះ ។


កែវ ម៉ៅ

កែវ ម៉ៅ រស់នៅក្នុងភូមិត្រពាំងតាសុក ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ជាមួយប្រពន្ធនិងកូនបីនាក់ ។ ថ្វីដ្បិតតែសព្វថ្ងៃ ម៉ៅ មានក្រុមគ្រួសារ មានផ្ទះសម្បែង មានដីស្រែចម្ការ និងមានជីវភាពសុខស្រួលក៏ដោយ ក៏អតីតកាលដែល ម៉ៅ ធ្លាប់បានឆ្លងកាត់ក្នុងរបបខ្មែរក្រហមមិនបានរលុបបាត់ពីចិត្តរបស់គាត់ទេ ។

ម៉ៅ បានចូលបម្រើក្នុងជួរកងទ័ពរំដោះនៅឆ្នាំ១៩៧១ ។ ម៉ៅ ត្រូវបានបញ្ជូនឲ្យទៅប្រយុទ្ធនៅសមរភូមិកំពង់ស្ពឺនៅក្បែរស្រុកតាកែវ ។ ក្រៅពីនេះ ម៉ៅ បានចូលប្រយុទ្ធក្នុងសមរភូមិជាច្រើនទៀត ។ នៅឆ្នាំ១៩៧៤ ម៉ៅ រងរបួសធ្ងន់ធ្ងរ ។ មិនយូរប៉ុន្មាន ក្រោយពីត្រូវរបួស ប្រធានកងពលរបស់ ម៉ៅ ត្រូវថ្នាក់លើចោទថាជាខ្មាំងនិងត្រូវបានចាប់ខ្លួន ។ ម៉ៅ ដែលជាយុទ្ធជនម្នាក់នៅក្នុងកងពលក៏ត្រូវចោទប្រកាន់ថាជាខ្មាំងដែរ ហើយត្រូវចាប់បញ្ជូនទៅមន្ទីរឃុំឃាំងនៅចុងឆ្នាំ១៩៧៤ ។ ម៉ៅ ជាមួយនឹងយុទ្ធជនពីរនាក់ទៀតដែលមកពីកងពលផ្សេងត្រូវកងទ័ពបញ្ជូនដោយថ្មើរជើងអស់រយៈពេល១យប់១ថ្ងៃទៅគុកក្រាំងតាចាន់ ។ មកដល់គុកមុនដំបូង ម៉ៅ និងយុទ្ធជនទាំងពីរជាប់ក្នុងបន្ទប់ជាមួយគ្នានិងជាប់ខ្នោះជាមួយគ្នា ។ ក្រោយមក ម៉ៅ ត្រូវបញ្ជូនទៅដាក់នៅក្នុងបន្ទប់មួយផ្សេងទៀតរួមជាមួយអ្នកទោសប្រមាណ ២០នាក់ ។ អ្នកទោសនៅក្នុងបន្ទប់នោះទាំងអស់សុទ្ធតែជាអ្នកទោសកម្រិតធ្ងន់ ។ អ្នកទោសម្នាក់ៗជាប់ខ្នោះជើងទាំងពីរនិងខ្នោះដៃ មានដែកបុកនៅដើមទ្រូងនិងមានសំណាញ់ដែកជាប់ពីលើក្បាល មិនអាចកម្រើខ្លួនរួច ។ ម៉ៅ ក៏មិនខុសពីអ្នកទោសទាំងនោះដែរ គាត់បានត្រឹមតែដេកផ្ងារខ្លួនប៉ុណ្ណោះ ។ កងទ័ពខ្មែរក្រហមបានយក ម៉ៅ ទៅសួរចម្លើយដោយរុំភ្នែកនឹងក្រណាត់ខ្មៅ ។ នៅរាល់ពេលសួរចម្លើយម្តងៗ អ្នកសួរចម្លើយបានធ្វើទារុណកម្ម ម៉ៅ យ៉ាងខ្លាំង ។ អ្នកសួរចម្លើយបានយកយកក្រណាត់កៅស៊ូខ្ទប់ច្រមុះ ម៉ៅ រហូតដល់គាត់សន្លប់ រួចដាក់ខ្នោះឆ្កាងដៃជើងនិងដាក់ឲ្យគាត់ដេកផ្ងារ ។ ម៉ៅបានបន្តថា *«ពេលខ្ញុំសន្លប់ទៅខ្ញុំអត់ដឹងទេ ប៉ុន្តែពេលគេលើកសួរចម្លើយម្តងទៀតយូរណាស់ ទម្រាំតែរកដង្ហើមបាននិយាយជាមួយគេម្តងៗ»* ។

រយៈពេល ៤ខែក្រោយមក ម៉ៅ ត្រូវបានសម្រាលទោសហើយដូរមកបន្ទប់មួយទៀត ដែលនៅទីនោះ ម៉ៅ ជាប់ខ្នោះតែជើងម្ខាងទេ ហើយអាចដើរចុះឡើងនៅក្នុងបន្ទប់គុកបាន ។ ម៉ៅ និយាយថា ចំនួនអ្នកទោសនៅក្នុងគុកកើនឡើងឬថយចុះមិនទៀងទាត់ ដោយសារអ្នកទោសជាច្រើនត្រូវឆ្មាំគុកនាំចេញពីគុកយកទៅសម្លាប់ ហើយជំនួសវិញដោយអ្នកទោសថ្មីៗ ។ អ្នកទោសខ្លះទៀតស្លាប់ទាំងជាប់ខ្នោះនៅក្នុងបន្ទប់ឃុំឃាំង ។ ម៉ៅ បានលួចមើលតាមប្រឡោះជញ្ជាំងឃើញឆ្មាំគុកយកសាកសពអ្នកទោសដែលសម្លាប់រួចហើយមកបោះគរលើគ្នាក្នុងរណ្តៅរួម ដែលពេលខ្លះរណ្តៅមិនទាន់ជីករួចនៅឡើយ ។ ម៉ៅ រៀបរាប់ថា ឆ្មាំគុកម្នាក់ហៅអ្នកទោសចេញទៅ ឆ្មាំគុកម្នាក់ទៀតចាំនៅខាងក្រៅភ្ជង់កាំភ្លើងហើយបណ្តើរអ្នកទោសចេញទៅមិនឆ្ងាយប៉ុន្មានពីគុកគឺប្រហែល២០ម៉ែត្រកំបាំងនឹងព្រៃគុម្ពោតមួយ រួចហើយគាត់ក៏ឮសំឡេងអ្នកទោសស្រែកអ៊ឺះៗនិងឮស្នូររើបម្រះ ។ នៅពេល

ដែលសំឡេងនោះស្ងាត់ក៏ឃើញឆ្មាំគុកអូសសាកសពអ្នកទោសទៅទម្លាក់ក្នុងរណ្ដៅរួម ។ បន្ទាប់មក ឆ្មាំគុកត្រឡប់មកគុកវិញនាំអ្នកទោសទៅម្នាក់ទៀត ។ ការសម្លាប់បែបនេះប្រព្រឹត្តទៅប្រហែលពីម៉ោង៨ពរសៀលរហូតដល់ម៉ោង៦ល្ងាច ។ ហេតុការណ៍នេះធ្វើឲ្យ ម៉ៅ បារម្ភអំពីជោគវាសនារបស់ខ្លួន មិនដឹងថាថ្ងៃណានឹងដល់វេនរបស់ខ្លួន ។ ម៉ៅ និយាយថា "ដល់ពេលគេហៅឈ្មោះទៅខ្ញុំភ័យថាខ្ញុំបែបមុនហើយនិងក្រោយទេ ដល់គេហៅរំលងឈ្មោះខ្ញុំហ្នឹងទៅដូចថាខ្លួនឯងរាងអរបន្តិចភ័យបន្តិច ។ ស្អែកឡើងគេហៅមួយសាទៀតខ្ញុំភ័យទៀត មិនដឹងឈ្មោះគេឬឈ្មោះខ្ញុំទៀត ទម្រាំរួចពីឈ្មោះខ្ញុំហ្នឹងទៅបានអរទៀតហើយ ។ ៣-៤ខែភ័យតែរហូត" ។

បន្ទាប់ពីជាប់ក្នុងមន្ទីរឃុំឃាំងក្រាំងតាចាន់អស់រយៈពេល៩ខែ ម៉ៅ ត្រូវអង្គការបញ្ជូនទៅមន្ទីរ២០៤ដែលនៅក្នុងព្រៃក្តួច ។ ម៉ៅ រស់នៅក្នុងមន្ទីរ២០៤អស់រយៈពេលជាងមួយឆ្នាំ ទើបអង្គការដោះលែងឲ្យត្រឡប់មកភូមិធ្វើការងារតាមកងចល័តដូចប្រជាជនដទៃទៀត ប៉ុន្តែគាត់នៅតែស្ថិតក្រោមការតាមឃ្លាំមើលពីអង្គការដដែល ។ ម៉ៅ បានបញ្ជាក់ថា "...គេបញ្ជូនទៅកងចល័តបានមានសិទ្ធិសេរី ប៉ុន្តែក្នុងការតាមដានដដែល" ។

ក្រោយពេល ម៉ៅ រួចខ្លួនពីមន្ទីរឃុំឃាំង២០៤ បានរយៈពេល៦ថ្ងៃ អង្គការក៏រៀបចំឲ្យ ម៉ៅ មានគូស្រករ គឺជាពិធីប្តេជ្ញាតាមរបៀបរបស់អង្គការ ហើយគាត់ក៏រស់នៅជាមួយប្រពន្ធដែលអង្គការផ្សំផ្គុំនោះរហូតដល់សព្វថ្ងៃនេះ ។

រហូតមកដល់បច្ចុប្បន្ន រឿងដែលធ្វើឲ្យ ម៉ៅ ឈឺចាប់ជាងគេនោះគឺការដែលអង្គការចោទប្រកាន់គាត់ថាជាខ្មាំងដោយគាត់មិនដឹងអំពីមូលហេតុទាល់តែសោះ ។ គាត់ចាប់ផ្តើមមួម៉ៅ ខឹងប្រឡាត និងពេលខ្លះឆាប់ភ័យខ្លាច ។ ម៉ៅ នៅតែយល់សប្តិជារឿយៗឃើញថាខ្លួនគាត់ជាប់គុក ។ ម៉ៅ រំឭកថា "...ខ្ញុំគ្មាននឹកឃើញថារស់ទេ សព្វថ្ងៃនៅតែយល់សប្តិឃើញថាជាប់គុកដដែល បេះតែគិតនឹកឃើញថាមិនទាន់មានប្រពន្ធកូនអីទេ នឹកឃើញតែនៅក្នុងគុករហូត នឹកឃើញតែភ័យរហូត ដល់ពេលភ្ញាក់ឡើងបានដឹងថាអញរួចពីគុកហើយ អញមានប្រពន្ធមានកូនហើយ" ។

អង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមមានសារសំខាន់ណាស់ចំពោះ ម៉ៅ ពីព្រោះម៉ៅចង់ដឹងថាតើមានអ្វីនឹងកើតឡើងចំពោះបុគ្គលដែលធ្លាប់ធ្វើទុក្ខបុកម្នេញរូបគាត់នៅក្នុងរបបខ្មែរក្រហម ។ ម៉ៅ នៅតែមានកំហឹងចំពោះអ្នកដែលធ្វើបាបគាត់ ប៉ុន្តែ ម៉ៅ មិនជ្រើសរើសយកការសងសឹកទេ ហើយគាត់រង់ចាំច្បាប់ដើម្បីកាត់សេចក្តី ។ ទោះបីជាគាត់ធ្លាប់ធ្វើជាកងទ័ពរបស់ខ្មែរក្រហមក៏ដោយ ប៉ុន្តែទីបំផុត ម៉ៅ និយាយថា "ខ្ញុំក្លាយជាអ្នកទោសខ្មែរក្រហមទៅវិញ" ។

**ស៊ុំ សាទីណា**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

◆ វិទ្យុ FM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។

◆ វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។

◆ វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។

◆ វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**សូ ហ្វារីណា និង លី សុផល**

# ជីវិតគ្រួសារខ្មែរ-វៀតណាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ភូមិអន្លង់ទ្រាស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គ និងមានប្រជាជនវៀតណាមជាច្រើនរស់នៅ។ នៅរដូវវស្សា ភូមិនេះត្រូវពន្លិចដោយទឹកជំនន់ ហើយអ្នកភូមិជិះទូកចម្ងាយប្រមាណពីរបីគីឡូម៉ែត្រទៅទីរួមខេត្តស្វាយរៀងដើម្បីលក់ដូរត្រីសាច់និងបន្លែបង្ការ ។ ទិដ្ឋភាពនៅភូមិអន្លង់ទ្រាពេលថ្ងៃជិតលិចពិតជាគួរឲ្យចាប់ចិត្តក្រៃលែង ។ ដូច្នេះមិនពិបាកពន្យល់ទេអំពីមូលហេតុដែល យុន ម៉ុន ទាក់ភ្នែកចំពោះសម្រស់របស់ សេង ហួ នៅភូមិអន្លង់ទ្រា ។ កាលបួសជាសង្ឃ ម៉ុន បាននិមន្តទៅទីរួមខេត្តព្រៃវែង ហើយបានឃើញ សេង ហួ ចែវទូកទៅទិញឥវ៉ាន់ ។


យុន ម៉ុន

យុន ម៉ុន ចាប់កំណើតនៅឆ្នាំ១៩៤០ នៅភូមិស្វាយអន្ទរ ដែលស្ថិតនៅខាងជើងទីរួមខេត្តព្រៃវែងប្រមាណ១០គីឡូម៉ែត្រ ។ ម៉ុន គឺជាកូនទី៤ក្នុងចំណោមបងប្អូនប្រុស៤នាក់ ស្រី៤នាក់ ។ នៅឆ្នាំ១៩៥៧ ពេលដែល ម៉ុន មានអាយុ៥ឆ្នាំ ម៉ុន បានបួសជាសាមណេរនៅវត្តស្វាយបទុម ក្នុងឃុំស្វាយអន្ទរ ក្នុងបំណងរៀនសូត្រទាំងផ្លូវធម៌និងផ្លូវលោកដើម្បីធ្វើជាគ្រូបង្រៀននៅពេលអនាគត ។ នៅក្នុងរបបសង្គមរាស្ត្រនិយម ព្រះសង្ឃនិងសិស្សដែលទទួលការសិក្សាក្រៅប្រព័ន្ធមានសិទ្ធិដាក់ពាក្យប្រឡងធ្វើគ្រូបង្រៀន ។ នៅឆ្នាំ១៩៦៨ ជិតដល់ពេលដែលត្រូវប្រឡងធ្វើជាគ្រូបង្រៀន ម៉ុន ក៏លាចាកសិក្ខាបទវិលត្រឡប់មកភូមិវិញរស់នៅជាមួយឪពុកម្តាយ ប្រកបរបរលក់ចាប់ហួយ ចិញ្ចឹមជ្រូកនិងធ្វើស្រែចម្ការ ។

សេង ហួ ដែលស្រស់ស្អាតដូចជាកូនកាត់ កើតនៅឆ្នាំ១៩៥០ នៅក្នុងគ្រួសារមួយដែលមានឪពុកជាជនជាតិចិនឈ្មោះ សេង និងម្តាយជាជនជាតិវៀតណាមឈ្មោះ ឡេ ធីហាយ នៅភូមិអន្លង់ទ្រា ឃុំព្រែកជ្រៃ ស្រុកពាមរក៍ ។ សេង ហួ មានបងប្អូនប្រុសស្រី៥នាក់ ។ អំឡុងពេលដែលរៀននៅសាលា ហួ ស្នាក់នៅផ្ទះបងប្រុសជីដូនមួយឈ្មោះ ហុក ឈន ដែលក្រោយមកក្លាយជាចៅហ្វាយស្រុកពាមរក៍ ។ ហួ រៀនចប់ថ្នាក់ទី៤ និងបានរៀនជំនាញកាត់ដេរ ។ នៅពេលឪពុកម្តាយរបស់ ម៉ុន ចូលស្តីដណ្តឹង សេង ហួ, ម៉ុន ភ្ញាក់ផ្អើលនិងសប្បាយចិត្តជាខ្លាំង ។ ម៉ុន មិននឹកស្មានសោះថា ឪពុកម្តាយរបស់គាត់ស្តីដណ្តឹងប៉ះចំស្ត្រីដែលគាត់ពេញចិត្តតាំងពីពេលដែលឃើញជាលើកទី១ ។ ម៉ុន និយាយថា ឪពុកម្តាយខាងស្រីបានបង្គាប់បណ្តាការជាប្រាក់ ៨.៥០០រៀល (ស្មើនឹងមាស២តម្លឹងកន្លះ) ។ ពិធីអាពាហ៍ពិពាហ៍បានប្រព្រឹត្តទៅនៅផ្ទះខាងស្រីនៅថ្ងៃទី១៣រោច ខែកត្តិក ក្នុងឆ្នាំ១៩៦៩ នៅភូមិអន្លង់ទ្រា គឺ៣ខែបន្ទាប់ពី ម៉ុន លាចាកសិក្ខាបទ ។ បន្ទាប់ពីនោះមានពិធីជប់លៀងដ៏ធំមួយទៀតដែលអញ្ជើញភ្ញៀវ២០តុនៅផ្ទះកូនកំលោះ ។

ពិធីអាពាហ៍ពិពាហ៍ដំណើរការតាមទំនៀមទម្លាប់ខ្មែរផងនិងវៀតណាមផង ។ គូស្រករថ្មីនេះក៏បានទទួលពរជ័យយ៉ាងកក់ក្តៅពីអ្នកភូមិ ។ បងស្រីធំបង្អស់របស់ ម៉ុន កត់សម្គាល់ថា "គ្មាននរណាម្នាក់រិះគន់ ម៉ុន អំពីការរៀបការជាមួយស្ត្រីវៀតណាមទេ ។ អ្នកភូមិនៅតែរាប់អានគាត់ដូចធម្មតា" ។

ពីរខែក្រោយថ្ងៃរៀបការ ម៉ុន និងប្រពន្ធ បានផ្លាស់ទៅរស់នៅផ្ទះថ្មីក្បែរផ្ទះឪពុកម្តាយរបស់ ម៉ុន នៅភូមិស្វាយអន្ទរ ។ ទាំងពីរនាក់ប្តីប្រពន្ធមិនប៉ិនប្រសប់ខាងការងារស្រែចម្ការដូចជាឪពុកម្តាយរបស់ខ្លួនទេ ។ សេង ហួ ជាមនុស្សរួសរាយឆ្លាតវៃនិងពូកែខាងជួញដូរ ។ ម៉ុន រំឭកថា "ប្រពន្ធខ្ញុំឆ្លាតណាស់ ព្រោះគាត់មានឈាមជ័រចិន ។ គាត់ចេះនិយាយភាសាចិននិងពូកែគិតលេខណាស់" ។ ទាំងពីរនាក់ប្រកបរបរលក់ចាប់ហួយ ។ យុន ម៉ុន

និយាយថា "ប្រពន្ធខ្ញុំជួយខ្ញុំច្រើនណាស់ ។ គាត់ដាំបាយដាំទឹក លក់ដូរ និងធ្វើកិច្ចការផ្សេងៗទៀត" ។ ប្រហែល១ឆ្នាំក្រោយមក ឪពុកម្តាយ បងប្រុសឈ្មោះ សេង កែ និងបងស្រីឈ្មោះ សេង ទៀង បានមករស់នៅជាមួយ ម៉ុន និង ហួ ។ ក្រុមគ្រួសារនេះរស់នៅតាមរបៀបជាខ្មែរ ប៉ុន្តែក៏ប្រារព្ធពិធីបុណ្យចូលឆ្នាំវៀតណាមដែរ ។ ការលក់ដូរក៏បានកក់កប ហើយក្រុមគ្រួសារក៏រស់នៅយ៉ាងមានសេចក្តីសុខ ។ ម៉ុន និង ហួ មានកូនបីនាក់ៈ កូនប្រុសម្នាក់កើតឆ្នាំ១៩៧០ កូនស្រីម្នាក់កើតឆ្នាំ១៩៧៣ និងកូនប្រុសម្នាក់ទៀតកើតឆ្នាំ១៩៧៥ ។ ម៉ុន និយាយថា ប្រពន្ធរបស់គាត់និយាយភាសាខ្មែរបានយ៉ាងច្បាស់ ហើយកូនៗក៏គ្មាននរណាម្នាក់ចេះភាសាវៀតណាមផង ។

នៅឆ្នាំ១៩៧៥ ម៉ុន ត្រូវប្រធានភូមិចាត់តាំងឲ្យធ្វើការក្នុងកងភ្ជួរនៅភូមិស្វាយអន្ទរ ។ ជាធម្មតា ម៉ុន វិលមកផ្ទះជួបជុំក្រុមគ្រួសារនៅពេលយប់ ។ នៅឆ្នាំ១៩៧៦ ម៉ុន ធ្វើការជាមួយកងកុមារ ហើយត្រូវដេកនៅជំរំនៅឯវាលស្រែរយៈពេលមួយឬពីរសប្តាហ៍ ប្រឈមមុខនឹងមូសខាំ ការងារហួសកម្លាំង និងការហូបចុកមិនគ្រប់គ្រាន់ ។ ក្នុងពេលជាមួយគ្នានោះ សេង ហួ ត្រូវប្រធានភូមិចាត់តាំងឲ្យធ្វើការក្នុងកងស្ត្រីធ្វើការនៅក្បែរភូមិ ។ ពេលល្ងាច ហួ អាចមកផ្ទះដើម្បីមើលកូនៗ ។ ហួ មិនត្រឹមតែរៀនអំពីរបៀបស្ទូងស្រូវប៉ុណ្ណោះទេ ប៉ុន្តែគាត់អាចស្ទូងបានលឿនមិនចាញ់អ្នកដទៃឡើយ ។ កូនៗរបស់គាត់ត្រូវទុកឲ្យស្ត្រីចាស់ៗមើលនៅមណ្ឌលកុមារ ។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៧ ឈ្លបខ្មែរក្រហមមួយក្រុមបានមកនាំខ្លួន សេង ហួ និងឪពុកម្តាយ ព្រមទាំងបងស្រីឈ្មោះ ទៀង បងប្រុសឈ្មោះ កែ ទៅប្រជុំរៀនសូត្រ ។ យុន ម៉ុន រំឭកហេតុការណ៍ឡើងវិញថា ÷

ពេលដែលខ្ញុំកំពុងតែភ្ជួរស្រែ មានមនុស្សប្រាប់ខ្ញុំថាប្រពន្ធខ្ញុំត្រូវអង្គការចាប់យកទៅសម្លាប់ហើយ ។ ខ្ញុំឈប់ភ្ជួរហើយត្រឡប់មកផ្ទះវិញ ប៉ុន្តែឃើញតែផ្ទះទទេស្អាត ។ សម្បត្តិរបស់របរក៏បាត់ទាំងអស់នៅសល់តែខោអាវរបស់ខ្ញុំប៉ុណ្ណោះ ។ ខ្ញុំសួរតាលឹមថា "ប្រពន្ធនិងកូនរបស់ខ្ញុំនៅឯណា?" តាលឹម ឆ្លើយថា "ទៅរៀនសូត្រហើយ" ។ ខ្ញុំដឹងថាប្រពន្ធកូនខ្ញុំត្រូវអង្គការសម្លាប់ចោលហើយព្រោះមិនឃើញត្រឡប់មកផ្ទះវិញជាង១០ថ្ងៃមកហើយ ។ ប្រធានឈ្លបហៅខ្ញុំទៅជួបគាត់ ។ ខ្ញុំអង្វរគាត់ថា "សូមមិត្តបងមេត្តាទុកកូនខ្ញុំម្នាក់ឲ្យមានជីវិតរស់ផង" ។ ជំនួសឲ្យចម្លើយ ប្រធានឈ្លបដកកាំភ្លើងភ្ជង់ខ្ញុំ ។ ខ្ញុំក៏ត្រូវចាប់ខ្លួនដាក់នៅក្នុងវត្តគ្វាវនៅក្នុងឃុំស្វាយអន្ទរដែរ ។ ខ្ញុំជាប់គុកតាំងពីឆ្នាំ១៩៧៧រហូតដល់ឆ្នាំ១៩៧៩ ។ នៅទីនោះ ខ្ញុំត្រូវបញ្ជាឲ្យធ្វើអ្វីៗគ្រប់បែបយ៉ាងដូចជាជីកដីជាដើម ។ ឈ្លបខ្មែរក្រហមបានអ្វីហូបក៏ឲ្យខ្ញុំហូបដែរ ហើយមិនដែលវាយឬសួរចម្លើយខ្ញុំទេ ។ ឈ្លបទាំងនោះកុហកខ្ញុំថាប្រពន្ធរបស់ខ្ញុំនៅវត្តគ្វាវដែរ ប៉ុន្តែតាមពិតអត់ទេ ។ គណៈឃុំឈ្មោះ ឆែម និងគណៈស្រុកឈ្មោះ ភា ។ អ្នកដែលទៅចាប់គ្រួសារខ្ញុំគឺប្រធានឈ្លបស្រុកឈ្មោះ ថូ ។ ខ្ញុំមិនដឹងថាអ្នកណាជាអ្នកបញ្ជាឲ្យមានការចាប់ខ្លួន ហើយក៏មិនដឹងថាប្រពន្ធកូននិងឪពុកម្តាយក្មេកព្រមទាំងបងថ្លៃខ្ញុំត្រូវយកទៅកន្លែងណាដែរ ។ ខ្ញុំគ្មានសម្បត្តិផ្ទះសម្រាប់រស់នៅដូច្នេះខ្ញុំក៏ទៅនៅជាមួយឪពុករបស់ខ្ញុំ ។ ខ្ញុំខឹងនឹងអ្នកដែលសម្លាប់ប្រពន្ធកូនខ្ញុំខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនដឹងថាគួរធ្វើយ៉ាងម៉េច ។ គួរឲ្យឈឺចាប់ណាស់គ្មានអ្វីប្រៀបប្រដូចបានទេ ។

ប៉ុន្មានម៉ោងមុនពេលត្រូវចាប់ខ្លួន សេង ហួ បានយកកូនៗទៅផ្ញើនឹងបងស្រីធំបង្អស់របស់ ម៉ុន ឈ្មោះ មុត ដោយសន្យាថាពីរម៉ោងក្រោយនឹងត្រឡប់មកយកកូនទៅវិញ ប៉ុន្តែ ហួ មិនត្រឡប់មកវិញជារៀងរហូត ។ ព្រឹកស្អែកឡើង ប្រធានភូមិឈ្មោះ តាលឹម និងឈ្លបពីរនាក់បានទៅយកកុមារទាំងបីដោយនិយាយថា "ម្តាយរបស់ក្មេងៗទាំងបីនាក់នេះឲ្យគាត់នាំក្មេងទៅជួប" ។ មុត និយាយថា "គេចាប់ពួកវាដាក់ក្នុងរទេះសេះ ។ កូនធំបង្អស់ពួននៅក្រោមគ្រែ ហើយស្រែកយំថា "ខ្ញុំមិនចង់ទៅទេ ខ្ញុំចង់នៅជាមួយយាយតាវិញ" ។ កូនទីពីរកំពុងតែគ្រុនក្តៅ ហើយខ្ញុំសុំទុកកូនមួយនេះ ប៉ុន្តែតាលឹម មិនព្រម" ។ ឪពុកនិងប្អូនស្រីពៅរបស់ ម៉ុន នៅក្នុងហេតុការណ៍នោះដែរ ប៉ុន្តែមិនអាចជួយអ្វីបានទាំងអស់ ។

ប្រហែលពីរសប្តាហ៍ក្រោយមក ម៉ុន ត្រូវប្រធានឈ្លបស្រុកឈ្មោះ ថូ ចាប់ខ្លួន និងបញ្ជូនទៅវត្តគ្វាវរហូតដល់ឆ្នាំ

១៩៧៩ ។ ម៉ុន មិនត្រូវបានដាក់ច្រវាក់ទេ ។ គាត់ដាំបន្លែនិងហូបចុកដូចជាប្រជាជនធម្មតាដែរ ។ ពេលយប់គាត់ដេកក្នុងផ្ទះមួយជាកន្លែងដែលតា ៗ ចំហុយថ្នាំបុរាណ ។ ម៉ុន បានជួបជាមួយអ្នកមកថ្មីជាច្រើននាក់ទៀតដែលមានប្រពន្ធជាជនជាតិវៀតណាមដែរដូចជា ព្រុន និងភ្វា ។ ព្រុន បានព្យាយាមរត់ចេញពីវត្តត្នោត ប៉ុន្តែមិនបានសម្រេចហើយត្រូវឈ្លបសម្លាប់ចោល ។

ខ្មែរក្រហមបានបង្ខំឲ្យ ម៉ុន រៀបការម្តងទៀត ។ បងប្អូននិងអ្នកជិតខាងរបស់ ម៉ុន បានប្រាប់គាត់ថា ខ្មែរក្រហមចង់ឲ្យគាត់បំភ្លេចប្រពន្ធវៀតណាមរបស់គាត់ ។ ម៉ុន និយាយថា "ថ្មី ៗ បន្ទាប់ពីខ្មែរក្រហមចាប់ប្រពន្ធកូនខ្ញុំយកទៅ ខ្ញុំមិនដែលដេកលក់ទេ ។ បើពេលណាដេកលក់គឺយល់សប្តិឃើញប្រពន្ធខ្ញុំ កូនខ្ញុំ និងឪពុកម្តាយក្មេកខ្ញុំរស់នៅជាមួយគ្នា ។ ពេលណាឃើញខោអាវរបស់ប្រពន្ធកូនខ្ញុំ ខ្ញុំនឹកដល់ពួកគេភ្លាម" ។

យុន ម៉ុន យល់ថា អ្នកដែលមានជាប់សាច់ឈាមវៀតណាមសុទ្ធតែត្រូវសម្លាប់ចោលទាំងអស់ ។ ម៉ុន លើកឧទាហរណ៍បងថ្លៃរបស់គាត់ម្នាក់ (បងប្រុសរបស់ ហួ ឈ្មោះ សេង វ៉ាន់) ដែលត្រូវសម្លាប់ចោលទាំងក្រុមគ្រួសារនៅសល់តែកូនប្រុសម្នាក់ឈ្មោះ ម៉ៅ ដែលរួចជីវិតដោយសាររត់ទៅលាក់ខ្លួននៅក្នុងចម្ការពោត ។ សូម្បីតែបងប្អូននិងអ្នកជិតខាងក៏និយាយថា ប្រពន្ធនិងកូនរបស់ ម៉ុន ត្រូវខ្មែរក្រហមសម្លាប់ចោលអស់ហើយ ។ ម្តាយក្មេករបស់ ម៉ុន បងថ្លៃស្រី ឈ្មោះ សេង ទៀង និងបងថ្លៃប្រុសឈ្មោះ សេង កែ ក៏ត្រូវសម្លាប់ចោលដែរ ។ អ្នកជិតខាងរបស់ ម៉ុន ម្នាក់ឈ្មោះ ប៉ាក់ សុខុម បាននិយាយថា "ចុងឆ្នាំ ១៩៧៧ ជនជាតិវៀតណាមមិនថាចាស់ ក្មេង បុរស ឬស្ត្រី ត្រូវសម្លាប់ចោលទាំងអស់ ។ បងជីដូនមួយរបស់ខ្ញុំមានប្រពន្ធជាជនជាតិវៀតណាម ហើយប្រពន្ធនិងកូន ៗ របស់គាត់ត្រូវសម្លាប់ចោលទាំងអស់ ។ នៅក្នុងរបបនោះ ជនជាតិវៀតណាមគឺជាមុខសញ្ញាដែលត្រូវកម្ទេច ។ ខ្ញុំដូចជាមិនឃើញមានកំហុសអ្វីផ្សេងទៀតទេ ។ ខ្មែរក្រហមសម្លាប់អ្នកដែលជាសត្រូវរបស់ខ្លួន" ។ នៅក្នុងគំនិតរបស់ សុខុម ការសម្លាប់នេះគឺជាផ្នែកមួយនៃសង្គ្រាមប្រឆាំងនឹងជនជាតិវៀតណាមដែលចាប់ផ្តើមតាំងពីដើមឆ្នាំ១៩៧៧ ។ សុខុម បន្ថែមថា "ផែនការនាំប្រជាជនជីកប្រឡាយ លើកទំនប់ ធ្វើស្រែចម្ការ គឺគ្រាន់តែដើម្បីបិទបាំងរូបភាពពិតនៃសង្គ្រាមប្រឆាំងនឹងជនជាតិវៀតណាមតែប៉ុណ្ណោះ" ។

ផ្នែកមួយនៃការសម្លាប់រង្គាលនេះគឺកម្មាភិបាលរបស់ខ្មែរក្រហមខ្លួនឯងត្រូវចោទប្រកាន់ថាជាជនក្បត់និងជួយគាំទ្រវៀតណាម ហើយកម្មាភិបាលទាំងនោះក៏ត្រូវសម្លាប់នាពេលក្រោយមក ។ ពែក ប៉ាច ដែលរស់នៅភូមិស្វាយអន្ទរនៅក្នុងរបបខ្មែរក្រហម បាននិយាយថា "ភូមិស្វាយអន្ទរនៅក្នុងតំបន់២០ ភូមិភាគបូព៌ា ។ កម្មាភិបាលខ្មែរក្រហមនៅភូមិភាគនិរតីចោទប្រកាន់កម្មាភិបាលខាងភូមិភាគបូព៌ាថាក្បត់ ប៉ុន្តែកម្មាភិបាលខាងភូមិភាគបូព៌ានិយាយផ្ទុយទៅវិញ ។ កម្មាភិបាលខាងនិរតីចូលមកភូមិភាគបូព៌ានៅឆ្នាំ១៩៧៨ ហើយនិយាយថាយើងជួយវៀតណាម តាមពិតគ្មាននរណាជួយវៀតណាមទេ" ។ កម្មាភិបាលភូមិភាគបូព៌ាក៏ត្រូវសម្លាប់ចោល រួមទាំងឈ្មោះ ឡឹក ឆែម គណៈឃុំស្វាយអន្ទរ ដែលបានចេញបញ្ជាឲ្យសម្លាប់ប្រពន្ធនិងកូនរបស់ ម៉ុន ឈ្មោះ ថូ ប្រធានឈ្លបស្រុក និងឈ្មោះ ភា គណៈស្រុក ។ ឈ្មោះ ឈឿន ដែលជាអ្នកមកចាប់ខ្លួនប្រពន្ធកូនរបស់ ម៉ុន ដោយផ្ទាល់ បានស្លាប់ដោយជំងឺនៅឆ្នាំ១៩៧៩ ចំណែក តាលឹម ប្រធានភូមិ នៅរស់រហូតដល់ឆ្នាំ២០០០ ។

ក្នុងនាមជាពុទ្ធសាសនិក យុន ម៉ុន ហាក់ដូចជាបានអភ័យទោសឲ្យ តាលឹម រួចទៅហើយ ។ តាមការបញ្ជាក់ របស់ ម៉ុន គាត់ពិតជាខឹងនឹង តាលឹម ខ្លាំងណាស់ ប៉ុន្តែគាត់មិនហ៊ានសងសឹកទេ ព្រោះខ្លាចមានកម្មពៀរ ។ ម៉ុន និយាយថា "ប្រសិនបើឲ្យខ្ញុំសម្លាប់នរណាម្នាក់ដើម្បីសងសឹក ខ្ញុំពិតជាមិនអាចធ្វើបានទេ" ។ ម៉ុន និយាយថា តាលឹម គ្រាន់តែធ្វើតាមបញ្ជារបស់គណៈឃុំនិងគណៈស្រុកប៉ុណ្ណោះ ។ ដោយរស់នៅជិតខាងគ្នា ម៉ុន និង តាលឹម ជួបមុខគ្នាជាញឹកញាប់ ប៉ុន្តែមិនដែលរំឭកអំពីអតីតកាលទេ ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងចិត្តរបស់ ម៉ុន គាត់ចង់ឲ្យមានតុលាការមួយដែលកាត់ទោសខ្មែរក្រហមដើម្បីស្វែងរកយុត្តិធម៌ឲ្យប្រពន្ធនិងកូនរបស់គាត់ ។

**សឹម សុរិយ៉ា**

# មិនចង់បំភ្លេច ហើយក៏មិនចង់ជួបម្តងទៀត

*អ៊ឹស្រ្តី អាំ ហាន អាយុ៦០ឆ្នាំ នៅភូមិត្រពាំងគូរ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ បានមានប្រសាសន៍ថាៈ "ចាំជាប់ដក់នឹងខ្លួនយើងដូចមេរៀនអ៊ីចឹង ។ អក្សរអើអាចភ្លេច ប៉ុន្តែរឿងខ្មែរក្រហមមិនភ្លេចទេ នៅតែនឹកឃើញវេទនា នៅតែនឹកឃើញលំបាក ។ ខ្ញុំអត់ចង់ភ្លេចទេ តែអត់ចង់ឲ្យឃើញ ធ្វើបុណ្យរាល់ថ្ងៃហ្នឹងលាចាករបបហ្នឹងកុំឲ្យមានអ៊ីចឹងទៀតណា៎" ។*


អាំ ហាន

អ៊ឹស្រ្តី អាំ ហាន គឺជាស្ត្រីមេម៉ាយមានកូន៥នាក់ ។ ប្តីរបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ក្នុងឆ្នាំ១៩៧៦ ។ មិនមែនតែ អ៊ឹហាន ម្នាក់ទេ បងប្អូនទាំងអស់របស់គាត់ រួមទាំងម្តាយរបស់គាត់ផង សុទ្ធតែជាស្ត្រីមេម៉ាយដោយសាររបបខ្មែរក្រហម ។ ប្តីរបស់ អ៊ឹហាន ឪពុក បងប្រុសពីរនាក់ បងថ្លៃប្រុស ប្អូនស្រីពៅជាមួយប្តីនិងកូនតូចត្រូវខ្មែរក្រហមយកទៅសម្លាប់ ។

អ៊ឹហាន មានកំណើតនៅភូមិទាល ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ។ ឪពុករបស់គាត់ឈ្មោះ អាំ វ៉ែន គឺជាអាចារ្យពេលា ម្តាយរបស់គាត់ឈ្មោះ អ៊ុក យុគ ។ អ៊ឹហាន បានផ្លាស់មករស់នៅភូមិធ្នង់រលើង ឃុំលាយបូរ ស្រុកត្រាំកក់ បន្ទាប់ពីគាត់រៀបការរួច ។ ប្តីរបស់គាត់ឈ្មោះ ញ៉ែម ពុធ ជាគ្រូបង្រៀន និងធ្លាប់ធ្វើជាកុម្ម៉ង់ដូក្នុងរបបលន់ណុល ។

នៅចុងឆ្នាំ១៩៧៥ អង្គការបានយកឪពុក បងប្រុស២នាក់ និងបងថ្លៃប្រុសរបស់ អ៊ឹហាន ទៅរៀនសូត្រជាបន្តបន្ទាប់ ។ កាលណោះគណៈឃុំត្រាំកក់ឈ្មោះ សមមិត្តនៅ ដែលធ្លាប់រស់នៅក្នុងភូមិជាមួយគ្នា និងធ្លាប់ជាមិត្តរួមថ្នាក់របស់ អ៊ឹហាន កាលពីកុមារ ។

ប្អូនស្រីពៅរបស់ អ៊ឹហាន ក៏ត្រូវអង្គការយកទៅសម្លាប់ទាំងប្តីទាំងកូនដែលទើបតែមានអាយុជាង១ឆ្នាំ ។ អ៊ឹហាន គិតថា មូលហេតុដែលអង្គការយកឪពុកនិងបងប្រុសរបស់គាត់ទៅសម្លាប់គឺដោយសារតែគ្រួសារគាត់ជាគ្រួសារអ្នកមានទ្រព្យធន ។ គាត់និយាយថា "គ្រួសារខ្ញុំពីដើមអ្នកមានគួរសម គេហៅថាគ្រួសារមូលធនណា៎ យកទៅទាំងពូជ គ្រួសារខ្ញុំយកអស់ប្រុសៗគ្មាននៅទេ ។ ប្អូនខ្ញុំមីពៅហ្នឹងឈ្មោះ អាំ ហ៊ឹន គេឲ្យខ្ចប់បាយឲ្យកងទ័ព មួយផ្ទះវេចមួយសំណុំ ខ្ចប់ហើយដាក់ឈ្មោះទៅ ។ ដល់ពេលហើយមិនដឹងនរណាខូច បែបមានអ្នកស្អប់ហើយ វាដូរសាច់មាន់ចេញទៅវាដាក់អាចម៍ជ្រូកចូលក៏មិនដឹងដែរ ។ ហើយគេថាយើងដាំបាយដាក់អាចម៍ជ្រូកឲ្យគេស៊ី គេថាយើងចង់សម្លាប់គេ ។ ឬមួយគេចាប់កំហុសយើងចង់សម្លាប់យើងតែម្តងណា៎ គេយកទៅទាំងពូជ" ។

បន្ទាប់ពីបងប្អូន៣នាក់និងឪពុករបស់ អ៊ឹហាន ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលអស់ហើយ ម្តាយរបស់ អ៊ឹហាន បានផ្ញើដំណឹងមកប្រាប់ អ៊ឹហាន ដែលរស់នៅភូមិធ្នង់រលើងថា កុំត្រឡប់ទៅឃុំត្រាំកក់វិញ ក្រែងអង្គការយកទៅសម្លាប់ទៀត ។ ដូច្នេះ អ៊ឹហាន ក៏បន្តរស់នៅភូមិខាងប្តីរបស់គាត់ ។ នៅឆ្នាំ១៩៧៦ សមមិត្តនៅ ត្រូវអង្គការផ្លាស់ពីឃុំត្រាំកក់ឲ្យមកធ្វើជាគណៈឃុំលាយបូរវិញ ។ បន្ទាប់ពីបានឃើញអ៊ឹហាន រស់នៅភូមិធ្នង់រលើង សមមិត្តនៅ ក៏បញ្ជាឲ្យឈ្លបចាប់ប្តីរបស់គាត់យកទៅសម្លាប់ ។

ហេតុការណ៍នោះកើតឡើងនៅក្នុងរដូវច្រូតឆ្នាំ១៩៧៦ ។ ប្តីរបស់ អ៊ឹហាន ឈ្មោះ ញ៉ែម ពុធ ត្រូវឈ្លបខ្មែរក្រហមបីនាក់ហៅទៅសែងដីនៅទីស្នាក់ការពាណិជ្ជកម្ម ។ ពុធ ជិះកង់ចេញទៅជាមួយឈ្លបខ្មែរក្រហម ។ អ៊ឹហាន រំឭកថា "កាលហ្នឹងម៉ោង៩ព្រឹក គាត់កំពុងតែវែកកណ្តាប់ពីស្រែមកសហករណ៍ ហើយខ្ញុំកំពុងតែរៀបកណ្តាប់នៅសហករណ៍ និងកំពុងតែស្ងោរដំឡូងផង ។ ឈ្លបបីនាក់កាន់កាំភ្លើងពីរដើមដើរមកអើតៗរកប្តីខ្ញុំ ប៉ុន្តែគេអត់សួរខ្ញុំទេ ។ មានអ្នកប្រាប់ថាប្តីខ្ញុំនៅស្រែឯណោះ ។ ដល់ហើយគេយកទៅ គេប្រាប់ឲ្យយកដងវែកនិងបង្គីទៅផង គេថាយកទៅឲ្យ

សែងដី តែមិនមែនទេ គេយកទៅបាត់រហូត ។ គេឲ្យគាត់ផាក់កង់ ហើយគេដិះពីក្រោយ ប្អូនខ្ញុំតាមមើលផុតកន្ទុយភ្នែក ។ ខ្ញុំយំអើយយំ ប្អូនខ្ញុំថាកុំយំ វាខ្លាចគេយកខ្ញុំទៀតណា៎ តែខ្ញុំទ្រាំមិនបាន ខ្ញុំបេះតែយំទៅ ។ កាលហ្នឹងកូនពៅខ្ញុំនៅតូចទើបតែអាយុ៩ឆ្នាំ» ។

បន្ទាប់ពីយកប្ដីរបស់ អ៊ឹហាន ទៅសម្លាប់ហើយ សមមិត្តនៅបន្តតាមដានគាត់ទៀត ។ អ៊ឹហាន រៀបរាប់បន្តទៀតថា «វាទៅតាមរករឿងតាមដានខ្ញុំនៅឯហ្នឹងទៀត ។ ខ្ញុំនៅវត្តខ្នារគេឲ្យខ្ញុំប្រូតវាដើរតាមខ្ញុំរើសកួរស្រូវ ។ ដល់ហើយខ្ញុំនឹកឃើញខ្លួនខ្ញុំថា អានេះមុខជាតាមដានខ្ញុំហើយ ។ វារើសបានកួរស្រូវមួយ យប់ឡើងវាប្រជុំតែម្ដង ។ វាថា គួរមិត្តយើងដែលប្រូតមើលកុំឲ្យជ្រុះ ជ្រុះមួយកួរហ្នឹងវាប៉ុន្មានគ្រាប់? ហើយមួយគ្រាប់ហ្នឹងវាចេញប៉ុន្មានដើម? វានិយាយអ៊ីចឹងណា៎ ។ ខ្ញុំនឹកឃើញភ័យទៀតថា យី! អាហ្នឹងតាមដានខ្ញុំណាស់ ។ ខ្ញុំអត់មាត់ទេណា៎អូន ដល់ស្អែកឡើងគេឲ្យខ្ញុំបោកស្រូវ ។ ខ្ញុំខាំមាត់ណាស់ ព្រោះអីខ្លាចគេយកខ្ញុំទៀតនឹកឃើញអាណិតកូននៅកំព្រា ។ ក្រោយមកខ្ញុំធ្វើប្រឡាយនេះ ហើយខ្ញុំថ្ងោះខ្លួន គេថាខ្ញុំសតិអារម្មណ៍ កាលហ្នឹងគេរករឿងខ្ញុំខ្លាំងដែរណា៎ ព្រោះគេយកប្ដីទៅហើយដល់យើងអ៊ីចឹងទៀតគេចង់យកយើងទៅមួយទៀត គេថាយើងមាយា ជំងឺវាមើលអត់ឃើញណា៎» ។

អ៊ឹហាន ធ្វើការនៅក្នុងកងស្ត្រីវ័យកណ្ដាល ទៅធ្វើស្រែឆ្ងាយៗពីភូមិ ។ រៀងរាល់ថ្ងៃទី១០ ទី២០ និងថ្ងៃទី៣០ អង្គការអនុញ្ញាតឲ្យមកលេងផ្ទះម្ដង ។ ចំណែកកូនៗត្រូវបញ្ជូនទៅកងកុមារ ។ អ៊ឹហាន រៀបរាប់ថា «ខ្ញុំគេឲ្យទៅកងនៅស្រែប្រាំងខាងកើតតាកែវឯណោះ ដល់យប់ថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ បានគេឲ្យមកផ្ទះ ។ មកមួយយប់អ៊ីចឹងជួបកូនទៅ ព្រលឹមឡើងងងឹតៗគេឲ្យឡើងទៅវិញ ហើយទុកកូននៅនឹងកងគេណា៎ ដល់មកផ្ទះវិញបាត់កូនអស់រលីង ។ កូនស្រីធំគេឲ្យទៅនៅកងឯវត្តខ្នារ ខ្ញុំទៅជួបសង្កើចខាំគ្នាឡើងស្គម ហើយវាអត់អីស៊ីផង ។ និយាយពីចង្កេះសំពត់ឡើងក្រហមប្រាកសង្កើចខាំនោះស្គមអើយស្គម ខ្ញុំអាណិតកូនខ្លោចចិត្ត» ។

នៅក្នុងខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានកៀរប្រជាជនឡើងលើភ្នំសំដៅទៅទិសខាងលិច ។ ពេលនោះ អ៊ឹហាន ក៏នាំកូនៗរត់ទៅតាមខ្មែរក្រហមដែរ ប៉ុន្តែដោយមិនអាចអត់ទ្រាំនឹងការលំបាកបាន ម្យ៉ាងអស់ស្រូវអង្ករបរិភោគផង គាត់ក៏សម្រេចចិត្តធ្វើដំណើរត្រឡប់ក្រោយវិញ ។ «ខ្ញុំរត់ទៅដល់ពោធិវង្ស ហើយដឹកស្រូវពីខ្នារយកទៅហូប ដល់ហើយអាពតគេឲ្យខ្ញុំរត់ទៅភ្នំលិច ខ្ញុំមិនទៅសុខចិត្តមកខាងណោះវិញ ខ្ញុំមកនេះមក តាហ៊ិន គណៈកងគេផ្ដាំថាទៅហ្នឹងកុំភ្លេចធាតុដើមណា៎ បានសារុងកុំភ្លេចសំពត់ខ្មៅ» ។



អ៊ឹហាន និងចៅៗរបស់គាត់

ក្រោយរបបខ្មែរក្រហមដួលរលំ អ៊ឹហាន នាំម្ដាយនិងកូនៗមករស់នៅភូមិត្រពាំងគួរ ហើយយកមាសមួយជីដែលម្ដាយរបស់គាត់លាក់បានទៅទិញម៉ាស៊ីនដេរចាស់មួយគ្រឿងមកដេរសម្លៀកបំពាក់ដើម្បីដូរយកអង្ករមកចិញ្ចឹមជីវិតគ្រួសារដែលមានសមាជិក ៧នាក់ ។

អ្នកភូមិម្នាក់ឈ្មោះ ឃុត ដែលជាអតីតអ្នកទោសនៅគុកក្រាំងតាចាន់ បានប្រាប់

អ៊ឹហាន ថាគាត់បានឃើញឪពុករបស់ អ៊ឹហាន ជាប់នៅគុកក្រាំងតាចាន់ ។

បច្ចុប្បន្ននេះ អ៊ឹហាន មានអាយុ៦០ឆ្នាំ ។ គាត់លែងមានអ្វីដែលត្រូវព្រួយបារម្ភទៀតហើយ ព្រោះកូនទាំង៥នាក់របស់គាត់បានរៀបការមានក្រុមគ្រួសាររៀងៗខ្លួននិងមានជីវភាពសមរម្យ មានដីស្រែជាច្រើនហិកតា មានផ្ទះក្បឿងធំទូលាយគ្រប់ៗគ្នា ។ កូនស្រីទី៣បានធ្វើគ្រូបង្រៀន ចំណែកកូនស្រីទី៤ជាជាងកាត់ដេរប្រចាំភូមិ ។ ចៅៗរបស់គាត់ក៏បានទៅសាលារៀនគ្រប់ៗគ្នា ។ អ៊ឹហាន រស់នៅជាមួយកូនៗដែលសង់ផ្ទះជន្ទែគ្នានៅលើដីភូមិរបស់គាត់ ។ គាត់ជួយមើលចៅដែលនៅតូចៗ ហើយពេលទំនេរគាត់ត្បាញកន្ត្រកឫស្សីសម្រាប់លក់ ។ ក្រៅពីនេះ អ៊ឹហាន បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសហគមន៍ក្នុងនាមជាសមាជិកសមាគមនារីភូមិត្រពាំងគូរ ។

រំឭកដល់របបខ្មែរក្រហម អ៊ឹហាន និយាយថា «កាលពីជំនាន់នោះវាហួសហេតុពេកហើយ ឈឺចិត្តណាស់ វាហួសនឹងនិយាយ ។ ដល់តែអ៊ីចឹងទៅនឹកឃើញថាមិនសមបើរស់មកបានប៉ុណ្ណឹងទេ ។ គេឲ្យទៅកងមួយថ្ងៃៗគ្មាននៅផ្ទះទេ មិនដែលស្គាល់ផ្ទះស្គាល់កូនយ៉ាងម៉េចទេ ។ គេចង់បំបាត់យើងមិនឲ្យស្គាល់កូនយើងទេ យើងដឹងតែធ្វើការទៅ កុំគិតគូររឿងគេ ។ បានថាតាំងពីហ្នឹងមកពេលដែលខ្ញុំនឹកឃើញរឿងអាពតម្តងៗយំណាំអូន អន្តុយស្រក់ទឹកភ្នែកនឹកគ្រាកម្សត់បិញ្ចឹមកូនតែម្នាក់ឯង» ។

បំណងប្រាថ្នាតែមួយគត់របស់ អ៊ឹស្រី អាំ ហាន នៅពេលនេះគឺសូមឲ្យប្រទេសកម្ពុជាមានសន្តិភាពជារៀងរហូត គ្មានការឈ្លោះទាស់ទែងគ្នា និងសូមកុំឲ្យរបបខ្មែរក្រហមវិលមកវិញសាជាថ្មីម្តងទៀត ព្រោះគាត់មិនចង់ឲ្យចៅៗរបស់គាត់ជួបប្រទះនឹងសោកនាដកម្មដូចដែលគាត់បានជួបទេ ។ **សាន់ កល្យាណ**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី «វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនរបស់លោកអ្នកចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

◆ រួមចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងពត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# តាំង គីម:
# ការឆ្លើយតបទៅនឹងការរំលោភផ្លូវភេទនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

*"ខ្ញុំឆ្ងល់ថាតើភាគីទាំងសងខាងអាចផ្សះផ្សាគ្នារបៀបម៉េច បើម្ខាងជាជនរងគ្រោះហើយម្ខាងទៀតជាជនដៃដល់ ហើយជនដៃដល់មិនបានទទួលស្គាល់កំហុសខ្លួនឯងទៀត? ប្រសិនបើអ្នកទាំងនោះទទួលស្គាល់កំហុសរបស់ខ្លួននោះខ្ញុំជាអ្នកសម្រេចថាត្រូវអភ័យទោសឲ្យដែរឬអត់ ។ កាលនោះខ្ញុំស្ទើរស្លាប់ស្ទើររស់ រួចឥឡូវមកនិយាយត្រឹមតែពាក្យ"សូមទោស" ម៉េចនឹងកើត?"* នេះជាសម្តីរបស់ តាំង គីម អ្នកដែលរួចជីវិតពីការរំលោភផ្លូវភេទដោយកងទ័ពខ្មែរក្រហម ។


តាំង គីម ឆ្នាំ១៩៧៣

តាំង គីម បានឈានដល់វ័យ២៣ឆ្នាំ នៅឆ្នាំ១៩៧៦ ពោលគឺមួយឆ្នាំបន្ទាប់ពីកងកម្លាំងរបស់ខ្មែរក្រហមទទួលបានជ័យជម្នះលើរដ្ឋាភិបាលលន់នល់ និងបានសាបព្រោះអំពើឃោរឃៅនៅតាមទីជនបទនៃប្រទេសកម្ពុជា ។ យប់មួយកងទ័ពខ្មែរក្រហមមួយក្រុមបានមកចាប់ខ្លួន តាំង គីម និងបានរំលោភលើរូបកាយរបស់គាត់យ៉ាងព្រៃផ្សៃបំផុតនៅក្នុងវាលស្រែក្បែរភូមិ ។ បន្ទាប់ពីលាក់ខ្លួនអស់រយៈពេលបីថ្ងៃនៅក្នុងបឹងភក់ដែលមានសុទ្ធតែឈើង និងបានមើលឃើញផ្ទាល់ភ្នែកនូវការសម្លាប់មនុស្ស៣៣គ្រួសារដោយកងទ័ពខ្មែរក្រហម តាំង គីម បានក្លាយជាមនុស្សតែម្នាក់គត់ដែលរួចជីវិតក្នុងចំណោមនារី៨នាក់ដែលត្រូវកងទ័ពខ្មែរក្រហមចាប់យកទៅរំលោភនិងសម្លាប់ក្នុងយប់នោះ ។

នៅក្នុងភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលទើបតែផលិតនាពេលថ្មីៗនេះ តាំង គីម បានទម្លាយជាលើកទី១នូវការឈឺចាប់របស់គាត់ដែលគាត់បានព្យាយាមបិទបាំងអស់រយៈពេលម្ភៃប្រាំបីឆ្នាំមកហើយ ។ សារសំខាន់របស់ភាពយន្តឯកសារនេះមិនអាចត្រូវបានមើលរំលងនោះទេ ដោយសារ តាំង គីម ជាស្ត្រីខ្មែរដំបូងបំផុតដែលហ៊ាននិយាយជាសាធារណៈពីអំពើរំលោភផ្លូវភេទដែលកើតមាននៅក្នុងរយៈពេលប្រាំឆ្នាំនៃរបបកម្ពុជាប្រជាធិបតេយ្យដែលគ្រប់គ្រងដោយបក្សកុម្មុយនិស្តកម្ពុជា ។

សាមសិបឆ្នាំបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅទីបំផុតរាជរដ្ឋាភិបាលកម្ពុជាបានយល់ព្រមកាត់ទោសសមាជិកខ្លះនៃថ្នាក់ដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាចំពោះបទល្មើសច្បាប់ក្នុងស្រុកនិងអន្តរជាតិដែលប្រព្រឹត្តនៅក្នុងរបបនោះ ។ កាលពីខែតុលា ឆ្នាំ២០០៤ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ដែលបានពិភាក្សាអស់រយៈពេលជាយូរមកហើយដើម្បីបង្កើតសាលាជំនុំជម្រះក្តីពិសេសមួយនៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ។ សាលាជំនុំជម្រះក្តីពិសេសនេះមានឈ្មោះថា "អង្គជំនុំជម្រះវិសាមញ្ញ" បង្កើតឡើងដើម្បីជំនុំជម្រះទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាមួយនឹងការរំពឹងទុកជាមុនថាអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើមដំណើរការនៅក្នុងពេលណាមួយនៃឆ្នាំ២០០៥នេះ ជាទូទៅមានការសង្ឃឹមថាអង្គជំនុំជម្រះវិសាមញ្ញនេះនឹងផ្តល់ឱកាសក្នុងការផ្សះផ្សាជាតិតាមរយៈការបង្កើតជាឯកសារប្រវត្តិសាស្ត្រដែលចងក្រងអំពីរបៀបដែលកម្ពុជាប្រជាធិបតេយ្យឡើងកាន់អំណាច និងមូលហេតុដែលរបបនេះបានបន្តជាភាពចលាចលនៅក្នុងសង្គមទាំងមូលនៅពេលនោះ ។

នៅខណៈដែលអង្គជំនុំជម្រះវិសាមញ្ញអាចផ្តន្ទាទោសជនដៃដល់សំខាន់ៗដែលបានប្រព្រឹត្តបទល្មើសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជាភាគច្រើនទទួលស្គាល់ថាយន្តការដទៃៗទៀតក៏មានភាពចាំបាច់ដែរដើម្បីសម្រេចឲ្យបាននូវការផ្សះផ្សាជាតិនៅកម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញនឹងជំនុំជម្រះ

តែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ មិនមែនកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមដែលជាអ្នកប្រព្រឹត្ត អំពើហិង្សាដោយផ្ទាល់ដៃនោះទេ ។ ការទទួលខុសត្រូវរបស់ មេដឹកនាំកំពូលរបស់របបកម្ពុជាប្រជាធិបតេយ្យទំនងជាមិនអាច កែប្រែជីវភាពរស់នៅរបស់ជនរងគ្រោះដោយអំពើរំលោភផ្លូវ ភេទនៅក្រោមរបបនោះទេ ហើយជនរងគ្រោះទាំងនោះត្រូវ រស់នៅប្រឈមមុខនឹងភាពជាអ្នកជិតខាងជាមួយអ្នកដែល រំលោភខ្លួន និងកេរដំណែលនៃឧក្រិដ្ឋកម្មដ៏គួរឲ្យរន្ធត់ ។ ហេតុដូច្នេះ ហើយ យន្តការបន្ថែមក្រៅពីអង្គជំនុំជម្រះវិសាមញ្ញនឹងមាន តួនាទីសំខាន់ដើម្បីដោះស្រាយអំពើឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយ កម្មាភិបាលថ្នាក់ក្រោម ។ គ្មានអ្វីគួរឲ្យសង្ស័យទេដែលថា ការប្រឈមមុខចំពោះបទល្មើសផ្លូវភេទដែលមិនមាននរណាហ៊ាន បង្ហើបនៅកម្ពុជា ទាមទារការប្តេជ្ញាចិត្តយ៉ាងខ្លាំង ទាំងពេលវេលា និងធនធានៈ ទីមួយ ត្រូវបង្កើតនូវឯកសារប្រវត្តិសាស្ត្រដ៏ត្រឹម ត្រូវមួយ ទីពីរ ត្រូវកាត់ទោសជនដៃដល់ និងចុងក្រោយបំផុត ត្រូវពង្រឹងការផ្សះផ្សាជាតិរយៈពេលយូរអង្វែង ។ ការសម្ងំ ស្ងៀមមិនមែនជាចម្លើយដ៏ត្រឹមត្រូវដែលអាចទទួលយកបាន ទៀតទេ ។ នៅទូទាំងប្រទេសកម្ពុជា ស្ត្រីផ្សេងទៀតដែលរងគ្រោះ ដូចជា តាំង គីម ដែរ កំពុងតែរង់ចាំពេលវេលាដើម្បីចែករំលែក បទពិសោធន៍ទុក្ខវេទនារបស់ខ្លួន ។

### ១) ឧក្រិដ្ឋកម្មរំលោភផ្លូវភេទនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ ១៩៧៩ សហគមន៍អន្តរជាតិបានចូលមកប្រទេសនេះជាលើក ទីមួយក្នុងរវាង៥ឆ្នាំ ហើយបានរកឃើញភស្តុតាងជាក់ស្តែងនៃ អំពើមនុស្សឃាតនិងទារុណកម្មនៅក្នុងបរិមាណដែលមិនអាច យល់បានមួយបន្ទាប់ពីការសម្លាប់រង្គាលដោយក្រុមណាហ្ស៊ីទៅ លើជនជាតិជ្វីហ្វ ។ យ៉ាងហោចណាស់មានមនុស្ស១លាន៥សែន នាក់ (ប្រមាណ២០ភាគរយនៃចំនួនប្រជាជនសរុប) បានបាត់បង់ ជីវិតនៅក្នុងរយៈពេល៤ឆ្នាំនៃការកាន់អំណាចរបស់កម្ពុជាប្រជា ធិបតេយ្យ ។ នៅក្នុងចំណោមនេះ ប្រជាជនចំនួនពី៥០ម៉ឺន ទៅ១លាននាក់ត្រូវបានប្រហារជីវិត ហើយចំនួនដទៃទៀតស្លាប់ ដោយខ្វះអាហារនិងជំងឺ ។ ភស្តុតាងជាក់ស្តែងដ៏ច្រើនសន្ធឹក សន្ធាប់នៅក្នុងរណ្តៅសាកសពរួមដូចជានៅជើងឯក និងសម្ភារ ធ្វើទារុណកម្មដែលបន្សល់ទុកនៅមន្ទីរស-២១ដែលជាអតីត សាលាបឋមសិក្សាមួយនោះ បានផ្តល់នូវភស្តុតាងដែលអាច ជឿជាក់បានថា របបកម្ពុជាប្រជាធិបតេយ្យបានសម្លាប់និងធ្វើ ទារុណកម្មមនុស្សដោយមិនរើសមុខ ។

ទំហំនៃការបំផ្លិចបំផ្លាញបានធ្វើឲ្យមានការលំបាកដល់ការ វែកញែកភាពខុសប្លែកគ្នានៅក្នុងចំណោមជនរងគ្រោះ ។ នៅខណៈ ដែលជនរងគ្រោះភាគច្រើនជាជនជាតិខ្មែរ ជនរងគ្រោះផ្សេង ទៀតក៏មានជនជាតិវៀតណាមនិងជនជាតិចាម ហើយសូម្បី តែព្រះសង្ឃនិងដូនជីក៏មិនត្រូវបានលើកលែងដែរ ។ កម្ពុជា ប្រជាធិបតេយ្យបានព្យាយាមបោសសម្អាត“សមាសភាពខ្មាំង” ពីគ្រប់ផ្នែកនៃសង្គម ។ ហេតុដូច្នេះហើយ របបនោះ បានសម្លាប់ទាំងបុរសនិង ស្ត្រី ទាំងក្មេងនិងចាស់ ។ មិនមានមែកធាងណាមួយ នៃសង្គមកម្ពុជាអាចរួច ផុតពីការធ្វើទុក្ខបុកម្នេញ នេះទេ ។


មាស ឆុន ប្តីរបស់ តាំង គីម ឆ្នាំ១៩៨១

ដោយគ្រាន់តែផ្អែក លើភស្តុតាងកោសល្យវិច័យតែម្យ៉ាងមិនទាន់គ្រប់គ្រាន់នៅឡើយ ទេក្នុងការកំណត់ថាស្ត្រីទទួលរងនូវការឈឺចាប់ខុសប្លែកពីបុរស ។ គ្រោងឆ្អឹងក្បាលមិនបានបង្ហាញភស្តុតាងនៃអំពើរំលោភឬបំពារ បំពានផ្លូវភេទទេ ហើយអ្នកដែលស្លាប់ទៅបាននាំយករឿងរ៉ាវ របស់ខ្លួនទៅជាមួយ ។ នៅក្នុងពេលប្រមូលចងក្រងឯកសារនៃ ឧក្រិដ្ឋកម្មរបស់របបកម្ពុជាប្រជាធិបតេយ្យ ស្ត្រីដែលនៅរស់ នៅតែរក្សាភាពស្ងប់ស្ងាត់ចំពោះប្រធានបទនៃអំពើរំលោភផ្លូវ ភេទ ។ ហេតុដូច្នេះហើយ ទស្សនៈជាទូទៅបានសន្មតថា អំពើ រំលោភផ្លូវភេទមិនត្រូវបានប្រើប្រាស់ជាអាវុធនៃសង្គ្រាមដូច ដែលធ្លាប់បានប្រើប្រាស់នៅក្នុងរបបប្រល័យពូជសាសន៍ដទៃទៀត ដូចនៅក្នុងអតីតប្រទេសយូហ្គោស្លាវីនិងរ៉ាវ៉ាន់ដាទេ ។

ផ្ទុយនឹងរបបផ្សេងៗទៀត របបកម្ពុជាប្រជាធិបតេយ្យ បានប្រកាន់គោលនយោបាយតឹងរ៉ឹងហាមប្រាមមិនឲ្យមានអំពើរំលោភផ្លូវភេទ ហើយថែមទាំងបានដាក់ឲ្យនៅក្រៅច្បាប់នូវរាល់ទំនាក់ទំនងផ្លូវភេទទាំងអស់ក្រៅពីការរៀបការ ។ របបនេះបានមើលទំនាក់ទំនងផ្លូវភេទថាជាអាកប្បកិរិយាវិទ្ធង្សនាដែលអាចធ្វើឲ្យមនុស្សមានស្មារតីមិនមូលលើការងារ ពោលគឺបដិវត្តន៍ស្រេចម្ការ ។ ទោះបីជារបបនោះចង់បង្ហាញថាអង្គការមានភាពបរិសុទ្ធខាងផ្នែកសីលធម៌ ក៏គោលនយោបាយមិនមានប្រភពច្រើននៅក្នុងសីលធម៌ដូចនៅក្នុងទស្សនវិជ្ជារបស់ ម៉ៅ សេទុង ដែលឲ្យតម្លៃទៅលើប្រសិទ្ធភាពជាងអ្វីៗទាំងអស់ដែរ ។ សុជីវធម៌បានផ្តល់ជាការដោះសារដ៏សមរម្យមួយសម្រាប់គ្រប់គ្រងទិដ្ឋភាពផ្សេងៗនៃជីវភាពរស់នៅ ។

ការហាមឃាត់យ៉ាងតឹងរ៉ឹងចំពោះទំនាក់ទំនងផ្លូវភេទពិតជាបានការពារស្ត្រីខ្លះពីអំពើហិង្សាផ្លូវភេទ ដោយសារតែបុរសបារម្ភអំពីគ្រោះថ្នាក់ចំពោះការប្រថុយប្រថានរបស់ខ្លួន ។ ក៏ប៉ុន្តែបន្ទាប់ពីបានធ្វើសម្ភាសជាមួយស្ត្រីជាច្រើនដែលនៅរស់ពីរបបនោះមក ម៉ម កល្យានី បានសន្និដ្ឋានក្នុងនាមជាអ្នកស្រាវជ្រាវម្នាក់ថា គោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាឲ្យលទ្ធផលផ្ទុយមកវិញ ពោលគឺបានជំរុញឲ្យមានឧក្រិដ្ឋកម្មរំលោភផ្លូវភេទលើស្ត្រីជាច្រើន ។ ដូចដែលអ្នកខ្លះបានកត់សម្គាល់ គោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាបានបង្កឲ្យមានការអនុវត្តដោយលួចលាក់ជាច្រើន ។ កងទ័ពខ្មែរក្រហមបានសម្លាប់ស្ត្រីនោះភ្លាមៗបន្ទាប់ពីរំលោភរួចដើម្បីបំបិទភ័ស្តុតាង ។ នៅក្នុងភាពយន្តឯកសារអំពីខ្សែជីវិតរបស់គាត់ តាំង គីម បានរៀបរាប់អំពីការអនុវត្តរបៀបនោះថា ÷

ពួកគេ (ទាហានខ្មែរក្រហម) រំលោភអ្នកដែលត្រូវយកទៅសម្លាប់ទាំងអស់ ។ គេមិនហ៊ានរំលោភអ្នកដែលមិនត្រូវស្លាប់ទេ ។ ក្មួយឯង (អ្នកផលិតភាពយន្ត) និយាយថា ចង់ស្វែងរកអ្នកដែលខុសសីលធម៌ជាមួយទាហានខ្មែរក្រហម ប៉ុន្តែក្មួយឯងប្រាកដជាមិនអាចរកឃើញករណីនេះទេ ។ ទាហានខ្មែរក្រហមមិនដែលធ្វើអ៊ីចឹងទេ ។ បើរកឃើញវិញ ទាំងអ្នករំលោភនិងជនរងគ្រោះប្រាកដជាត្រូវស្លាប់ទាំងពីរនាក់ ។ អ៊ីចឹងហើយ គេរំលោភតែអ្នកដែលត្រូវសម្លាប់ប៉ុណ្ណោះ ។

ជាងនេះទៅទៀត ច្បាប់បានដាក់ទណ្ឌកម្មទាំងជនដៃដល់និងជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទដែលបានប្រព្រឹត្តកំហុសប្រឆាំងនឹងអង្គការ ។ ស្ត្រីក៏មិនហ៊ានរាយការណ៍អំពីការបំពារបំពានផ្លូវភេទដែរ ដោយសារស្ត្រីរងគ្រោះត្រូវគំរាមកំហែងថានឹងស្លាប់ប្រសិនបើហ៊ានរាយការណ៍ប្រាប់អង្គការ ។ ដូច តាំង គីម ដែរ បន្ទាប់ពីរួចរស់ជីវិតពីអំពើរំលោភនិងបានចូលទៅរស់នៅក្នុងសហករណ៍វិញ គាត់មិនបង្ហាញខ្លួនឲ្យនរណាម្នាក់ដឹងនិងខិតខំព្យាយាមមិនឲ្យអង្គការចាប់អារម្មណ៍ ។


តាំង គីម ឆ្នាំ១៩៨៥

ជនដៃដល់ដែលប្រព្រឹត្តអំពើរំលោភមិនត្រឹមតែត្រូវបានការពារដោយច្បាប់ដែលរារាំងការរាយការណ៍ទេ ថែមទាំងដោយទម្រង់វិមជ្ឈការនៃការចេញបញ្ជារបស់បក្សកុម្មុយនិស្តកម្ពុជាថែមទៀត ។ ទម្រង់គ្រប់គ្រងនេះមើលទៅមានទំនងថា មេបញ្ជាការជាន់ខ្ពស់មិនអាចដឹងអំពីក្រិដ្ឋកម្មនេះទេ ។ ស្ត្រីម្នាក់បានរាយការណ៍ថា នៅក្នុងគុកមួយនោះ អ្នកទោសនារីៗត្រូវរំលោករហូតដល់មានផ្ទៃពោះរួចត្រូវសម្លាប់ចោលដើម្បីបំបាត់ភ័ស្តុតាង ។ ឧក្រិដ្ឋកម្មរបស់ឆ្មាំគុកមិនដែលត្រូវបានរកឃើញទាល់តែសោះ ដោយសារតែគុកមានទីតាំងនៅកន្លែងដាច់តែឯង ហើយឆ្មាំទាំងនោះជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះអ្នកទោសចេញនិងចូលក្នុងពន្ធនាគារ ។ គោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាមិនត្រឹមតែមិនបានរារាំងអំពើរំលោភផ្លូវភេទប៉ុណ្ណោះទេ ថែមទាំងបានបង្កើតជា «វប្បធម៌និរទណ្ឌភាព» នៅជុំវិញឧក្រិដ្ឋកម្មរំលោភផ្លូវភេទ ។ ប្រសិនបើជនដៃដល់អាចបំបាត់ភ័ស្តុតាងទាំងអស់ដោយការសម្លាប់ជនរងគ្រោះ ជនដៃដល់ទាំងនោះក៏អាចបំភាន់ភ្នែករបស់អង្គការបានចំពោះទោសកំហុសរបស់ខ្លួនដែរ ។

ជារួម មនុស្សជាច្រើន រួមទាំងស្ត្រីដែលរួចជីវិតពីរបប

កម្ពុជាប្រជាធិបតេយ្យផង ជឿជាក់ថា អំពើរំលោភផ្លូវភេទមិនបានកើតឡើងទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារតែខ្វះខាតភ័ស្តុតាងជាក់ស្តែង ហើយនេះជាឥទ្ធិពលដែលមិននឹកស្មានដល់នៃវិធានការដ៏តឹងរ៉ឹងហាមប្រាមទំនាក់ទំនងផ្លូវភេទរបស់កម្ពុជាប្រជាធិបតេយ្យ និងការបង្ខំចិត្តមិននិយាយដោយជនរងគ្រោះជាស្ត្រី ។ វាប្រហែលជាត្រឹមត្រូវក្នុងការនិយាយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមានអំពើរំលោភផ្លូវភេទរបៀបជាខ្សែសង្វាក់ដូចដែលបានកើតឡើងនៅក្នុងរបបប្រល័យពូជសាសន៍នៅរ៉្វាន់ដានិងយូហ្គោស្លាវីទេ ។ ក៏ប៉ុន្តែ អំពើរំលោភ



តាំង គីម និងកូនៗ ឆ្នាំ១៩៨៤

និងការបំពារបំពានផ្លូវភេទប្រាកដជាមានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបញ្ហាលំបាកសម្រាប់ប្រជាជនកម្ពុជាឥឡូវនេះគឺថា តើត្រូវដោះស្រាយជាមួយបទល្មើសដែលកប់បាត់នេះយ៉ាងដូចម្តេច? ភាគច្រើននៃភ័ស្តុតាងជាក់ស្តែងបានបាត់បង់ជាមួយនឹងការបាត់បង់ជីវិតរបស់ជនរងគ្រោះ ។ វប្បធម៌នៃការប្រមាថអ្នកដែលនៅរស់រានមានជីវិតពីអំពើរំលោភផ្លូវភេទនៅតែកើតមាននៅក្នុងប្រទេសកម្ពុជា ហើយវប្បធម៌នេះបានធ្វើឲ្យជនរងគ្រោះមិនហ៊ានចេញមុខបង្ហើបរឿងរ៉ាវដែលខ្លួនបានជួបប្រទះ ។ ស្ត្រីនៅតាមទីជនបទនៃប្រទេសកម្ពុជាមានការភ័យខ្លាចជាខ្លាំងដោយសារតែអ្នកទាំងនេះរស់នៅយ៉ាងជិតស្និទ្ធជាមួយជនដៃដល់ ហើយស្ត្រីទាំងនេះមិនហ៊ានប្រថុយប្រថានបង្ហើបឈ្មោះជនដៃដល់ដែលបានបំពានលើខ្លួនឡើយ ។ វាមានសារសំខាន់ក្នុងការបង្កើតយន្តការមួយដើម្បីដោះស្រាយឧក្រិដ្ឋកម្មទាំងនេះ ហើយយន្តការនេះអាចអនុញ្ញាតឲ្យប្រជាជនកម្ពុជាបានប្រឈមមុខចំពោះអតីតកាលដែលកប់បាត់នេះ អាចបញ្ចប់ការយល់ឃើញមិនត្រឹមត្រូវដែលថាអំពើរំលោភផ្លូវភេទមិនបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងឆ្ពោះទៅរកការផ្សះផ្សាជាតិនៅតាមសហគមន៍ ។

## ២) យុត្តិធម៌ៈ អង្គជំនុំជម្រះវិសាមញ្ញ

មានការរំពឹងទុកជាច្រើនថា អង្គជំនុំជម្រះវិសាមញ្ញអាចនឹងចាប់ផ្តើមដំណើរការរបស់ខ្លួននៅក្នុងការផ្សះផ្សាជាតិនៅកម្ពុជា ។ អ្នកសង្កេតការណ៍នៅក្នុងនិងក្រៅប្រទេសនៅតែមានមន្ទិលសង្ស័យថាតើអង្គជំនុំជម្រះវិសាមញ្ញដែលបង្កើតនៅក្នុងប្រព័ន្ធតុលាការកម្ពុជាអាចដំណើរការដោយយុត្តិធម៌ដែរឬទេ? ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញជាយន្តការដែលចង់បានបំផុតរហូតមកដល់សព្វថ្ងៃនេះ ហើយឱកាសនិងពេលវេលានៅមានគ្រប់គ្រាន់ដើម្បីកែលម្អកង្វះខាតរបស់អង្គជំនុំជម្រះនេះ ។ ដោយការយល់ដឹងអំពីឧបសគ្គក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មរំលោភផ្លូវភេទនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ប្រជាជនកម្ពុជានិងអ្នកសង្កេតការណ៍អន្តរជាតិអាចស្នើជាមធ្យោបាយផ្សេងៗដើម្បីធានាថាឧក្រិដ្ឋកម្មប្រឆាំងនឹងស្ត្រីត្រូវបានដោះស្រាយយ៉ាងសមរម្យ ។

### ក) យុត្តាធិការដែលមានកំណត់លើបុគ្គល

ទិដ្ឋភាពមួយនៅក្នុងចំណោមទិដ្ឋភាពដ៏ចម្រូងចម្រាស់បំផុតនៃអង្គជំនុំជម្រះវិសាមញ្ញគឺវិសាលភាពនៃការចោទប្រកាន់របស់អង្គជំនុំជម្រះនេះ ។ ក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិបានផ្តល់ជាអនុសាសន៍ថា អង្គជំនុំជម្រះវិសាមញ្ញគួរតែអាចចោទប្រកាន់"អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត"ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកទាំងនេះរួមទាំង "មេដឹកនាំជាន់ខ្ពស់" ក៏ដូចជា"កម្មាភិបាល

ថ្នាក់ក្រោមដែលបានចូលរួមដោយផ្ទាល់នៅក្នុងអំពើឃោរឃៅធ្ងន់ធ្ងរបំផុតនៅក្នុងរបបនោះ» ។

ពាក្យសម្តីដែលប្រើចុងក្រោយបំផុតនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានបង្រួមវិសាលភាពយុត្តាធិការបុគ្គលមកនៅត្រឹម«មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋកម្ម» ។

ពាក្យសម្តីដែលមានសរសេរនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានប្រានចោលនូវលទ្ធភាពក្នុងការនាំទៅកាន់អង្គជំនុំជម្រះវិសាមញ្ញនូវមេបញ្ជាការថ្នាក់ក្រោមមួយចំនួនធំដែលអាចមានចំណែកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះមិនមានឆន្ទៈក្នុងការបញ្ចូលអ្នកដឹកនាំនយោបាយបច្ចុប្បន្នទៅក្នុងយុត្តាធិការរបស់ខ្លួនទេ ហើយដែលគួរឲ្យកត់សម្គាល់នោះគឺសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកាន់តំណែងតូចតាចនៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញបានសន្មតជាមុនអំពីមូលហេតុដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តៈ ថ្នាក់ដឹកនាំកំពូលរបស់បក្សកុម្មុយនិស្តកម្ពុជាបានរួមគំនិតគ្នាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងទ្រង់ទ្រាយធំ និងបានបង្កើតក្បាលម៉ាស៊ីនដឹកនាំក្នុងការប្រព្រឹត្តបទល្មើសទាំងនេះ ។ ប្រវត្តិវិទូ ស៊ីវ ហេដ័រ បានអះអាងថា កង្វះខាតនៃអង្គជំនុំជម្រះវិសាមញ្ញអំពីយុត្តាធិការលើ«ត្រីតូចៗ» បានបោះបង់ចោលនូវលទ្ធភាពក្នុងការបង្ហាញអំពីមូលហេតុនៃឧក្រិដ្ឋកម្មដែលបានកើតឡើង ហើយដែលឧក្រិដ្ឋកម្មទាំងនោះជាលទ្ធផលនៃការប្រើប្រាស់អំណាចមិនត្រឹមត្រូវដែលកូនចៅនៅក្រោមបង្គាប់ប្រព្រឹត្តដោយឆន្ទៈរបស់ខ្លួនឯងដោយមេកោយរបស់ខ្លួនមិនបានដឹងពីការប្រព្រឹត្តនោះ ។

ប្រជាជនកម្ពុជាបានសម្តែងថា ខ្លួនចង់បានសាលាជំនុំជម្រះក្តីមួយដើម្បីយល់ដឹងអំពីមូលហេតុនៃកំហុសដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីការពារកុំឲ្យរបបនេះកើតឡើងម្តងទៀត ។ ហុកសិបប្រាំភាគរយនៃប្រជាជនកម្ពុជាគិតថាកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមជាជនដៃដល់ ប៉ុន្តែសាធារណជនមានមតិមិនស៊ីសង្វាក់គ្នាទេជុំវិញវិធីនៃការដាក់ឲ្យកម្មាភិបាលថ្នាក់ក្រោមទាំងនោះទទួលខុសត្រូវ ។ សែសិបមួយភាគរយគិតថាកម្មាភិបាលថ្នាក់ក្រោមជាជនរងគ្រោះផងនិងជាជនដៃដល់ផង ប៉ុន្តែភាគច្រើននៃអ្នកទាំងនោះមិនបានអាណិតកម្មាភិបាលថ្នាក់ក្រោមទេ ។ ហុកសិបប្រាំពីរភាគរយ បានបញ្ជាក់ថាខ្លួនមិនអាចអភ័យទោសឲ្យកម្មាភិបាលថ្នាក់ក្រោមដែលជាអ្នកប្រព្រឹត្តអំពើហិង្សាដោយផ្ទាល់ដៃទេ ។ ឯកសារប្រវត្តិសាស្ត្របានបង្ហាញថា ជាញឹកញាប់កម្មាភិបាលថ្នាក់ក្រោមត្រូវមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាធ្វើទុក្ខបុកម្នេញ ប៉ុន្តែបទពិសោធន៍ដែលកម្មាភិបាលទាំងនេះបានទទួលគឺខុសៗពីគ្នាពេករហូតដល់មិនអាចសន្និដ្ឋានជារួមថាអ្នកទាំងនេះនៅក្នុងប្រភេទនៃ «ជនរងគ្រោះ» ឬក៏ «ជនដៃដល់» ។


តាំង គីម ឆ្នាំ២០០៤

តាមរយៈការបង្វែរចំណាប់អារម្មណ៍ពីបទពិសោធន៍របស់កម្មាភិបាលថ្នាក់ក្រោមទាំងនេះទៅកាន់បទពិសោធន៍របស់មេដឹកនាំជាន់ខ្ពស់វិញ អាណត្តិដែលមានរយៈពេលកំណត់របស់អង្គជំនុំជម្រះវិសាមញ្ញទំនងជាមិនអាចធ្វើឲ្យយើងដឹងអំពីរបៀបអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាទេ ។ អាណត្តិដែលមានរយៈពេលកំណត់នេះមានបញ្ហាពាក់ព័ន្ធជាច្រើនដល់ការចោទប្រកាន់អំពីបទល្មើសរំលោភផ្លូវភេទ ។ ព្រះរាជអាជ្ញានឹងប្រឈមមុខនឹងការលំបាកជាខ្លាំងនៅក្នុងការបង្ហាញអំពី«ការទទួលខុសត្រូវចំពោះបញ្ជា»របស់មេដឹកនាំជាន់ខ្ពស់ចំពោះទង្វើរំលោភផ្លូវភេទរបស់កម្មាភិបាលថ្នាក់ក្រោម ។


ព្រះតេជគុណ មាស ចាន់ណា កូនរបស់ តាំង គីម ឆ្នាំ២០០៤

ព្រះរាជអាជ្ញាអាចព្យាយាមចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ម្នាក់ពីបទល្មើសរំលោភនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ បើយោងទៅតាមគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា វាមិនទំនងទេថាមេដឹកនាំជាន់ខ្ពស់ជាអ្នកប្រព្រឹត្តអំពើរំលោភផ្លូវភេទដោយផ្ទាល់ ដូច្នេះព្រះរាជអាជ្ញាត្រូវតែបង្ហាញថាចុងចោទទទួលខុសត្រូវតាមទ្រឹស្តី “ការទទួលខុសត្រូវចំពោះបញ្ជា” ចំពោះការចេញបញ្ជាឲ្យកម្មាភិបាលនៅក្រោមបង្គាប់ប្រព្រឹត្តអំពើរំលោភផ្លូវភេទ និងបង្ហាញថាមេដឹកនាំជាន់ខ្ពស់បានដាក់ចេញនូវផែនការ “ជាខ្សែសង្វាក់ឬរីករាលដាល” ដើម្បីប្រើប្រាស់អំពើរំលោភផ្លូវភេទជាអាវុធនៃសង្គ្រាម ។

ទ្រឹស្តីនៃ “ការទទួលខុសត្រូវចំពោះបញ្ជា” អាចបណ្តាលឲ្យមេដឹកនាំជាន់ខ្ពស់ម្នាក់ទទួលខុសត្រូវចំពោះសកម្មភាពរបស់អ្នកនៅក្រោមបង្គាប់បញ្ជារបស់ខ្លួន ប្រសិនបើមេដឹកនាំនោះបានដឹងឬគួរតែដឹងថាអ្នកនៅក្រោមបង្គាប់បញ្ជាប្រព្រឹត្តអំពើមិនត្រឹមត្រូវ ហើយមេដឹកនាំនោះមិនបានចាត់វិធានការជាបន្ទាន់និងសមរម្យដើម្បីទប់ស្កាត់ទង្វើនោះ ឬខកខានមិនបានដាក់ទណ្ឌកម្មទៅលើអ្នកប្រព្រឹត្តនោះ ។ គោលនយោបាយដែលត្រូវបានស្គាល់ជាទូទៅរបស់បក្សកុម្មុយនិស្តកម្ពុជាក្នុងការហាមប្រាមបទល្មើសផ្លូវភេទ ជាភស្តុតាងដ៏រឹងមាំមួយសម្រាប់គាំទ្រការអះអាងរបស់មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យដែលថាខ្លួនមិនបានបញ្ជាឲ្យមានការប្រព្រឹត្តបទល្មើសផ្លូវភេទទាំងនោះទេ ។ ក៏ប៉ុន្តែ បើទោះបីជាចុងចោទម្នាក់មិនបានបញ្ជាឲ្យមានការប្រព្រឹត្តអំពើរំលោភផ្លូវភេទក៏ដោយ ព្រះរាជអាជ្ញានៅតែអាចបង្ហាញអំពីការទទួលខុសត្រូវរបស់ចុងចោទនោះប្រសិនបើមានភស្តុតាងបង្ហាញថាចុងចោទមានការធ្វេសប្រហែសក្នុងការការពារមិនឲ្យមានបទល្មើសរំលោភផ្លូវភេទ ។ ភស្តុតាងបានបង្ហាញថានៅតំបន់ដែលមានបទល្មើសរំលោភផ្លូវភេទភាគច្រើននៃមេដឹកនាំជាន់ខ្ពស់មិនបានដឹងអំពីការប្រព្រឹត្តរបស់កម្មាភិបាលនៅក្រោមបញ្ជារបស់ខ្លួនទេ ។ នេះដោយសារតែកងទ័ពរបស់បក្សកុម្មុយនិស្តកម្ពុជាបានប្រព្រឹត្តបទល្មើសជាសម្ងាត់និងបានបំបាត់ភស្តុតាងនៃឧក្រិដ្ឋកម្មរបស់ខ្លួនទាំងអស់ ។ ម៉ម កល្យានី បានពន្យល់ថា ÷

ការបំផ្លាញចោលនូវរាល់ភស្តុតាងទាំងអស់នៃឧក្រិដ្ឋកម្មគឺមានសារសំខាន់ណាស់ ធ្វើដូច្នេះមន្ត្រីជាន់ខ្ពស់នឹងមិនដឹងអំពីឧក្រិដ្ឋកម្មរំលោភផ្លូវភេទដែលបានកើតឡើង ។ គ្រាន់តែគំរាមកំហែងជនរងគ្រោះមិនឲ្យបកអាក្រាតឧក្រិដ្ឋកម្មនោះមិនទាន់គ្រប់គ្រាន់ទេ ។ ដូច្នេះជនរងគ្រោះទាំងនោះត្រូវបានសម្លាប់បំបិទមាត់ដើម្បីបំបាត់ស្លាកស្នាមទាំងអស់នៃឧក្រិដ្ឋកម្ម ។

សក្ខីភាពរបស់អ្នកដែលនៅរស់រានជីវិតបានបង្ហាញឲ្យឃើញថាមេដឹកនាំជាន់ខ្ពស់មិនបាន “គ្រប់គ្រងឲ្យមានប្រសិទ្ធភាព” ចំពោះអ្នកនៅក្រោមបញ្ជារបស់ខ្លួន យ៉ាងហោចណាស់នៅក្នុងទីតាំងពិសេសណាមួយ ។ អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបានភស្តុតាងដែលអាចបង្ហាញថាអំពើរំលោភផ្លូវភេទមានលក្ខណៈរីករាលដាល និងមានជាខ្សែសង្វាក់ប្រឆាំងនឹងសមាជិកនៃក្រុមជាតិពន្ធភាគតិចផ្សេងៗនៅក្នុងប្រទេសកម្ពុជា រួមទាំងជាតិពន្ធវៀតណាម ចាម និងចិន ជាពិសេសនៅក្នុងមន្ទីរឃុំឃាំង ។ របាយការណ៍មានផ្សេងៗពីគ្នាស្តីពីអំពើហិង្សាផ្លូវភេទនៅក្នុងមន្ទីរឃុំឃាំងដែលមានអ្នកទោសស្ត្រីសរុបប្រមាណ៦,៨ភាគរយនៃចំនួនប្រជាជនទាំងអស់ ។ នៅក្នុងសៀវភៅដ៏ល្បីល្បាញអំពីមន្ទីរឃុំឃាំងស-២១ ដេវីដ ឆេនដល័រ បានបញ្ជាក់ថា អំពើបំពារបំពានផ្លូវភេទកើតឡើងមិនសូវញឹកញាប់ប៉ុន្មានទេនៅក្នុងមន្ទីរឃុំឃាំងនេះ ដោយសារការត្រួតពិនិត្យយ៉ាងជិតដល់របស់ឆ្មាំគុក ។ ឆ្មាំគុកត្រូវបានហៅឲ្យចូលរួមនៅពេលសួរចម្លើយអ្នកទោសស្ត្រីដើម្បីបញ្ចៀសទារុណកម្មផ្លូវភេទ ។ ផ្ទុយទៅវិញ មនុស្សម្នាក់ដែល ម៉ម កល្យានី បានសម្ភាសន៍បានរៀបរាប់អំពីរបៀបដែលឆ្មាំគុករំលោភអ្នកទោសដែលជានារីក្មេងៗម្តងហើយម្តងទៀតនៅក្នុងមន្ទីរឃុំឃាំងមួយដែលមានឈ្មោះថា“មន្ទីរ១៥” ។ អតីតអ្នកទោសម្នាក់នោះបានពន្យល់ថា “ប្រហែលជាអ្នកទាំងនោះ (ឆ្មាំគុក) ព្យាយាមលាក់បាំងមិនឲ្យមេកោយរបស់ខ្លួនដឹង ។ នៅមន្ទីរ១៥មានកងទ័ពដប់នាក់នៅការពារយើង ដូច្នេះអ្នកទាំងដប់នេះមានភាពងាយស្រួលណាស់ក្នុងការលាក់បាំងអ្វីដែលខ្លួនបានប្រព្រឹត្ត ។ គ្មាននរណាម្នាក់ចេញឬចូលទេ ។” ជាការពិត របាយការណ៍របស់ ឆេនដល័រ និង កល្យានី មានភាពស៊ីសង្វាក់គ្នាត្រង់ថា អំពើរំលោភផ្លូវភេទទំនងជាកើតឡើងភាគច្រើននៅកន្លែងដែលមិនសូវមានការត្រួតពិនិត្យ

ជិតដល់ ។ នៅមន្ទីរឃុំឃាំងស-២១ ដែលអ្នកគ្រប់គ្រងតែងតែត្រួតពិនិត្យយ៉ាងហ្មត់ចត់ ឬមានទំនាក់ទំនងញឹកញាប់ជាមួយកម្មាភិបាលថ្នាក់ក្រោម ។ ឆ្មាំគុកនឹងត្រូវដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរសូម្បីតែចំពោះការប្រព្រឹត្តកំហុសតូចតាចមួយ ប៉ុន្តែនៅជំរំតាមព្រៃដែលនៅឆ្ងាយពីការត្រួតពិនិត្យរបស់ថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ឆ្មាំគុកធ្វើអ្វីៗស្រេចនឹងចិត្ត ។

ដោយផ្អែកលើភស្តុតាងនេះ ព្រះរាជអាជ្ញានឹងប្រឈមមុខចំពោះការលំបាកក្នុងការបង្ហាញថា មេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យបានដឹងឬមិនបានដាក់ទណ្ឌកម្មចំពោះអ្នកដែលប្រព្រឹត្តទង្វើនេះ ។ ការលំបាកក៏នឹងប្រាកដជាមានដែរនៅក្នុងការបង្ហាញថា មេដឹកនាំជាន់ខ្ពស់គ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើអ្នកនៅក្រោមបញ្ជារបស់ខ្លួននៅកន្លែងដែលឧក្រិដ្ឋកម្មរំលោភផ្លូវភេទភាគច្រើនបានកើតឡើង ។ ការណ៍ដែលឧក្រិដ្ឋកម្មរំលោភនេះត្រូវបានប្រព្រឹត្តដោយសម្ងាត់លាក់កំបាំង និងបានបំផ្លិចបំផ្លាញភស្តុតាងអស់ជាច្រើន ក៏បណ្តាលឲ្យមានការលំបាកក្នុងការបង្ហាញថា ឧក្រិដ្ឋកម្មនេះមានទម្រង់រីករាលដាល និងមានការរៀបចំជាខ្សែសង្វាក់ ។ ភស្តុតាងដែលមានស្រាប់អំពីរបៀបដែលឧក្រិដ្ឋកម្មរំលោភផ្លូវភេទត្រូវបានប្រព្រឹត្តគឺស្របទៅនឹងទ្រឹស្តីរបស់ ស៊ីវ ហេង៉រ ដែលថាភាគច្រើននៃឧក្រិដ្ឋកម្មដែលបានកើតឡើងបណ្តាលមកពីអ្នកនៅក្រោមបង្គាប់ប្រើប្រាស់អំណាចដោយចិត្តឯងជាជាងមកពីការសមគំនិតរវាងថ្នាក់លើ និងថ្នាក់ក្រោមរបស់បក្សកុម្មុយនិស្តកម្ពុជាដើម្បីប្រើប្រាស់អំពើរំលោភផ្លូវភេទជាអាវុធនៃសង្គ្រាម ។ ច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញបានធ្វើឲ្យមានការលំបាកជាខ្លាំងក្នុងការបង្ហាញថា អំពើរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ទ្រឹស្តី“ការទទួលខុសត្រូវចំពោះការចេញបញ្ជា” បានឆ្លុះបញ្ចាំងអំពីការជឿជាក់ដែលថា មេដឹកនាំជាន់ខ្ពស់ជាអ្នកទទួលខុសត្រូវ ជាជាងអ្នកនៅក្រោមបញ្ជា ហើយទ្រឹស្តីនៃការអនុវត្តនេះទំនងជាចាប់តែ“ត្រីធំ” និងចាប់មេដឹកនាំជាន់ខ្ពស់ទាំងនេះឲ្យទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក៏ប៉ុន្តែផលវិបាកនៃសកម្មភាពនេះប្រហែលជាការខកខានក្នុងការផ្តល់ការទទួលខុសត្រូវចំពោះបទល្មើសសំខាន់ៗជាច្រើនដូចជាបទល្មើសរំលោភផ្លូវភេទ និងការលុបចោលនូវឧក្រិដ្ឋកម្មទាំងនេះចេញពីឯកសារប្រវត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញ ។

### ១) ការលុបបទល្មើសរំលោភផ្លូវភេទចេញពីបទល្មើសច្បាប់ជាតិ

អង្គជំនុំជម្រះវិសាមញ្ញបានបញ្ចូលបទល្មើសលើច្បាប់ជាតិចំនួនបី (អំពើមនុស្សឃាត ទារុណកម្ម និងការវាយប្រហារលើសាសនា) និងបទល្មើសលើច្បាប់អន្តរជាតិចំនួនប្រាំ (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ និងឧក្រិដ្ឋកម្មប្រឆាំងអ្នកដែលបានទទួលការការពារជាអន្តរជាតិ) ។ បទល្មើសរំលោភផ្លូវភេទមិនត្រូវបានបញ្ចូលជាបទល្មើសលើច្បាប់ជាតិនៅក្នុងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញទេ បើទោះបីជាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ របស់ប្រទេសកម្ពុជាដែលនៅជាធរមាននៅឡើយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានដាក់បញ្ចូលទង្វើនេះថាជាបទល្មើសក៏ដោយ ។ មានការពន្យល់ជាច្រើនទាក់ទងនឹងការមិនបញ្ចូលបទល្មើសរំលោភផ្លូវភេទទៅក្នុងប្រភេទឧក្រិដ្ឋកម្មដែលនឹងត្រូវកាត់សេចក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ វាអាចជាហេតុផលនៃជំនឿជាទូទៅដែលថាអំពើរំលោភផ្លូវភេទមិនបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះអំពើនេះផ្ទុយទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ដូចដែលបានលើកឡើងរួចហើយនៅផ្នែកទី១ ភស្តុតាងជាក់ស្តែងនៃអំពើរំលោភផ្លូវភេទមិនមានទេ ហើយក៏មិនសូវមានរបាយការណ៍ពីស្ត្រីរងគ្រោះនៃអំពើនេះដែរ ។ ស្ត្រីរងគ្រោះបង្ខំចិត្តនៅស្ងៀមដោយសារតែក្តីអាម៉ាស់និងការភ័យខ្លាច ។ ជាងនេះទៅទៀត ខណៈពេលដែលច្បាប់ស្តីពីអង្គជំនុំជម្រះវិសាមញ្ញកំពុងតែពិភាក្សា មានការស្រាវជ្រាវមួយចំនួនទាក់ទងនឹងប្រធានបទការបំពារបំពានផ្លូវភេទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនទាន់គ្រប់គ្រាន់នៅឡើយ ។ ជាលទ្ធផល វិធានការជាអន្តរជាតិប្រឆាំងនឹងអំពើរំលោភផ្លូវភេទដែលបានប្រើប្រាស់នៅតុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងអតីតយូហ្គោស្លាវីមិនមានកើតឡើងទេនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃប្រទេសកម្ពុជា ។

ក្រៅពីកង្វះខាតភស្តុតាងជាក់ស្តែង ថែមទាំងមិនមានការ

ស្រាវជ្រាវបន្ថែមទៀតអំពីអំពើរំលោភនិងការបំពារបំពានផ្លូវភេទក្នុងគោលបំណងដើម្បីបញ្ចូលបទល្មើសផ្លូវភេទទៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅឡើយទេ ។ មកទល់នឹងពេលផ្តល់សច្ចាប័ននៅខែតុលាឆ្នាំ២០០៤ អ្នកស្រាវជ្រាវប្រមូលបានសក្ខីភាពគ្រប់គ្រាន់ពីអ្នកដែលនៅរស់រានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យដើម្បីបង្ហាញថាអំពើរំលោភផ្លូវភេទពិតជាកើតឡើង ។ បទពិសោធន៍ពីការស៊ើបអង្កេតផ្សេងៗនៅក្នុងអំពើសាហាវយង់ឃ្នងផ្សេងៗបានចាប់ផ្តើមផ្តោតលើការសិក្សាពីអំពើហិង្សាផ្លូវភេទលើស្ត្រី ។ ការលុបចេញពីបទល្មើសច្បាប់ជាតិនូវបទល្មើសរំលោភផ្លូវភេទពីក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនឹងមានបញ្ហាបើត្រួតពិនិត្យមើលភាពជឿនលឿនទៅមុខនៃសាលាជំនុំជម្រះក្តីអន្តរជាតិនៅរ៉្វាន់ដានិងយូហ្គោស្លាវីក្នុងការទទួលស្គាល់ថានៅក្នុងប្រវត្តិសាស្ត្រមានការប្រើប្រាស់អំពើរំលោភផ្លូវភេទជាអាវុធនៃសង្គ្រាម ។ សាលាជំនុំជម្រះក្តីទាំងនេះបានប្រកាសថា អំពើរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងទារុណកម្ម ព្រមទាំងបានរួមចំណែកយ៉ាងសម្បើមនៅក្នុងយុត្តិសាស្ត្រអន្តរជាតិជុំវិញឧក្រិដ្ឋកម្មទាក់ទងនឹងភេទ ។



ជាត រចនា និង តាំង គីម ឆ្នាំ២០០៤

### គ) ការប្រើប្រាស់វាក្យសព្ទដែលចាស់គំរិលនិងមានន័យចង្អៀត

ព្រះរាជអាជ្ញានឹងនៅតែមានជម្រើសក្នុងការចោទប្រកាន់អំពើរំលោភផ្លូវភេទនៅក្នុងបទល្មើសអន្តរជាតិ ។ បើទោះបីជាអនុសញ្ញាទីក្រុងហ្សឺណែវមិនបានចែងឲ្យច្បាស់លាស់ថាអំពើរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មសង្គ្រាមក៏ដោយ ក៏អំពើនេះត្រូវបានចាត់ទុកថាជាអំពើបំពារបំពានធ្ងន់ធ្ងរនៅក្រោមអនុសញ្ញាក្រុងហ្សឺណែវទីបួនដែលបានហាមឃាត់“ការបង្កឲ្យមានរបួសធ្ងន់ធ្ងរដោយចេតនា ឬបង្កឲ្យមានការឈឺចាប់ដល់រាងកាយឬសុខភាព” និង“ការប្រព្រឹត្តអំពើអមនុស្សធម៌”ទៅលើជនស៊ីវិល ។ ជាងនេះទៅទៀត សាលាជំនុំជម្រះក្តីនៅយូហ្គោស្លាវីនិងរ៉្វាន់ដាបានជួយឲ្យច្បាប់អន្តរជាតិអភិវឌ្ឍទៅមុខដោយការទទួលស្គាល់ថាអំពើរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មសង្គ្រាម ។

ជាអកុសល ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជានៅតែប្រើប្រាស់វាក្យស័ព្ទចាស់គំរិលដែលដកស្រង់ចេញពីច្បាប់មនុស្សធម៌អន្តរជាតិដដែល ដោយមិនបានប្រើប្រាស់វាក្យស័ព្ទដែលមានចែងនៅច្បាប់បង្កើតសាលាជំនុំជម្រះក្តីអន្តរជាតិសំខាន់ៗពីរខាងលើឡើយ ។ មាត្រា៦នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញមិនបានបញ្ចូលអំពើរំលោភផ្លូវភេទ ឬអំពើហិង្សាផ្លូវភេទ ជាឧក្រិដ្ឋកម្មសង្គ្រាមទេ ។ អ្នកធ្វើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានបដិសេធនិយមន័យទូលាយដាងមុនដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតសាលាជំនុំជម្រះក្តីនៅរ៉្វាន់ដាដែលបានដាក់បញ្ចូល“អំពើរំលោភ ការបង្ខំឲ្យធ្វើពេស្យាចារ និងរាល់ទម្រង់នៃអំពើបំពារបំពានមិនសមរម្យ” ថាជាឧក្រិដ្ឋកម្មសង្គ្រាម ។ មធ្យោបាយតែមួយគត់ដែលអាចចោទប្រកាន់ថាអំពើរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មសង្គ្រាមគឺត្រូវអះអាងថាអំពើរំលោភផ្លូវភេទស្ថិតនៅក្នុងឃ្លាដែលមិនសូវច្បាស់លាស់ថា “ការបំពានធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូរបស់បុគ្គល” ឬ “អំពើបន្ទាបបន្ថោកនិងមើលងាយ” ។

បើទោះបីជាអ្នកធ្វើច្បាប់នេះបានដាក់បញ្ចូលអំពើរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅក្នុងមាត្រា៥ក្តី ក៏ច្បាប់

ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនេះបានលុបចោលប្រភេទផ្សេងៗនៃឧក្រិដ្ឋកម្មផ្លូវភេទ ដូចជាការបំពារបំពានផ្លូវភេទនិងការធ្វើឲ្យទៅជាទាសករដែលអ្នកដែលនៅរស់រានមានជីវិតបានអះអាងថាពិតជាមានកើតឡើងនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយសារតែភាពខុសគ្នានៅក្នុងពាក្យពេចន៍ដែលសរសេរនៅក្នុងច្បាប់ វាមិនទាន់ច្បាស់លាស់នៅឡើយថាតើអង្គជំនុំជម្រះវិសាមញ្ញនឹងយកយុត្តិសាស្ត្ររបស់សាលាជំនុំជម្រះក្តីអន្តរជាតិនៅរ៉ាន់ដានិងអតីតយូហ្គោស្លាវីមកបកស្រាយនិយមន័យរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងនឹងអំពើរំលោភផ្លូវភេទដែរឬទេ ។ យុត្តិសាស្ត្ររបស់សាលាជំនុំជម្រះក្តីអន្តរជាតិទាំងនេះបានអភិវឌ្ឍនិយមន័យនៃអំពើរំលោភផ្លូវភេទនិងការបំពារបំពានផ្លូវភេទនៅក្រោមច្បាប់អន្តរជាតិ ។ សាលាជំនុំជម្រះក្តីអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដាបានឲ្យនិយមន័យ "អំពើហិង្សាផ្លូវភេទ" យ៉ាងទូលាយថាជា"ការបំពារបំពានរូបរាងកាយ ដើម្បីមូលហេតុផ្លូវភេទដែលប្រព្រឹត្តលើបុគ្គលម្នាក់នៅក្នុងស្ថានភាពបង្ខិតបង្ខំ" ។ សាលាជំនុំជម្រះក្តីនេះបានផ្តល់និយមន័យទូលាយជាងមុននូវពាក្យ "ស្ថានភាពគំរាមកំហែង" ថាជាស្ថានភាពដែលរួមមាន "ការគំរាមកំហែង ការបំភិតបំភ័យ ការបោកប្រាស់និងទម្រង់ផ្សេងៗទៀតនៃការបង្ខិតបង្ខំ" ដូចជានៅក្នុងស្ថានភាពដែលមានជម្លោះប្រដាប់អាវុធឬវត្តមាននៃកងកម្លាំងប្រដាប់អាវុធ" ។ សាលក្រមបន្តៗមកទៀតក៏បានពង្រីកនិយមន័យនៃឧក្រិដ្ឋកម្មផ្លូវភេទដែលស្ថិតនៅក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ហើយថែមទាំងបានបញ្ចូលការបំពារបំពានផ្លូវភេទថែមទៀត ។ និយមន័យដ៏ច្បាស់លាស់នៃអំពើរំលោភផ្លូវភេទមានសារសំខាន់ណាស់ ដោយសារតែនិយមន័យនេះបានទទួលស្គាល់ទិដ្ឋភាពគំរាមកំហែងនៃជម្លោះប្រដាប់អាវុធ ។ ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញនឹងទំនងជាជំរុញការអនុវត្តយុត្តិសាស្ត្ររបស់សាលាជំនុំជម្រះក្តីនៅប្រទេសរ៉ាន់ដានិងអតីតយូហ្គោស្លាវីទាក់ទងនឹងអំពើហិង្សាផ្លូវភេទ ប៉ុន្តែវាហាក់បីដូចជាសុទិដ្ឋិនិយមពេកក្នុងការសន្មតថាចៅក្រមកម្ពុជានឹងទាញយកមកប្រើប្រាស់នូវនិយមន័យដ៏រីកចម្រើននៃបទល្មើសផ្លូវភេទ ។

## ឃ) ភាពប្រទូសរ៉ាយនៃប្រព័ន្ធយុត្តិធម៌កម្ពុជាចំពោះបទល្មើសផ្លូវភេទ

ការខកខានរបស់ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងការបញ្ចូលបទល្មើសរំលោភផ្លូវភេទទៅក្នុងបទល្មើសច្បាប់ជាតិ និងការប្រើប្រាស់និយមន័យចាស់គំរិលក្នុងការបកស្រាយបទល្មើសរំលោភផ្លូវភេទ ប្រហែលជាអាចពន្យល់បានខ្លះតាមរយៈការអនុវត្តជាទូទៅនូវបទល្មើសរំលោភផ្លូវភេទនៅក្រោមច្បាប់ជាតិ ។ បើទោះបីជាភាពខុះចន្លោះនៃច្បាប់និងបញ្ហាភ័ស្តុតាងដែលបានពិភាក្សាពីផ្នែក "ក" ដល់ផ្នែក "គ" ខាងលើត្រូវបានដោះស្រាយ ការចោទប្រកាន់ណាមួយទាក់ទងនឹងបទល្មើសរំលោភផ្លូវភេទនៅក្នុងអង្គជំនុំជម្រះនឹងនៅតែជួបប្រទះនឹងវប្បធម៌ចំពោះការចោទប្រកាន់នោះ ។ មានបីចំណុចដែលបង្ហាញអំពីការខកខាននៃប្រព័ន្ធច្បាប់កម្ពុជាក្នុងការរារាំងអំពើរំលោភផ្លូវភេទៈ ការមិនបានរាយការណ៍វត្តមាននៃអំពើរំលោភផ្លូវភេទ កម្រិតទាបនៃការកាត់សេចក្តីឧក្រិដ្ឋកម្មរំលោភផ្លូវភេទ និងកម្រិតកាន់តែទាបនៃការផ្តន្ទាទោសអំពើរំលោភផ្លូវភេទ។ អង្គការសិទ្ធិមនុស្សបានរាយការណ៍ថា សូម្បីតែអំពើរំលោភផ្លូវភេទបានកើនឡើងជារៀងរាល់ឆ្នាំ ក៏ដោយ ឧបសគ្គនៅក្នុងប្រព័ន្ធយុត្តិធម៌នៅតែរារាំងស្ត្រីជាច្រើនមិនឲ្យចេញមុខបរិហារបទល្មើសរំលោភផ្លូវភេទ ។ ឧបសគ្គទាំងនេះកើតឡើងនៅគ្រប់ដំណាក់កាលទាំងអស់ពីដំណាក់កាលស៊ើបអង្កេតទៅដល់ដំណាក់កាលសវនាការ ហើយនៅជិតដាមយ៉ាងជាប់នៅក្នុងប្រព័ន្ធច្បាប់និងវប្បធម៌ ។


តាំង គីម
ថតនៅប្រទេសអាល្លឺម៉ង់ ឆ្នាំ២០០៥

មូលហេតុមួយចំនួនជាហេតុផលនៃការខកខានមិនបានកាត់សេចក្តីអំពើរំលោភផ្លូវភេទ ។ ទីមួយ អំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការបានបណ្តាលឲ្យពលរដ្ឋអស់ទំនុកចិត្តទៅលើប្រព័ន្ធយុត្តិធម៌ ។ ជាញឹកញាប់ អ្នកអនុវត្តច្បាប់បានបំពានលើច្បាប់ដើម្បីស្វែងរកដំណោះស្រាយរវាងភាគី ដែលក្នុងនោះរួមមាន

ការបង្ខិតជនរងគ្រោះឲ្យទទួលយកសំណងជាប្រាក់ឬបង្ខំឲ្យរៀបការជាមួយជនល្មើស ។ អំពើស៊ីសំណូកសូកប៉ាន់បានធ្វើឲ្យជនរងគ្រោះរារែកក្នុងការដាក់ពាក្យបណ្ដឹងទៅតុលាការ ។ បើទោះបីជាច្បាប់កម្ពុជាតម្រូវឲ្យរដ្ឋជាអ្នកទទួលខុសត្រូវចំពោះការកាត់សេចក្ដី ជនរងគ្រោះត្រូវតែបង់សំណូកជាមុនដើម្បីអាចចាប់ផ្ដើមការស៊ើបអង្កេត និងត្រូវបង់ថ្លៃលិខិតកោសល្យវិច័យរបស់ពេទ្យ (ដែលជាភ័ស្ដុតាងសំខាន់បំផុតនៅក្នុងករណីរំលោភផ្លូវភេទ) ។

ទីពីរ ការមិនផ្ដល់តម្លៃដល់ស្ដ្រីរងគ្រោះនៃអំពើរំលោភផ្លូវភេទនៅប្រទេសកម្ពុជា បានធ្វើឲ្យស្ដ្រីអស់ទឹកចិត្តក្នុងការបើកកកាយអំពើរំលោភផ្លូវភេទ ដោយសារការព្រួយបារម្ភចំពោះក្ដីអាម៉ាស់ដែលមិនអាចទទួលយកបានសម្រាប់ខ្លួនឯងនិងក្រុមគ្រួសារ ។ ភាគច្រើន ការភ័យខ្លាចផ្នែកអារម្មណ៍កើតព្រមគ្នានឹងកង្វល់ផ្នែកសន្ដិសុខ ។ ឧទាហរណ៍ ស្ដ្រីម្នាក់អាចព្រួយបារម្ភក្នុងការបកអាក្រាតរឿងរ៉ាវរំលោភផ្លូវភេទ ព្រោះអាចនាំទៅដល់ការសងសឹកពីសំណាក់ជនដៃដល់ឬការតិះដៀល និងការមិនរាប់រកពីសហគមន៍ដែលស្ដ្រីនោះរស់នៅ ។ នាយកអង្គការលីកាដូដែលជាអង្គការសិទ្ធិមនុស្សដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា បានពន្យល់ថា ប្រជាជនកម្ពុជាភាគច្រើនជឿជាក់ថា អំពើរំលោភផ្លូវភេទមិនមែនជាបទល្មើសទេ ដោយសារតែជំនឿមិនសមរម្យថាបុរសមិនអាចគ្រប់គ្រងខ្លួនឯងបាន ។ មន្ដ្រីតុលាការមិនអាចផ្អែកលើទស្សនៈមិនសមរម្យនេះទេ បើមិនដូច្នោះទេប្រាកដជាបង្កើតជាបញ្ហាទីបីមិនខាន ពោលគឺ «ការបកស្រាយច្បាប់មិនត្រឹមត្រូវ» ។ ចៅក្រមបានលើកលែងការចោទប្រកាន់បទល្មើសរំលោភផ្លូវភេទដោយសារតែមូលហេតុមិនត្រឹមត្រូវ ដូចជានៅពេលដែលជនរងគ្រោះមិនមែនជានារីព្រហ្មចារី ឬនៅពេលដែលជនដៃដល់ជាសាច់ញាតិរបស់ជនរងគ្រោះ ។ បើទោះបីជាច្បាប់ទាក់ទងនឹងបទល្មើសរំលោភផ្លូវភេទរបស់កម្ពុជាមានភាពខ្វះចន្លោះច្រើនក៏ដោយ ជាក់ស្ដែងច្បាប់នោះខកខានមិនបានបកស្រាយអំពី «ការព្រមព្រៀង» ឬក៏លទ្ធភាពដែលអាចកំណត់ថាជា«ការព្រមព្រៀង» ម្យ៉ាងទៀត ចៅក្រមមិនមានឆន្ទៈក្នុងការបំបាត់ចោលនូវជំនឿមិនសមរម្យរបស់ខ្លួនហើយអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ ។ អង្គការសិទ្ធិមនុស្សមួយដែលសិក្សាទៅលើអំពើរំលោភផ្លូវភេទនៅកម្ពុជាបានរាយការណ៍ថា នៅឆ្នាំ២០០៤ ចៅក្រមបានកាត់ទោសជនសង្ស័យទាក់ទងនឹងអំពើរំលោភផ្លូវភេទតែប្រាំពីរភាគរយនៃបទល្មើសផ្លូវភេទទាំងអស់ ។


តាំង គីម ថតនៅប្រទេសអាល្លឺម៉ង់ ឆ្នាំ២០០៥

ចុងក្រោយ ប្រជាជនកម្ពុជាមិនមានជំនឿចិត្តទាល់តែសោះចំពោះប្រព័ន្ធច្បាប់របស់ប្រទេស ។ ជនដៃដល់ដឹងថាខ្លួនអាចមានឥទ្ធិពលទៅលើលទ្ធផលនៃរឿងក្ដីដោយការផ្ដល់សំណូកដល់ចៅក្រមឬមន្ដ្រីតុលាការ ហើយសាធារណជនក៏ខកខានក្នុងការបរិហារបទល្មើសឬរៀបចំជាពាក្យបណ្ដឹង ។ នេះជាការពិតនៅពេលដែលជនដៃដល់ជាបុគ្គលិករដ្ឋ ។ នៅក្នុងចំណោមបទល្មើសរំលោភផ្លូវភេទចំនួន២៥ករណីដែលប្រព្រឹត្តដោយភ្នាក់ងាររដ្ឋនៅឆ្នាំ២០០៣ មិនមានការផ្ដន្ទាទោសមួយករណីទាល់តែសោះ ។

## ង) ការប្រមូលភ័ស្ដុតាង

តាមប្រវត្តិសាស្ដ្រ ការប្រមូលភ័ស្ដុតាងនៃបទល្មើសប្រឆាំងនឹងស្ដ្រី ជាពិសេសចំពោះឧក្រិដ្ឋកម្មផ្លូវភេទ មានការលំបាកជាខ្លាំងដោយសារកត្តាជាក់ស្ដែងនិងសង្គម ។ គម្លាតដ៏វែងឆ្ងាយរវាងហេតុការណ៍និងការបង្កើតអង្គជំនុំជម្រះក្ដីគឺប្រហែលជាឧបសគ្គជាក់ស្ដែងដ៏លំបាកបំផុតក្នុងការប្រមូលភ័ស្ដុតាងនៃបទល្មើសរំលោភផ្លូវភេទ ។ បន្ទាប់ពីរយៈពេល៣០ឆ្នាំកន្លងផុត

ទៅ ភស្តុតាងជាក់ស្តែងនៃបទល្មើសផ្លូវភេទបានឈានទៅដល់ចំណុចមួយដែលប្រើការលែងកើត ហើយការបាត់បង់នេះបានមានសារសំខាន់ជាពិសេសចំពោះបទល្មើសរំលោភផ្លូវភេទនៅក្នុងប្រទេសកម្ពុជាដែលអាស្រ័យលើលិខិតកោសល្យវិច័យរបស់ពេទ្យដើម្បីបញ្ជាក់អំពីភស្តុតាងនៃការរំលោភផ្លូវភេទ ។

ទារុណកម្មផ្នែកស្មារតីនិងឥទ្ធិពលផ្នែកចិត្តវិទ្យានៃអំពើរំលោភដែលជាញឹកញាប់ត្រូវបានលាក់កំបាំងយូរហូតដល់ភស្តុតាងជាក់ស្តែងរលុបបាត់ បានបង្កើតជាឧបសគ្គជាច្រើនដល់អ្នកស៊ើបអង្កេត ។ ការប៉ះពាល់ផ្លូវចិត្តជារឿងធម្មតាសម្រាប់អ្នកដែលជាជនរងគ្រោះនៃអំពើរំលោភផ្លូវភេទ គឺបណ្តាលឲ្យស្ត្រីមានការចងចាំដ៏ឈឺចាប់ជាពិសេសនៅពេលអ្នកទាំងនោះត្រូវបង្ខំចិត្តរំឭករឿងរ៉ាវដ៏ឈឺចាប់នេះ ។ ប៉ែតសិបភាគរយនៃអ្នកដែលរួចជីវិតពីអំពើរំលោភផ្លូវភេទនៅរ៉្វាន់ដាត្រូវបានរកឃើញថា "មានការប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ"បន្ទាប់ពីជម្លោះត្រូវបានបញ្ចប់ ។ អ្នកស៊ើបអង្កេតនៅក្នុងតុលាការនៅអតីតយូហ្គោស្លាវីបានរកឃើញថា ការសួរសំណួរដដែលៗបានធ្វើឲ្យប៉ះទង្គិចម្តងទៀតដល់ផ្លូវចិត្តរបស់ជនរងគ្រោះនៃអំពើរំលោភផ្លូវភេទ ។ បទពិសោធន៍កន្លងមកបង្ហាញថា ពេលវេលាបានធ្វើឲ្យរសាយការប៉ះទង្គិចផ្លូវចិត្ត ប៉ុន្តែមិនបានជួយឲ្យស្ត្រីរងគ្រោះសះស្បើយពីការប៉ះទង្គិចផ្លូវចិត្តនោះទេ ។ ជាក់ស្តែង"ស្ត្រីកំដរអារម្មណ៍"ជប៉ុន (ស្ត្រីជនជាតិជប៉ុនដែលស្ម័គ្រចិត្តលះបង់ខ្លួនប្រាណឲ្យទាហានជប៉ុននៅសម័យសង្គ្រាមលោកលើកទីពីរ) មិនបានបង្ហើបរឿងរ៉ាវផ្ទាល់ខ្លួនអស់រយៈពេលរាប់ទសវត្សរ៍បន្ទាប់ពីសង្គ្រាមលោកលើកទីពីរ ។ ដូចគ្នានេះដែរ ២៨ឆ្នាំក្រោយហេតុការណ៍ទើប តាំង គីម បង្ហើបពីការឈឺចាប់នៃអំពើរំលោភផ្លូវភេទ ។

ឧបសគ្គមួយផ្សេងទៀតចំពោះការប្រមូលភស្តុតាងនៃអំពើរំលោភផ្លូវភេទគឺភាពរួញរារបស់ស្ត្រីខ្លួនឯងក្នុងការបរិហាររឿងរ៉ាវផ្ទាល់ខ្លួនដោយសារតែផលវិបាកសង្គមដូចជា ការចំអក ការប្រមាថ ការមិនទទួលស្គាល់ ការមិនរាប់រក ។ ការនេះបានកើតឡើងជាញឹកញាប់នៅក្នុងសង្គមដែលគ្រប់គ្រងតាមបែបប្រពៃណីនិងដែលឲ្យតម្លៃលើបុរស ។ នៅក្នុងសង្គមប្រភេទនេះ តម្លៃរបស់នារីស្ថិតនៅលើសេចក្តីបរិសុទ្ធនៃកាយ វាចាចិត្ត និងព្រហ្មចារី ។ នៅក្នុងសង្គមដែលចាត់ទុកថាឧក្រិដ្ឋកម្មប្រឆាំងនឹងស្ត្រីជាឧក្រិដ្ឋកម្មប្រឆាំងនឹងក្រុមគ្រួសារឬសហគមន៍ទាំងមូល ជាញឹកញាប់គ្រួសារមិនបានរាប់អានជនរងគ្រោះឡើយដើម្បីថែរក្សាកត្តិយសក្រុមគ្រួសារនៅក្នុងសង្គម ។ អ្នកស៊ើបអង្កេតដែលបានធ្វើសម្ភាសស្ត្រីនៅក្នុងប្រទេសហ្គាតេម៉ាឡាពេលក្រោយជម្លោះបានរកឃើញថា មានស្ត្រីតិចតួចណាស់ដែលហ៊ាននិយាយអំពីបទពិសោធន៍ឈឺចាប់នៃអំពើរំលោភផ្លូវភេទ ដោយសារតែស្ត្រីទាំងនោះបានគិតថាវាជាផ្នែកមួយនៃយុទ្ធនាការយោធាប្រឆាំងនឹងសហគមន៍អន្តោគ្រាម ។ ជនរងគ្រោះរស់នៅដោយចាត់ទុកថាខ្លួនគ្មានរឿងអ្វីកើតឡើង ហើយជាទូទៅរំពុកតែអំពីទុក្ខសោកពីឥទ្ធិពលនៃសង្គ្រាម ។ អ្នកស៊ើបអង្កេតដែលមិនទទួលបានការហ្វឹកហ្វឺនគ្រប់គ្រាន់ក្នុងការសាកសួរសំណួរទាក់ទងនឹងបញ្ហានេះនឹងធ្វើឲ្យឧក្រិដ្ឋកម្មផ្លូវភេទកប់កាន់តែជ្រៅថែមទៀត ។

**(នៅមានត)**

**ខេទ្រីណា អាន់ជីសុន**

## សីលធម៌ប្រការទី៦របស់ជនបដិវត្តន៍

◆ **កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឱ្យសោះ។**

*(ទស្សនាវដ្តី "យុវជនយុវនារីបដិវត្តន៍" លេខ១០ ខែតុលា ឆ្នាំ១៩៧៨)*

## ពាក្យស្លោកខ្មែរក្រហម

◆ **បើចង់ធ្វើបដិវត្តន៍ត្រូវរកមនុស្សបដិវត្តន៍ ចង់បានមនុស្សបដិវត្តន៍ត្រូវមានគោលជំហរសតិអារម្មណ៍បដិវត្តន៍។**

*(កំណត់ហេតុលេខ ០៥៣)*

◆ **ភារកិច្ចរបស់យើងត្រូវទទួលខុសត្រូវចំពោះប្រជាជនគ្រប់សម្តី គ្រប់អំពើ គ្រប់នយោបាយ ត្រូវតែស្របតាមយោបល់ ស្របតាមប្រយោជន៍របស់ប្រជាជនទាំងស្រុង បើមានកំហុសត្រូវតែកម្រូវ បានហៅថាទទួលខុសត្រូវចំពោះប្រជាជន។**

*(កំណត់ហេតុរបស់សមមិត្ត ញ៉ុក សារុន)*

◆ **ដឹកនាំត្រូវធ្វើគំរូមហាជនលើជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំង ការងារ រស់នៅ សីលធម៌ និងសាមគ្គីភាព ឯកភាព តាមមាគ៌ារបស់បក្ស។** *(កំណត់ហេតុលេខ ០៧៦)*

# ការិយាល័យពត៌មានសាធារណៈ

«ការិយាល័យពត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យពត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ពត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ធេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យពត៌មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង ៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

**៤) ហាងកាហ្វេ** ៖ មជ្ឈមណ្ឌលយើងខ្ញុំមានហាងកាហ្វេសម្រាប់បម្រើសេវាភេសជ្ជៈនិងចំណីអាហារជូនលោកអ្នក ។

ការិយាល័យពត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជ័យ សុភារម្យ ឬ រ័ត្ន ដារ៉ា ពិដោរ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។


ក្រុមនិស្សិតធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា


ក្រុមដូនជីប្រជុំនៅបន្ទប់ពត៌មានសាធារណៈ

# សិទ្ធិមនុស្ស និង កម្ពុជាប្រជាធិបតេយ្យរបបម៉ៅនិយម

ប៉ុល ពត ដែលជាអ្នកនិយមលទ្ធិម៉ៅ គឺជាជនដែលបង្ក គ្រោះថ្នាក់ធ្ងន់ធ្ងរបំផុតនៃរបបវាលពិឃាដ ។ ចលនាម៉ៅជ្រុល និយមបរាជ័យក្នុងការដណ្តើមអំណាចនៅប្រទេសប៉េរូ ប៉ុន្តែ ខ្មែរក្រហមបានឡើងកាន់អំណាចនៅក្នុងប្រទេសកម្ពុជា ហើយ មធ្យោបាយរបស់ក្រុមនេះគឺបំភិតបំភ័យប្រជាជននៅតាមទី ជនបទតាមរយៈការវាយឆ្មក់និងការដាក់ពង្រាយគ្រាប់មីន ។ របបកម្ពុជាប្រជាធិបតេយ្យបានបង្កការប៉ះពាល់ផ្លូវចិត្តដល់ ប្រជាជនកម្ពុជារាប់លាននាក់ និងបានបង្កការភ័យខ្លាចជានិរន្តរ៍ ដល់គ្រប់ពលរដ្ឋកម្ពុជាទាំងអស់ ។ ប្រជាជនជាច្រើនបានស្លាប់ ដោយសារតែ ប៉ុល ពត មិនមានលទ្ធភាពដោះស្រាយការ អភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ។

នៅក្នុងរយៈពេលនៃការគ្រប់គ្រងរបស់របបកម្ពុជាប្រជា ធិបតេយ្យពីឆ្នាំ១៩៧៥ដល់១៩៧៩ យ៉ាងហោចណាស់មាន ប្រជាជន១,៧លាននាក់បានស្លាប់ដោយសារជំងឺ កង្វះខាត អាហារបរិភោគ ការធ្វើការហួសកម្លាំង និងការប្រហារជីវិត ។ របបនេះបានបំបាត់ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ កម្មសិទ្ធិឯកជន និងសាសនា ។ នៅក្នុងអត្ថបទដែលចុះផ្សាយនៅក្នុងទស្សនាវដ្តី "ថៃមស៍" ថ្ងៃទី២៩ ខែកក្កដា អាដាម ហ្សៀល បានរកឃើញថា ប៉ុលពតបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ប៉ុល ពត ជាអ្នក ចេញបញ្ជាឲ្យមានការសម្លាប់ ។ ប៉ុល ពត ត្រូវបានផ្តួលរំលំពី អំណាចដោយការវាយលុករបស់វៀតណាមនៅឆ្នាំ១៩៧៩ ។

បណ្ឌិត ណាន់ស៊ី គ្រេត ដែលមានកំណើតនៅទីក្រុង ភ្នំពេញ បាននិយាយថា "ខ្ញុំមិនដឹងថាត្រូវចាប់ផ្តើមពីកន្លែងណាទេ? ខ្ញុំមានអារម្មណ៍ថាអ្វីមួយដែលគ្រោះថ្នាក់និងមិនធ្លាប់កើតមានពី មុនមក ហៀបនឹងកើតឡើងហើយដោយក្រុមនិយមលទ្ធិម៉ៅ" ។

គាត់បាននិយាយដោយអួលដើមកទៀតថា "មិនមាន ចលនាដើម្បីសន្តិភាព"ណាមួយគាំទ្រនិងគោរពជីវិតរបស់យើង ទេ ។ ខ្ញុំមិនយល់ទាល់តែសោះហេតុអ្វីបានជាមនុស្សអាចប្រព្រឹត្ត អំពើបែបនេះចំពោះមនុស្សដូចគ្នា ។ ខ្ញុំបានឃើញមនុស្សជាច្រើន ស្លាប់យ៉ាងអណោចអធម ។ សាកសពខ្លះហើម ហើយសាកសពខ្លះ ឥតមានសម្លៀកបំពាក់និងអណ្តែតតាមទឹកទន្លេ ។ មនុស្សជាច្រើន មានអារម្មណ៍ថាស្លាប់ឆាប់ប្រសើរជាងរស់នៅដោយឈឺចាប់ នៅក្នុងសម័យនោះ" ។

បន្ទាប់ពីការធ្វើសង្គ្រាមដ៏ខ្លាំងក្លានិងបំផ្លិចបំផ្លាញមក ប៉ុល ពត បានក្លាយជានាយករដ្ឋមន្ត្រី ហើយបន្ទាប់ពីឡើងកាន់អំណាច បានតែមួយថ្ងៃប៉ុណ្ណោះ ប្រជាជនទាំងអស់នៅទូទាំងប្រទេសបាន ក្លាយជាកសិករ ។ ប្រជាជនត្រូវបានបង្ខំឲ្យចាកចេញពីទីក្រុង និងទៅរស់នៅទីជនបទ ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌល ឯកសារកម្ពុជា បានថ្លែងថា "ទាំងប្រជាជនកម្ពុជានិងពិភពលោក គួរតែសិក្សាអំពីអតីតកាលដែលពោរពេញទៅដោយសោកនាដកម្ម នេះ" ។

ដេវីដ ឆេនដល័រ សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ ម៉ូណាស និងជាអ្នកជំនាញការអន្តរជាតិអំពីប្រវត្តិសាស្ត្ររបប កម្ពុជាប្រជាធិបតេយ្យ បាននិយាយថា "ប្រជាជនជិតពីរលាននាក់ បានស្លាប់ដោយសារបាក់កម្លាំង កង្វះអាហារូបត្ថម្ភ ឬការប្រហារ ជីវិតនៅចន្លោះឆ្នាំ១៩៧៦និងឆ្នាំ១៩៧៩ ។ សមាជិកបក្ស កុម្មុយនិស្តកម្ពុជារាប់ពាន់នាក់ក៏ត្រូវសម្លាប់ដែរ" ។

នៅពេលដែលក្រុមឧទ្ទាមខ្មែរក្រហមនិយមលទ្ធិម៉ៅចូល កាន់កាប់ប្រទេសកម្ពុជា ក្រុមនេះបានបញ្ជាឲ្យប្រជាជនទាំងអស់ ធ្វើការងាររៀងរាល់ថ្ងៃគ្មានពេលសម្រាក ។ ប្រជាជនមិនដែល ទទួលបានអាហារបរិភោគគ្រប់គ្រាន់ម្តងណាឡើយ ។ ពេលខ្លះ នៅពេលប្រជាជនបដិសេធមិនព្រមធ្វើការ កងទ័ពខ្មែរក្រហមនឹង ធ្វើទារុណកម្មប្រជាជន ហើយបង្ខំឲ្យធ្វើការហួសម៉ោងកំណត់ ។ ខ្មែរក្រហមមិនបានចែកស្បែកជើងឲ្យប្រជាជនទេ ហើយថែម ទាំងប្លន់ប្រជាជនថែមទៀត ។ ខ្មែរក្រហមមិនបានបន្សល់អ្វីឲ្យ ប្រជាជនឡើយ ។ ប្រជាជនត្រូវដេកផ្ទាល់ដី និងមិនមានអាហារ បរិភោគ ។

ម៉ៃឃើល វីខឺរី បានប៉ាន់ស្មានថា ប្រជាជនប្រមាណពី៥ម៉ឺន

ទៅ៣០ម៉ឺននាក់ត្រូវបានប្រហារជីវិត ក្នុងចំនួនតួលេខប្រជាជនស្លាប់សរុបប្រមាណជាង៧៥ម៉ឺននាក់នៅក្នុងអំឡុងរយៈពេល៤ឆ្នាំនៃការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ ។ ដេវីដ ឆេនដល័រ បានប៉ាន់ស្មានថាមានការប្រហារជីវិតរហូតដល់ទៅ១០ម៉ឺននាក់ ។ អត្ថបទមួយរបស់ ហ៊ីលីព រ៉ូបឺតសឹន ស្តីអំពីកម្ពុជាដែលចេញផ្សាយនៅក្នុងទស្សនាវដ្តី «នយោបាយការបរទេស» បានផ្តល់តួរលេខអំពីចំនួនអ្នកស្លាប់សរុបពី១,៥លាននាក់ទៅ២លាននាក់ ដោយមិនគិតអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅមុនរបបកម្ពុជាប្រជាធិបតេយ្យហើយដែលបណ្តាលឲ្យមនុស្សស្លាប់ក្នុងចំនួរច្រើនដែរ ។

ការសិក្សារបស់ហ្វាំងឡង់បានប៉ាន់ស្មានថាចំនួនមនុស្សស្លាប់សរុបនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺប្រមាណ១លាននាក់ ។ បើយោងទៅតាមការសិក្សាជាច្រើន ប្រជាជនភាគច្រើនបានសម្រេចចិត្តចាកចេញពីទីក្រុងដោយការភ័យខ្លាចថាខ្មែរក្រហមនឹងចាប់ខ្លួន សម្លាប់ប្រជាជន ឬបង្ខំឲ្យប្រជាជនទៅតស៊ូជាមួយក្រុមខ្លួននៅក្នុងព្រៃ និងប្រើប្រាស់ប្រជាជនទាំងនេះដើម្បីការពារក្រុមខ្លួន ។

ឌិត ប្រន អ្នកកាសែតជនជាតិកម្ពុជា និងជាអ្នកថតរូបឲ្យកាសែត «ញូវយ៉កថែមស៍» ដែលស្ទើរតែបាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បាននិយាយថា «បុរស ស្ត្រី និងកុមារដែលត្រូវបានមើលឃើញថាជាការគំរាមកំហែងឬបដិសេធមិនគោរពតាមបញ្ជារបស់អង្គការ ត្រូវបានសម្លាប់» ។

នៅពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ ខ្មែរក្រហមបានបែកបាក់ដោយសារជម្លោះផ្ទៃក្នុង ហើយនៅឆ្នាំ១៩៩២បេសកកម្មអង្គការសហប្រជាជាតិបានចុះឈ្មោះប្រជាជនដែលអាចបោះឆ្នោតបានចំនួន៤,៦លាននាក់ ។ នៅឆ្នាំដដែល សម្តេចព្រះបាទនរោត្តម សីហនុ បានថ្កោលទោសខ្មែរក្រហម ហើយនៅឆ្នាំ១៩៩៣ខ្មែរក្រហមបានដកខ្លួនចេញពីកិច្ចចារសន្តិភាព ធ្វើពហិការមិនចូលរួមការបោះឆ្នោតជាតិ និងត្រឡប់ទៅរកការតស៊ូក្នុងព្រៃរបស់ខ្លួនជាបន្ត ។ សម្តេច នរោត្តម សីហនុ ទទួលបានជ័យជម្នះនៅក្នុងការបោះឆ្នោត ។ រដ្ឋធម្មនុញ្ញថ្មីបានបង្កើតរបបរាជាធិបតេយ្យម្តងទៀត ហើយសម្តេច នរោត្តម សីហនុ បានឡើងគ្រងរាជ្យសាជាថ្មី ។ ប្រជាជនបានអះអាងថា «អង្គការសហប្រជាជាតិគួរតែរកឲ្យឃើញ ចាប់ខ្លួន និងនាំទៅកាន់តុលាការនូវអ្នកដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងប្រទេសកម្ពុជា» ។

ម្យ៉ាងវិញទៀត នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ក្រុម «គន្លងចិញ្ចាចចិញ្ចែង» បានតស៊ូប្រដាប់អាវុធប្រឆាំងនឹងរដ្ឋាភិបាលប៉េរូ ដើម្បីគាំទ្រមនោគមវិជ្ជាបែបម៉ៅនិយមជ្រុល ។ ជនជាតិប៉េរូប្រមាណ៣ម៉ឺននាក់បានស្លាប់នៅក្នុងជម្លោះ ។ ជនជាតិប៉េរូមានការភ័យខ្លាចអំពើហិង្សាជាពិសេស ។ អង្គការ «គន្លងចិញ្ចាចចិញ្ចែង» និយមម៉ៅត្រូវបានបង្កើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០និងដើមទសវត្សរ៍ឆ្នាំ១៩៩០ ការវាយប្រហារភេរវកម្មជាច្រើនបានកើតឡើងជារៀងរាល់ថ្ងៃនៅទូទាំងប្រទេសប៉េរូ ដែលបង្កឡើងដោយអង្គការ «គន្លងចិញ្ចាចចិញ្ចែង» ។ ប៉ុន្តែអង្គការនេះបានដួលរលំបន្ទាប់ពីហ្គូសម៉ាន ដែលមេដឹកនាំរបស់អង្គការនេះ ត្រូវចាប់ខ្លួននៅខែកញ្ញា ឆ្នាំ១៩៩២ ។ កាលពីអតីតកាល ស្ទើរតែគ្រប់ស្ថាប័នទាំងអស់នៅក្នុងប្រទេសប៉េរូសុទ្ធតែជាមុខសញ្ញានៃការប្រើប្រាស់អំពើហិង្សារបស់អង្គការ «គន្លងចិញ្ចាចចិញ្ចែង» ។

ភាគច្រើននៃជនរងគ្រោះជាជនជាតិប៉េរូ ។ បន្ទាប់ពីការបង្ហូរឈាមជាបន្តបន្ទាប់នៅឆ្នាំ១៩៨៦ នៅឆ្នាំ១៩៩១អង្គការ «គន្លងចិញ្ចាចចិញ្ចែង» បានបង្កអំពើហិង្សានៅក្នុងទីប្រជុំជននៃទីក្រុងធំៗរបស់ប្រទេស ។ អតីតនាយករដ្ឋមន្ត្រីប្រទេសប៉េរូ លោក ហ្វូជិ ម៉ូរិ បានបើកយុទ្ធនាការហិង្សាមួយប្រឆាំងនឹងអង្គការ «គន្លងចិញ្ចាចចិញ្ចែង» និងអង្គការ «ទូប៉ាក់អាម៉ារូ» ។ លោក ហ្វូជិ ម៉ូរិ បានចាប់ខ្លួនមេដឹកនាំជាច្រើននៃក្រុមខ្មាំងទាំងនេះ ហើយអំពើហិង្សាបានថយចុះយ៉ាងច្រើន ។ ប្រជាជនប៉េរូរាប់ពាន់នាក់ត្រូវបានចោទប្រកាន់និងកាត់ទោសពីបទទាក់ទងនឹងអំពើភេរវកម្ម ។ មានការជឿជាក់ថា ចាប់តាំងពីការបង្ក្រាបរបស់លោក ហ្វូជិ ម៉ូរិ អំពើហិង្សាលែងជាបញ្ហាទៀតហើយនៅក្នុងប្រទេសប៉េរូ ។

សង្គ្រាមរបស់ក្រុមនិយមលទ្ធិម៉ៅបានបណ្តាលឲ្យបាត់បង់អាយុជីវិតរបស់ប្រជាជនរាប់សិបនាក់ ប្រជាជនមួយចំនួនមានវិបត្តិស្មារតី និងមួយចំនួនទៀតមានបញ្ហាជីវភាពដោយសារតែ

ប្ដីរបស់ខ្លួនបានបាត់បង់ជីវិត ។ ក្រុមទាំងនេះជាក្រុមដែលបង្កអំពើហិង្សាធ្ងន់ធ្ងរបំផុតនៅប្រទេសប៉េរូ និងបានសម្លាប់រង្គាលប្រជាជនទាំងឡាយណាដែលត្រូវបានសង្ស័យថាចូលដៃជើងជាមួយរដ្ឋាភិបាល ។ ប្រជាជនជាច្រើនត្រូវបានវាយសម្លាប់ ឬសម្លាប់ដោយគប់នឹងដុំថ្ម ហើយកុមារខ្លះត្រូវបានកាត់ស្លឹកត្រចៀក ។ អង្គការនិយមម៉ៅទាំងនេះបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ បំផ្ទុះគ្រាប់បែក និងសម្លាប់មនុស្ស ។ ការខូចខាតដោយសារសង្គ្រាមនៅក្នុងប្រទេសប៉េរូមានតម្លៃ២២ពាន់លានដុល្លារ ។

មកទល់នឹងឆ្នាំ១៩៩៤ អង្គការ "គន្លងចិញ្ចាចចញ្ចែង" បានបាត់បង់កម្លាំងភាគច្រើនរបស់ខ្លួន ហើយជនភៀសខ្លួនជាង៨ម៉ឺននាក់បានវិលត្រឡប់ទៅផ្ទះសម្បែងរបស់ខ្លួនវិញ ។ នៅចន្លោះឆ្នាំ១៩៩៥ដល់ឆ្នាំ២០០០ អង្គការ "គន្លងចិញ្ចាចចញ្ចែង" បានកាត់បន្ថយអំពើហិង្សាមកនៅត្រឹមកម្រិតអប្បរមានៅក្នុងតំបន់ភាគច្រើន លើកលែងតែតំបន់អាម៉ាហ្សូននៃប្រទេសប៉េរូ ជាកន្លែងដែលក្រុមខ្ទាម"គន្លងចិញ្ចាចចញ្ចែង"ដែលនៅសេសសល់នៅបន្តបំភិតបំភ័យជនជាតិដើមម្ចាស់ស្រុក និងបានបណ្ដាលឲ្យជនស៊ីវិលខ្លះចាកចោលផ្ទះសម្បែង ។ អង្គការ "មេសាណាស្ប៉ូណាល់ ស៊ូប ឌីសផ្លេសហ្សាមៀនតូ" ដែលជាសហគមន៍នៃអង្គការមិនមែនរដ្ឋាភិបាល បានឲ្យដឹងថា ជម្លោះបានបណ្ដាលឲ្យប្រជាជនចំនួន៤៣ម៉ឺននាក់បោះបង់ចោលផ្ទះសម្បែងរបស់ខ្លួន ប៉ុន្តែឥទ្ធិពលរបស់ជម្លោះនេះបានប៉ះពាល់ដល់ប្រជាជនច្រើនជាង១,៦លាននាក់ ។ ប្រជាជន៦ម៉ឺននាក់នៅតែជាអ្នកចាកចោលផ្ទះសម្បែង ។ ជនជាតិប៉េរូរាប់សែននាក់បានរត់គេចចេញពីផ្ទះរបស់ខ្លួននៅទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០ ។ ប្រជាជនទាំងនេះបានរត់គេចចេញពីការវាយប្រហារដោយអំពើហិង្សា ។ ឥឡូវនេះ ជនជាតិប៉េរូបានថ្កោលទោសអំពើភេរវកម្ម ហើយប្ដេជ្ញាប្រយុទ្ធជាមួយសកម្មភាពភេរវកម្ម ។

ការសម្លាប់រង្គាលប្រជាជនគឺពិតជាគ្មានអ្វីចម្លែកទេសម្រាប់លទ្ធិម៉ៅនិយម ។ កម្ពុជានិងប៉េរូជារាជាណាចក្រពីរដែលទទួលរងនូវការបំផ្លិចបំផ្លាញដោយលទ្ធិម៉ៅនិយម ។ មិនមានការដោះសារនយោបាយណាមួយទេចំពោះអំពើហិង្សា ។

**ខាមីឡា សារុព**

## សេចក្ដីប្រកាសរកកូនស្រីឈ្មោះ អ៊ូច សាវឿន

នាងខ្ញុំឈ្មោះ ចាន់ សៀម អាយុ៥៧ឆ្នាំ សព្វថ្ងៃរស់នៅភូមិជីប្រាប ឃុំសន្លុង ស្រុកទ្រាំង ខេត្តតាកែវ ។ នាងខ្ញុំសូមសួររកកូនស្រីឈ្មោះ អ៊ូច សាវឿន ហៅ យឿន ដែលបានចូលបម្រើបដិវត្តន៍នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៤ ។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យឿន បម្រើការងារក្នុងកងនារីសែងអ្នករបួសនៅវត្តអង្គកែវ ឃុំអង្គកែវ ស្រុកទ្រាំង ខេត្តតាកែវ ។ នៅឆ្នាំ១៩៧៦ យឿន បានផ្ញើសំបុត្រមកផ្ទះប្រាប់ថាធ្វើពេទ្យនៅភ្នំពេញ ។ ប្រហែល៩ឆ្នាំមុន យឿន ផ្ញើសំបុត្រមកភូមិកំណើតម្ដងទៀត ប្រាប់ថារស់នៅខេត្តពោធិសាត់ ។ នាងខ្ញុំបានឲ្យកូនប្រុសទៅរក ប៉ុន្តែរកមិនឃើញ ។ តាំងពីពេលនោះមកក៏បាត់ដំណឹង យឿន រហូត ។ បើគិតមកដល់បច្ចុប្បន្ន យឿន មានអាយុប្រហែល៤០ឆ្នាំ ។

ប្រសិនបើ យឿន បានឃើញសេចក្ដីប្រកាសនេះ ឬបងប្អូនណាបានដឹងដំណឹងរបស់ យឿន សូមមេត្តាទាក់ទងនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

## សេចក្ដីប្រកាសរកបងស្រីឈ្មោះ យេន

នាងខ្ញុំឈ្មោះ ជា យ៉ន អាយុ៤២ឆ្នាំ រស់នៅភូមិបន្ទាយយមរាជ ឃុំប្រាសាទ ស្រុកសន្ទុក ខេត្តកំពង់ធំ សូមសួររកបងស្រីឈ្មោះ យេន ហៅ រ៉េត ដែលបាត់ខ្លួនក្នុងឆ្នាំ១៩៧៩ ។ នៅក្នុងរបបខ្មែរក្រហម យេន ធ្វើការងារនៅទីក្រុងភ្នំពេញ ។

កាលពីឆ្នាំ១៩៨២ ខ្ញុំបានទទួលដំណឹងថា យេន បានផ្ញើសំបុត្រមួយមកដល់សាលាស្រុកសន្ទុក ។ កាលនោះយោធាស្រុកម្នាក់ដែលមិនស្គាល់ឈ្មោះ បានមកប្រាប់ យាយលន់ អ្នកភូមិយមរាជថាមានសំបុត្រពីឈ្មោះ យេន សួររកបងប្អូន ។ ក្រោយមកខ្ញុំបានទៅរកសំបុត្រនោះតាមរយៈឈ្មោះ តាស្រ៊ី ដែលជាមន្ត្រីមន្ទីរសង្គមកិច្ចស្រុកសន្ទុក ប៉ុន្តែរកមិនឃើញ ។

ប្រសិនបើ យឿន បានឃើញសេចក្ដីប្រកាសនេះ ឬបងប្អូនណាបានដឹងដំណឹងរបស់ យឿន សូមមេត្តាទាក់ទងនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# បួនចំណុចដែលអង្គជំនុំជម្រះវិសាមញ្ញនៅប្រទេសកម្ពុជាអាចរៀនសូត្រពីសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា

នៅក្នុងប្រទេសដែលខ្ទេចខ្ទាំដោយកេរដំណែលនៃរបបគ្រប់គ្រងផ្តាច់ការដ៏ឃោរឃៅ អំពើពុករលួយនយោបាយ និងអំពើរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ កិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយអតីតកាលរបស់កម្ពុជាឲ្យមានប្រសិទ្ធិភាពហាក់បីដូចជាពុំមានទីបញ្ចប់ទាល់តែសោះ ។ កិច្ចខិតខំប្រឹងប្រែងផ្សេងៗដើម្បីនាំយកខ្មែរក្រហមទៅកាន់តុលាការឥឡូវនេះបានចំណាយពេលវេលាអស់ជាងមួយភាគបួនសតវត្សរ៍ទៅហើយ ។ សូម្បីតែការចរចាថ្មីៗបំផុតនេះដើម្បីបង្កើតសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិ ក៏បានជួបប្រទះនឹងការមិនសប្បាយចិត្ត ការអូសបន្លាយពេល និងភាពច័លច្រក ។ ទោះបីជាមានការគំរាមកំហែងក៏ដោយ ក៏ស្ថិរភាពសន្តិភាពនិងយុត្តិធម៌ប្រហែលជាអាចសម្រេចបាននៅពេលអនាគត ។ បន្ទាប់ពីការចរចាដែលអូសបន្លាយពេលវេលាអស់រយៈពេល៦ឆ្នាំ នៅទីបំផុតរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានរៀបចំរួចជាស្រេចដើម្បីដោះស្រាយអតីតកាលនិងត្រួសត្រាយផ្លូវសម្រាប់អនាគតរបស់កម្ពុជា ។

នៅក្នុងអំឡុងពេលចរចាដ៏យូររវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា (ICTR) ដំណើរការបានពាក់កណ្តាលទៅហើយនៅក្នុងទីក្រុងអារូហ្សា (ប្រទេសតង់ហ្សានី) ។ នៅពេលដែលសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដាព្យាយាមស្វែងរកយុត្តិធម៌ឲ្យប្រជាជននៅក្នុងតំបន់ សាលាជំនុំជម្រះក្តីនេះទទួលបាននូវការរិះគន់ដ៏ច្រើនសន្ធឹកសន្ធាប់ជុំវិញការចំណាយនិងកង្វះខាតប្រសិទ្ធភាព ។ នេះមិនមែនជារឿងចួនគ្នាទេដែលអ្នកគាំទ្រអន្តរជាតិបានទទូចថាកម្ពុជាត្រូវតែបង្កើតសាលាជំនុំជម្រះក្តីមួយដែលមានភាពរលូន មិនការិយាធិបតេយ្យ និងដែលអាចស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាបាន ។ អង្គជំនុំជម្រះវិសាមញ្ញនៅប្រទេសកម្ពុជានឹងមិនទទួលបាននូវពេលវេលានិងធនធានដូចសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដាទេ ។

អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជាទទួលបានការឧបត្ថម្ភពីអង្គការសហប្រជាជាតិ ។ គុណវិបត្តិនៃការចងក្រងឯកសារដែលញាំញីសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដានឹងផ្តល់ជាមេរៀនដ៏មានតម្លៃសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅប្រទេសកម្ពុជា ។ តាមរយៈការយកចិត្តទុកដាក់លើកំហុសរបស់សាលាជំនុំជម្រះក្តីសម្រាប់ប្រទេសរ្វ៉ាន់ដានៅទីក្រុងអារូហ្សា អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជានឹងប្រាកដជាអាចរៀបចំដំណើរការរបស់ខ្លួនបានល្អប្រសើរជាងសាលាជំនុំជម្រះក្តីអន្តរជាតិមុនៗក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា និងដើម្បីធ្វើជាគំរូមួយសម្រាប់ពិភពលោក ។

ខណៈដែលសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដាទទួលបាននូវបទពិសោធន៍ថ្មី ជោគជ័យរបស់សាលាជំនុំជម្រះក្តីដែលមានអាយុ១១ឆ្នាំនេះភាគច្រើនត្រូវបាំងបាត់ដោយការលំបាកនៅពេលចាប់ផ្តើមដំបូងនៃសាលាជំនុំជម្រះក្តីនេះ ។ មានបញ្ហាមួយចំនួនដែលញាំញីសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា ហើយដែលអង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជាត្រូវតែចៀសវាងឲ្យបានប្រសិនបើចង់ឲ្យដំណើរការរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព ។ ទីមួយ តាំងពីដំបូងម្ល៉េះ សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដាត្រូវញាំញីដោយទំនាក់ទំនងមិនល្អរវាងរដ្ឋាភិបាលក្នុងស្រុកនិងសហគមន៍អន្តរជាតិ ។ ទីពីរ ការចំណាយជ្រុលហួសហេតុនិងការមិនទទួលខុសត្រូវលើហិរញ្ញវត្ថុបានរារាំងលទ្ធភាពនៃការស្វែងរកយុត្តិធម៌របស់សាលាជំនុំជម្រះក្តី ។ ទីបី ការអូសបន្លាយពេលវេលានៃនីតិវិធីបានរារាំងប្រសិទ្ធភាពនៃសាលាជំនុំជម្រះក្តីក្នុងការចេញសេចក្តីសម្រេចនិងសាលក្រម ។ ទីបួន សាលាជំនុំជម្រះក្តីនេះមានទីតាំងនៅក្រៅប្រទេសរ្វ៉ាន់ដា ដែលបញ្ហានេះបានបង្កជាការអូសបន្លាយពេលវេលា និងបានបន្ថយឥទ្ធិពល

នៃដំណើរការសាលាជំនុំជម្រះក្តីនេះទៅលើជីវភាពប្រចាំថ្ងៃរបស់ប្រជាជនរ៉្វាន់ដា ។

តាមរយៈការមើលឃើញភាពទន់ខ្សោយរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជាប្រាកដជាអាចរៀបចំដំណើរការរបស់ខ្លួនបានល្អប្រសើរក្នុងការដោះស្រាយកិច្ចការរបស់ខ្លួនដែលកំពុងតែរង់ចាំ ។ លទ្ធភាពនៃការស្វែងរកយុត្តិធម៌និងបង្កើតការទទួលខុសត្រូវពឹងផ្អែកទាំងស្រុងទៅលើប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

### ១) ទំនាក់ទំនងទន់ខ្សោយរវាងរដ្ឋាភិបាលជាតិនិងសហគមន៍អន្តរជាតិ

***រ៉្វាន់ដាៈ*** ទំនាក់ទំនងរវាងរដ្ឋាភិបាលរ៉្វាន់ដានិងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិគឺជាកិច្ចការដែលគ្មាននរណាយកចិត្តទុកដាក់ ។ បើទោះបីជារដ្ឋាភិបាលរ៉្វាន់ដាគាំទ្រការបង្កើតសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាក៏ដោយ ក៏រដ្ឋាភិបាលនេះមិនយល់ស្របចំពោះទិដ្ឋភាពមួយចំនួនរបស់សាលាជំនុំជម្រះក្តីនេះដែរ ។ អង្គការសហប្រជាជាតិខកខានមិនបានដោះស្រាយការព្រួយបារម្ភរបស់រដ្ឋាភិបាលរ៉្វាន់ដាទាក់ទងនឹងទីតាំងរបស់សាលាជំនុំជម្រះក្តី យុត្តាធិការនៃពេលវេលា និងការហាមឃាត់ទោសប្រហារជីវិត ។ បន្ថែមទៅលើកង្វះខាតដែលបានលើកឡើងខាងលើ ក្នុងនាមជាសាលាជំនុំជម្រះក្តីអន្តរជាតិសុទ្ធសាធ សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាមិនមានឥទ្ធិពលដោយផ្ទាល់ទៅលើវិជ្ជាជីវៈផ្នែកច្បាប់របស់ពលរដ្ឋរ៉្វាន់ដាទេ ។ ប្រព័ន្ធយុត្តិធម៌ជាតិរបស់រ៉្វាន់ដានឹងមិនទទួលបានផលប្រយោជន៍ច្រើនប៉ុន្មានទេបន្ទាប់ពីសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិមួយនេះបញ្ចប់ដំណើរការរបស់ខ្លួន ។

***កម្ពុជាៈ*** ផ្ទុយទៅវិញ អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជាគឺជាលទ្ធផលនៃការចរចារវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ មុនដំបូង អង្គការសហប្រជាជាតិស្វះស្វែងដើម្បីបង្កើតសាលាជំនុំជម្រះក្តីដែលគ្រប់គ្រងដោយអន្តរជាតិនៅក្នុងប្រទេសជិតខាងរបស់កម្ពុជា ។ នៅពេលសម្រុះសម្រួលអ្វីដែលអង្គការសហប្រជាជាតិព្យាយាមស្វះស្វែងរក គំរូចម្រុះមួយនឹងត្រូវបង្កើតឡើងដោយមានការចូលរួមពីប្រទេសម្ចាស់ផ្ទះ ។ នៅក្នុងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាមិនមានការអនុវត្តរបៀបនេះទេ ។ នៅទីបញ្ចប់ អង្គជំនុំជម្រះវិសាមញ្ញនឹងជួយបំពាក់បំប៉នជំនាញវិជ្ជាជីវៈដល់ចៅក្រមនិងមេធាវីកម្ពុជាដែលនឹងចូលរួមនៅក្នុងដំណើរការជំនុំជម្រះ និងជួយកាត់បន្ថយចំណុចខ្វះខាតនៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ។

### ២) ការចំណាយជ្រុលហួសហេតុ និងការគ្រប់គ្រងហិរញ្ញវត្ថុមិនត្រឹមត្រូវ

***រ៉្វាន់ដាៈ*** ការរិះគន់អំពីការចំណាយយ៉ាងចម្លែករបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានក្លាយទៅជាមេរៀនដ៏មានតម្លៃសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជា ។ នៅទីក្រុងអារូហ្សា អង្គការសហប្រជាជាតិទទួលខុសត្រូវក្នុងការសាងសង់អគារសម្រាប់សវនាការ ការិយាល័យមន្ទីរឃុំឃាំង និងអគារសម្រាប់ស្នាក់នៅ ។ ការចំណាយដ៏ច្រើនទៅលើការសាងសង់រចនាសម្ព័ន្ធចាំបាច់ និងការគ្រប់គ្រងមិនត្រឹមត្រូវ បានចំណាយអស់ថវិកាសម្រាប់ដំណើរការរយៈពេលពីរឆ្នាំដំបូងរបស់សាលាជំនុំជម្រះក្តីនេះ ។ អ្នកធ្វើអធិការកិច្ចហិរញ្ញវត្ថុមកពីអង្គការសហប្រជាជាតិដែលត្រួតពិនិត្យមើលការចំណាយរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញថា សាលាជំនុំជម្រះក្តីនេះមិនមានប្រព័ន្ធគណនេយ្យ ហើយជាលទ្ធផល មិនអាចផលិតឯកសារហិរញ្ញវត្ថុបត់មាននៃការចំណាយទេ ។ សហគមន៍អន្តរជាតិនឹងមិនអាចអត់ធ្មត់ដូចនៅក្នុងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាទេប្រសិនបើថវិការបស់ខ្លួនត្រូវចាយខ្ជះខ្ជាយនៅទីក្រុងភ្នំពេញ ។

***កម្ពុជាៈ*** សាលាជំនុំជម្រះក្តីនៅកម្ពុជាត្រូវតែមានប្រសិទ្ធភាពខ្ពស់ដើម្បីឲ្យសាលាជំនុំជម្រះក្តីនេះអាចមានអត្ថិភាពទៅតាមចំនួនថវិកាដែលប៉ាន់ស្មាន ។ កត្តាជាគន្លឹះពីរនឹងជួយអង្គជំនុំជម្រះវិសាមញ្ញឲ្យគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ខ្លួនបានល្អ ។ ទីមួយ ហិរញ្ញវត្ថុតិចតួចប៉ុណ្ណោះដែលនឹងត្រូវចំណាយសម្រាប់ការសាងសង់អគារផ្សេងៗ ។ ខុសគ្នាពីសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាដែលចាំបាច់ត្រូវសាងសង់ឡើងទាំងស្រុងភាគច្រើននៃអគារសម្រាប់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ

នៅកម្ពុជាមានរួចជាស្រេច ។ ទីពីរ ខណៈពេលដែលភាពអសកម្ម និងការចំណាយហិរញ្ញវត្ថុញាំញីសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដា អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជានឹងត្រូវគ្រប់គ្រងដោយថវិកានិងអាណត្តិមានកំណត់នៃប្រតិបត្តិការ ។ ការដាក់កម្រិតលើខ្លួនឯងនូវថវិកានិងអាណត្តិនឹងជួយសម្រួលដល់អង្គជំនុំជម្រះវិសាមញ្ញមួយនេះឲ្យមានប្រសិទ្ធិភាពជាងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដា ។

## ៣) កង្វះប្រសិទ្ធភាព និងការអូសបន្លាយពេលវេលានៃនីតិវិធី

**វ៉ាន់ដា:** នៅពេលចាប់ផ្តើម សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដាមានការលំបាកជាខ្លាំងក្នុងការស្វែងរកយុត្តិធម៌ ។ ដោយសារតែសាលាជំនុំជម្រះក្តីអន្តរជាតិប្រភេទនេះទើបតែកើតឡើងជាលើកដំបូង តាមច្បាប់ សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដាត្រូវតែបង្កើតអង្គការច្បាប់មួយដើម្បីដោះស្រាយបញ្ហានីតិវិធីដែលកើតឡើង ។ ភាពចន្លោះប្រហោងនៅក្នុងច្បាប់នីតិវិធីបាននាំទៅដល់ការបង្កើតសវនាការតូចៗនៅក្នុងសវនាការព្រហ្មទណ្ឌ ។ ដោយសារតែគ្មានសាលាជំនុំជម្រះក្តីប្រភេទនេះពីមុនមក សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិវ៉ាន់ដាត្រូវតែបង្កើតក្រមនីតិវិធីព្រហ្មទណ្ឌសម្រាប់ខ្លួនឯង ។ កាន់តែលំបាកជាងនេះទៅទៀត សាលាជំនុំជម្រះក្តីនេះមានការលំបាកក្នុងការកោះហៅសាក្សីដែលត្រូវធ្វើដំណើរក្នុងចម្ងាយផ្លូវឆ្ងាយពីវ៉ាន់ដាមកតុលាការ ។ នៅពេលធ្វើដំណើរទៅដល់ទីក្រុងអារូហ្សាហើយ អ្វីៗក៏មិនដំណើរការដោយស្រួលដែរ ដោយសារឧបសគ្គភាសារវាងសាក្សី ចៅក្រម និងមេធាវី នេះបើគិតត្រឹមតែបញ្ហានៅក្នុងការស្វែងរកយុត្តិធម៌ ។

**កម្ពុជា:** វិធានការមួយចំនួននឹងជួយសម្រួលសាលាជំនុំជម្រះក្តីនៅកម្ពុជាដើម្បីចៀសវាងការអូសបន្លាយពេលវេលានៃនីតិវិធីដែលធ្លាប់ជួបប្រទះនៅឯសាលាជំនុំជម្រះក្តីអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដា ។ ទីមួយ អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជានឹងពឹងផ្អែកច្រើនទៅលើប្រព័ន្ធយុត្តិធម៌ដែលមានស្រាប់របស់កម្ពុជាដើម្បីអនុវត្តច្បាប់នីតិវិធី ។ នៅពេលដែលមានការខ្វះចន្លោះ នីតិវិធីអន្តរជាតិនឹងចូលមកបំពេញ ។ អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជាក៏នឹងអាចពឹងផ្អែកទៅលើច្បាប់ដែលបង្កើតដោយសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិវ៉ាន់ដាដែរ ។ ទីពីរ ភាសាខ្មែរគឺជាភាសាផ្លូវការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ។ ថ្វីដ្បិតតែការបកប្រែគឺជាតម្រូវការចាំបាច់មិនអាចចៀសវាងបាន ប៉ុន្តែឧបសគ្គនៃការប្រើប្រាស់ភាសានឹងមិនសូវមានដូចនៅវ៉ាន់ដាទេ ដោយសារតែវត្តមានរបស់ចៅក្រមកម្ពុជានៅក្នុងចំណោមចៅក្រមជំនុំជម្រះ ។

## ៤) ទីតាំងដ៏ឆ្ងាយនៃសាលាជម្រះក្តី

**វ៉ាន់ដា:** ការរិះគន់ផ្សេងទៀតចំពោះសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដាគឺការលំបាកផ្នែកភ័ស្តុភារ ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធានាឲ្យបាននូវភាពមិនលម្អៀង សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដាបានដាក់ទីតាំងរបស់ខ្លួននៅក្នុងទីក្រុងអារូហ្សា ។ ទោះជាយ៉ាងណាក៏ដោយ ទីតាំងដ៏ឆ្ងាយនេះបានបង្កទៅជាបញ្ហាភ័ស្តុភារនិងសេដ្ឋកិច្ច ។ ការចំណាយនិងការអូសបន្លាយពេលវេលានៃការធ្វើដំណើរដើម្បីទៅទីក្រុងអារូហ្សាជាបន្ទុកបន្ថែមទៅលើការចំណាយរបស់សាលាជំនុំជម្រះក្តី ។ អ្វីដែលសំខាន់នោះប្រហែលជាការណ៍ដែលថា ប្រជាជនវ៉ាន់ដាមិនបានចូលរួមដោយផ្ទាល់នៅក្នុងសវនាការជំនុំជម្រះ ។ ដោយសារតែសាលាជំនុំជម្រះក្តីមានទីតាំងនៅក្នុងប្រទេសផ្សេង ប្រជាជនវ៉ាន់ដាភាគច្រើនត្រូវតែពឹងផ្អែកទាំងស្រុងទៅលើប្រព័ន្ធផ្សព្វផ្សាយឬប្រភពដែលមិនសូវទុកចិត្តបានដើម្បីទទួលពត៌មានអំពីសាលាជំនុំជម្រះក្តី ។

**កម្ពុជា:** ផ្ទុយមកវិញ អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជានឹងមានទីតាំងនៅក្នុងទីក្រុងភ្នំពេញរបស់ប្រទេសកម្ពុជា ។ ទីតាំងនេះនឹងអាចជួយកាត់បន្ថយដល់បញ្ហាស្មុគ្រស្មាញសំខាន់ៗដែលសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសវ៉ាន់ដាជួបប្រទះរួចហើយ ។ ការចំណាយនិងពេលវេលានៃការធ្វើដំណើរទៅចូលរួមស្តាប់សវនាការក៏មិនមែនជាឧបសគ្គសម្រាប់ប្រជាជនកម្ពុជាដែរ ។ ដែលកាន់តែសំខាន់ជាងនេះទៅទៀតប្រហែលជាការណ៍ដែលសាធារណជនតាមដានសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញជារៀងរាល់ថ្ងៃ ។ ជនរងគ្រោះ ជនដៃដល់ និងប្រជាពលរដ្ឋ នឹងបានមើលឃើញអំពីកិច្ចការរបស់តុលាការដូចគ្នា ។

តម្លាភាពរបស់អង្គជំនុំជម្រះវិសាមញ្ញនិងការចូលរួមដ៏ច្រើនរបស់សាធារណជននឹងជួយធានាឲ្យសាលាជំនុំជម្រះក្តីនេះមានភាពស្មោះត្រង់ ។

**កិច្ចការនៅចំពោះមុខ**

ពាក្យថា អង្គជំនុំជម្រះវិសាមញ្ញគឺជាការសម្រុះសម្រួលនៃភាពមិនចុះសម្រុងគ្នារវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាដែលឥឡូវនេះឈានដល់ការព្រមព្រៀងគ្នាហើយ ។ "ខ"មួយចំនួនរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងជួយធានាឲ្យមានការចាប់ផ្តើមមួយដែលងាយស្រួលជាងសាលាជំនុំជម្រះក្តីនៅទីក្រុងអារូហ្សា ។ ប្រជាពលរដ្ឋកម្ពុជាបានរង់ចាំយុត្តិធម៌អស់រយៈពេលគ្រប់គ្រាន់ហើយ ។ សម្រាប់មនុស្សភាគច្រើន យុត្តិធម៌នេះប្រហែលជាកើតឡើងយឺតយ៉ាវពេក ប៉ុន្តែអ្វីដែលធ្លាប់ជាក្តីសង្ឃឹមដែលនៅឆ្ងាយ នៅទីបំផុតអាចសម្រេចបានហើយ ។ ពេលវេលាមានសារសំខាន់ខ្លាំងណាស់ ហើយជូនកាលឱកាសអាចកន្លងផុតទៅវិញក៏មាន ។ បើនិយាយអំពីយុត្តិធម៌ កម្ពុជាមិនអាចរង់ចាំតទៅទៀតបានទេ ដោយសារតែមេដឹកនាំខ្មែរក្រហមដែលនៅសេសសល់មានអាយុកាន់តែច្រើនណាស់ហើយ ។

**សាយមិន អ៊ូ ខននែល**

## វិវឌ្ឍន៍ថ្មីៗជុំវិញបញ្ហាថវិកាសម្រាប់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ

***ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៤*** ៖ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាកំណត់ថវិកាប៉ាន់ស្មានទុកជាមុនចំនួនហាសិបប្រាំមួយលានពីរសែនប្រាំពីរម៉ឺនពីរពាន់ (៥៦.២៧២) លានដុល្លារ សម្រាប់ដំណើរការរយៈពេល៣ឆ្នាំរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

***ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥*** ៖ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថាខ្លួនអាចឧបត្ថម្ភតែថវិកាចំនួនមួយលានប្រាំសែនដុល្លារនៃថវិកាដប់បីលានបីសែនដុល្លារដែលការទទួលខុសត្រូវរបស់ខ្លួនប៉ុណ្ណោះ ។ បើតាមប្រសាសន៍របស់ឯកឧត្តម ឪម យិនទៀង ទីប្រឹក្សាជាន់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ការឧបត្ថម្ភរបស់រាជរដ្ឋាភិបាលកម្ពុជាតាមពិតគឺប្រាំមួយលានប្រាំពីរសែនដុល្លារ បើគិតទាំងសាច់ប្រាក់និងការឧបត្ថម្ភលើការចំណាយផ្សេងៗទៀតដូចជាអគារនិងសន្តិសុខជាដើម ។

***ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៥*** ៖ នៅក្នុងសន្និសីទវិរអង្គាសថវិកានៅទីស្នាក់ការកណ្តាលនៅទីក្រុងញូវយ៉ក អង្គការសហប្រជាជាតិប្រមូលថវិកាបានសាមសិបប្រាំបីលានបួនសែនប្រាំបីម៉ឺន (៣៨,៤៨) ដុល្លារពីប្រទេសចំនួនដប់បីសម្រាប់ឧបត្ថម្ភដល់ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

***ថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៥*** ៖ ប្រទេសបែលហ្ស៊ិកបានប្រកាសឧបត្ថម្ភថវិកាមួយសែនប្រាំបួនម៉ឺនបីពាន់ប្រាំរយ (១៩៣.៥០០) ដុល្លារដល់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

***ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥*** ៖ សហគមន៍អឺរ៉ុបឧបត្ថម្ភថវិកាមួយលានបីសែនដុល្លារដល់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

***ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥*** ៖ «កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» ចូលជាធរមាន ។ សេចក្តីថ្លែងការណ៍មួយរបស់អង្គការសហប្រជាជាតិនៅថ្ងៃដដែលនេះបានប្រកាសថា ថវិកាដែលប្រទេសសមាជិកបានសន្យាផ្គត់ផ្គង់ដល់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញឥឡូវនេះមានគ្រប់គ្រាន់ ។

***ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០០៥*** ៖ ប្រទេសបារាំងបានប្រកាសថានឹងរៀបចំថវិកាចំនួនមួយលានបីសែនដុល្លារបន្ថែមទៀតសម្រាប់ឧបត្ថម្ភដល់អង្គជំនុំជម្រះវិសាមញ្ញនៅឆ្នាំ២០០៦ ។

**សរសេរដោយ ឌី ឫទ្ធិ**

អ្នកទោសនៅមន្ទីរស-២១



# ការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា

**(តពីលេខមុន)**

## ជំពូក៣

## ការអប់រំអំពីសន្តិភាពនៅក្នុងសង្គមដែលបាក់បែក

ដូចដែលបានលើកឡើងនៅក្នុងជំពូកមុន ការអប់រំអំពីសន្តិភាពអាចត្រូវបានបង្រៀននៅក្នុងមុខវិជ្ជាផ្សេងៗ និងផ្តល់អត្ថប្រយោជន៍ជាច្រើន។ នៅទីនេះ យើងនឹងក្រឡេកមើលទៅការអប់រំអំពីសន្តិភាពនៅក្នុងប្រទេសផ្សេងទៀតដែលបាក់បែក និងបន្ទាប់ពីបញ្ចប់សង្គ្រាម ។

### ១) រ៉្វាន់ដា

អំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាកើតឡើងរយៈពេល ១០០ថ្ងៃ ពីខែមេសាដល់ខែកក្កដា ឆ្នាំ១៩៩៤។ ប្រជាជនប្រមាណពី៨០ម៉ឺននាក់ដល់១លាននាក់ត្រូវបានសម្លាប់នៅក្នុងរយៈពេលនោះ។ អំពើមហាប្រល័យនេះជាលទ្ធផលនៃការបែកបាក់ប្តូរទំនាស់ជាតិពន្ធុដោយជនជាតិភាគច្រើនហ៊ូទូនិងជនជាតិភាគតិចទុតស៊ី ។

ក្រៅពីការបាត់បង់ជីវិតមនុស្ស អំពើប្រល័យពូជសាសន៍បានបន្តឲ្យប្រជាជនរ៉្វាន់ដារាប់លាននាក់មានវិបត្តិផ្លូវចិត្តដោយសារអំពើហិង្សា ។ ប្រជាជនរ៉្វាន់ដាជាច្រើននាក់មានរបួសយ៉ាងធ្ងន់ធ្ងរ បាត់បង់ផ្ទះសម្បែង បាត់បង់សមាជិកគ្រួសារនិងមិត្តភក្តិ ។ បើតាមការប៉ាន់ស្មាន កុមារកំព្រាមានចំនួនប្រមាណ៣០ម៉ឺននាក់ ហើយប្រមាណជា៩០ភាគរយនៃកុមារដែលនៅរស់បានឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់សមាជិកក្រុមគ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់ខ្លួន ។ កុមារមិនត្រឹមតែបាត់បង់ជីវិតដោយសារអំពើប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ប៉ុន្តែកុមារដែលមានអាយុតិចជាង១០ឆ្នាំត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ ហើយការធ្វើយ៉ាងនេះបានបញ្ចប់ក្តីសង្ឃឹមនៃអនាគតរបស់កុមារទាំងនោះ ។

នៅទីបំផុត អំពើប្រល័យពូជសាសន៍បានធ្វើឲ្យកុមារកំព្រា ស្ត្រីមេម៉ាយ ឬអ្នកដែលបានបាត់បង់សមាជិកគ្រួសារ រស់នៅដោយសេចក្តីភ័យខ្លាចនិងស្រេកឃ្លានការសងសឹក ហើយករណីនេះបានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះសន្តិសុខជាតិ ។

ប្រជាជនរ៉្វាន់ដាភាគច្រើនជឿជាក់ថា ប្រព័ន្ធអប់រំរបស់ប្រទេសរ៉្វាន់ដានៅមុនឆ្នាំ១៩៩៤បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់យុត្តិធម៌ ដោយផ្អែកលើជាតិពន្ធ គំនិតស្រលាញ់មាតុភូមិ គម្លាតផ្លូវភេទ និងការរើសអើងសាសនា ហើយទាំងអស់នេះជាកត្តានាំឆ្ពោះទៅរកអំពើប្រល័យពូជសាសន៍។ ដើម្បីដោះស្រាយបញ្ហានេះ គោលបំណងជាសារវន្តនៃការអប់រំរបស់រ៉្វាន់ដាគឺដើម្បីរំដោះពលរដ្ឋទាំងអស់ចេញពីគ្រប់ទម្រង់នៃការរើសអើង ដើម្បីលើកកម្ពស់វប្បធម៌សន្តិភាព ការយោគយល់ យុត្តិធម៌ និងការអត់ធ្មត់ លើកកម្ពស់សាមគ្គីជាតិ ចៀសវាងវប្បធម៌និទណ្ឌភាព និងដើម្បីពង្រឹងការគោរពសិទ្ធិមនុស្ស សមភាពផ្លូវភេទ សាមគ្គីភាព និងលិទ្ធិប្រជាធិបតេយ្យ ។ ជាក់ស្តែងរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលនៅរ៉្វាន់ដាសម្រេចបានជោគជ័យនូវគោលដៅរបស់ខ្លួនតាមរយៈការផ្តល់ឲ្យកុមារក៏ដូចជាយុវជនរ៉្វាន់ដានូវចំណេះដឹង ជំនាញ និងតម្លៃដែលមានមូលដ្ឋានលើសន្តិភាព ។

#### ក) ការអប់រំផ្លូវការ

នៅឆ្នាំ១៩៩៦ ប្រទេសរ៉្វាន់ដាបានរៀបចំកម្មវិធីសិក្សាជាថ្មី។ កម្មវិធីសិក្សាថ្មីនេះមានរួមបញ្ចូលនូវមុខវិជ្ជាសិក្សាដែលលើកតម្កើងដល់សន្តិភាព សាមគ្គីជាតិ ការផ្សះផ្សាជាតិ សមភាព និងជំនាញនៅក្នុងចំណោមកុមារ ។

នៅខែតុលា ឆ្នាំ១៩៩៦ ក្រសួងអប់រំនៃប្រទេសរ៉្វាន់ដាបានបង្កើតមុខវិជ្ជាមួយឈ្មោះថា "ភាពជាពលរដ្ឋ" នៅថ្នាក់បឋមសិក្សា ហើយក្រោយមកមុខវិជ្ជានេះត្រូវបានពង្រីកទៅមធ្យមសិក្សា។ មុខវិជ្ជានេះរួមមានការអប់រំអំពីសន្តិភាពសិទ្ធិមនុស្សនិងអំពីជំនាញផ្សេងៗសម្រាប់ចិញ្ចឹមជីវិត។ ភាគច្រើននៃមុខវិជ្ជា "ភាពជាពលរដ្ឋ" ផ្តោតទៅលើជំនាញក្នុងការដោះស្រាយជម្លោះ ។ គ្រប់ផ្នែកទាំងអស់នៃការសិក្សា ផ្តោតទៅលើផ្នែកខុសៗគ្នានៃ

ប្រវត្តិសាស្ត្ររបស់ប្រទេសរ៉្វាន់ដា ដូចជាបុព្វហេតុនៃអំពើប្រល័យពូជសាសន៍ និងឥទ្ធិពលរបស់ទង្វើនេះ ការទទួលខុសត្រូវរបស់អ្នកដែលប្រព្រឹត្តទង្វើនេះ ជំនាញក្នុងការស្តារប្រទេស និងការត្រួតពិនិត្យអំពីលទ្ធភាពក្នុងការបង្កើតវប្បធម៌សន្តិភាពនៅរ៉្វាន់ដា ។

មានលក្ខខណ្ឌវិនិច្ឆ័យបីយ៉ាងសម្រាប់ការចាប់ផ្តើមការអប់រំអំពី "ភាពជាពលរដ្ឋ" ។ ទីមួយ គ្រូបង្រៀនត្រូវតែបានទទួលការបង្ហឹកមួយរយៈដើម្បីយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្ត ដូចជាទ្រឹស្តីនៃការប៉ះទង្គិចផ្លូវចិត្តជាមូលដ្ឋាន រោគសញ្ញានៃការប៉ះទង្គិចផ្លូវចិត្តរបស់កុមារតាមប្រភេទ អាយុ ។ល ។ សៀវភៅសម្រាប់ការហ្វឹកហ្វឺននេះមានមូលដ្ឋានចេញពី "ការអប់រំ ស៊ូសានហ្វោធឹន អំពីការដោះស្រាយជម្លោះ" ។ ទីពីរគឺតម្រូវការនៃសៀវភៅណែនាំចំពោះគ្រូបង្រៀនដែលអាចជួយគ្រូឲ្យយល់អំពីរបៀបដែលអាចផ្តល់ការអប់រំអំពីសន្តិភាពនិងការផ្សះផ្សាជាតិដល់កុមារ ។ ទីបីគឺជាតម្រូវការសៀវភៅដែលមានចម្រៀងនិងអត្ថបទសម្រាប់អានជាគំរូសម្រាប់កុមារ ។

ក្រសួងអប់រំរ៉្វាន់ដាក៏បានរៀបគម្រោងនិងអភិវឌ្ឍកម្មវិធីអប់រំក្រៅប្រព័ន្ធដល់យុវជន សៀវភៅអក្សរសាស្ត្រដែលនិយាយអំពីប្រធានបទនៃការអប់រំសន្តិភាព និងបានបង្កើតក្រុមសិល្បៈឲ្យសម្តែងអំពីបញ្ហាសន្តិភាព ។

### ១) ជំរំសាមគ្គី

គណៈកម្មការជាតិបានរៀបចំ"ជំរំសាមគ្គី"ជាលើកទីមួយនៅឆ្នាំ១៩៩៦ដើម្បីសាមគ្គីភាពនិងការផ្សះផ្សាជាតិនៅក្នុងប្រទេសរ៉្វាន់ដា ដើម្បីផ្តល់ការអប់រំដល់អ្នកដែលវិលត្រឡប់មកពីនិរទេសខ្លួន អតីតទាហាន កុមារ និងជនសង្ស័យពីបទប្រល័យពូជសាសន៍ដែលទើបតែរួចពីការឃុំឃាំង ។ ការអប់រំនៅតាមជំរំជាតម្រូវការចាំបាច់សម្រាប់អ្នកដែលនឹងក្លាយទៅជាមន្ត្រីរដ្ឋបាល និងនិស្សិតនៅតាមសកលវិទ្យាល័យ ។ បុគ្គលិកដែលចង់ត្រឡប់ទៅបម្រើការងារផ្នែកសាធារណៈឬឯកជន និងពលរដ្ឋវ័យក្មេងដែលចង់ត្រឡប់ទៅសាលារៀនវិញ ចាំបាច់ត្រូវតែបញ្ចប់វគ្គហ្វឹកហ្វឺននៅតាមជំរំជាមុនសិន ។

ជំរំសាមគ្គីមានទិសដៅដាក់បញ្ចូល"សន្តិភាព"ទៅក្នុងគ្រប់គោលការណ៍នៃការអប់រំទាំងអស់ ។ នៅក្នុងរយៈពេលពីមួយខែទៅបីខែ ជំរំសាមគ្គីបានផ្តល់នូវការអប់រំមនោគមវិជ្ជាខ្លះដើម្បីផ្តល់ជាមូលដ្ឋានដល់ការយល់ដឹងអំពីគំនិតជាតិនិយម និងដើម្បីលុបបំបាត់មេរៀនដែលមានលក្ខណៈចោទប្រកាន់ដល់ជាតិពន្ធផ្សេងៗ ដែលបង្កើតឡើងដោយរដ្ឋាភិបាលមុនៗ និងការអប់រំដែលមានលក្ខណៈនយោបាយ ។

មានគម្រោងខុសៗគ្នាជាច្រើននៅក្នុងជំរំសាមគ្គីដែលគាំទ្រដោយអង្គការក្រៅរដ្ឋាភិបាល ។ ស្ទើរតែគ្រប់គម្រោងទាំងអស់ផ្តោតទៅលើការលើកកម្ពស់ការកសាងសន្តិភាពនៅក្នុងចំណោមយុវជនរ៉្វាន់ដា ដោយការប្រមូលយុវជនរ៉្វាន់ដាពីតំបន់ផ្សេងៗឲ្យមករស់នៅក្នុងជំរំ រៀនសូត្រពីគ្នាទៅវិញទៅមក និងធ្វើការជាមួយគ្នានៅក្នុងគម្រោងសុខុមាលភាពសហគមន៍ដូចជា ការផលិតឥដ្ឋ ការសាងសង់ផ្ទះ ការដាំដំណាំ និងការសាងសង់ទីធ្លាសម្រាប់ហាត់កីឡា ការបោសសំរាមនៅផ្លូវសាធារណៈ និងការសាងសង់សាលារៀនឡើងវិញ ។ តាមរយៈការចូលរួមក្នុងជំរំនិងគម្រោងកសាងសហគមន៍ទាំងនេះ យុវជនអាចទទួលយកចំណេះដឹងអំពីជំនាញក្នុងការធ្វើសហប្រតិបត្តិការ ការលើកកម្ពស់មោទកភាពនិងការយល់ដឹងចំពោះខ្លួនឯង ការបំបាត់ចោលនូវទំនៀមទម្លាប់ចាស់គំរិល ការគ្រប់គ្រងខ្លួនឯងនៅក្នុងជីវភាពរបស់ជំរំ និងការដោះស្រាយជម្លោះ ។

### ក) ជំរំយុវជន

ជំរំយុវជនដែលទទួលបានការឧបត្ថម្ភពីគម្រោង "ការលើកកម្ពស់ការផ្សះផ្សានៅក្នុងចំណោមយុវជន" របស់អង្គការទស្សនៈពិភពលោកត្រូវបានបង្កើតឡើងនៅឆ្នាំ២០០២ ។ នៅក្នុងរយៈពេលមួយសប្តាហ៍ ជំរំយុវជនបាននាំជនជាតិហ៊ូទូនិងទុតស៊ីចំនួន៣០នាក់ទៅទស្សនាទីតាំងប្រល័យពូជសាសន៍ដែលមានមនុស្សស្លាប់ប្រមាណជាង៥ម៉ឺននាក់ ។ បន្ទាប់ពីទស្សនកិច្ចនេះ ជំរំយុវជនបានបង្កើតជាក្រុមពិភាក្សាមួយអំពីអារម្មណ៍របស់អ្នកចូលរួមម្នាក់ៗ បន្ទាប់ពីបានទស្សនាទីតាំងប្រល័យពូជសាសន៍ និងបានចែករំលែករឿងរ៉ាវនិងការចងចាំពីអំពើប្រល័យពូជសាសន៍ឲ្យគ្នាទៅវិញទៅមក ។ ទន្ទឹមនឹងពេលនោះដែរ អ្នកដឹកនាំជំរំក៏បានចូលរួមនៅក្នុងការពិភាក្សាអំពីតម្លៃនៃការអត់ឱននិងការផ្សះផ្សាជាតិ ។ យុវជនទាំងនោះបានចំណាយពេលវេលាដែលសប្បាយ

ជាមួយគ្នាដូចជាលេងល្បែងកម្សាន្ត ច្រៀងចម្រៀង រាំលេង សម្តែងរឿងកំប្លែងខ្លីៗ ទស្សនាខ្សែភាពយន្តនិងធ្វើការងាររបស់គម្រោង ។

ជំរឿយុវជនបានជួយដល់ប្រជាជនរ៉ាន់ដាដែលនៅរស់ពីរបបប្រល័យពូជសាសន៍ឲ្យដោះស្រាយចំពោះការប៉ះទង្គិចផ្លូវចិត្ត និងបានជួយពង្រីកការយល់ដឹងនិងសុទិដ្ឋិនិយមសម្រាប់អនាគត ។ ជំរឿយុវជនបានជំរុញយុវជនឲ្យចេះចែករំលែកអារម្មណ៍និងបទពិសោធន៍កន្លងមក និងធ្វើការជាក្រុមដើម្បីកសាងជំនាញក្នុងការធ្វើទំនាក់ទំនង ភាពស្មោះត្រង់ និងរបៀបក្នុងការដោះស្រាយការប៉ះទង្គិចផ្លូវចិត្តនៅក្នុងចំណោមកុមារ ។

## ២) អៀរឡង់ខាងជើង

សាសនានិងនយោបាយបានបែងចែកប្រជាជននៅអៀរឡង់ខាងជើងជាពីរក្រុមគឺ ក្រុមប្រូតេស្តង់និងក្រុមកាតូលិក ។ កុមារនៃក្រុមទាំងពីរនេះត្រូវបានឪពុកម្តាយនិងសហគមន៍របស់ខ្លួនបង្រៀនឲ្យស្អប់និងរើសអើងចំពោះក្រុមម្ខាងទៀត ហើយសាសនាមាននៅពាសពេញកម្មវិធីសិក្សាទាំងអស់ ។ ការស្អប់ក្រុមម្ខាងទៀតបានកើនឡើងយ៉ាងខ្លាំងនៅឆ្នាំ១៩៦៩ នៅពេលដែលអំពើហិង្សាបានផ្ទុះឡើង ។ នៅពេលដែលកំពុងមានជម្លោះ យុវជនក្នុងក្រុមទាំងសងខាងបានប្រយុទ្ធគ្នាទៅវិញទៅមកក្នុងលំនាំជាទាហាន ។ អំពើហិង្សាដែលបានកើតឡើងនៅចន្លោះឆ្នាំ១៩៦៩និង១៩៩៨បានបណ្តាលឲ្យមនុស្សស្លាប់ប្រមាណ ៣៦០០នាក់ ដែលជាង៣៥ភាគរយនៃអ្នកដែលបានស្លាប់គឺជាយុវជនកុមារដែលនៅវ័យក្មេងៗ (ចន្លោះពីអាយុទើបនឹងកើតដល់អាយុ២៥ឆ្នាំ) ។

ដើម្បីធ្វើឲ្យប្រសើរឡើងវិញនូវសង្គមមួយដែលបាក់បែក ចាំបាច់ត្រូវតែកែលម្អប្រព័ន្ធអប់រំ ។ ជាក់ស្តែងកម្មវិធីអប់រំអំពីសន្តិភាពដែលរៀបចំឡើងដោយសហគមន៍និងក្រុមសាសនាបានជួយកែប្រែការយល់ឃើញរបស់ក្រុមមួយចំពោះក្រុមមួយទៀតបានយ៉ាងច្រើន ។

### ក) ការអប់រំផ្លូវការ

ដើម្បីបង្រួបបង្រួមសង្គមដែលបាក់បែក ក្រសួងអប់រំអៀរឡង់ខាងជើងបានធ្វើកំណែទម្រង់កម្មវិធីសិក្សារបស់សាលារៀនក្នុងគោលបំណងអភិវឌ្ឍការយោគយល់រវាងកុមារនៃក្រុមទាំងពីរ ។ ប្រព័ន្ធអប់រំថ្មីនេះមានគោលដៅកែប្រែអាកប្បកិរិយារបស់កុមារតាមរយៈការបង្រៀនឲ្យយល់ពីតម្លៃនៃសាសនានិងវប្បធម៌ផ្សេងទៀត និងតាមរយៈការលើកទឹកចិត្តឲ្យបង្កើនទំនាក់ទំនងល្អរវាងសហគមន៍ផ្សេងៗ និងលើកទឹកចិត្តឲ្យមាតាបិតាសិស្សចូលរួមក្នុងការអប់រំកូនៗរបស់ខ្លួន ។ ដោយសារតែឪពុកម្តាយ សហគមន៍ និងសាលារៀន មានតួនាទីសំខាន់នៅក្នុងសង្គមដែលបែកបាក់ មាតាបិតាកំពុងតែគិតឃើញថាបញ្ហានេះជាបញ្ហាគន្លឹះនៅក្នុងកម្មវិធីអប់រំថ្មី ។ សាលារៀនត្រូវតែសហការជាមួយមាតាបិតាសិស្សដើម្បីយល់ដឹងអំពីទម្រង់នៃការអប់រំដែលមាតាបិតាសិស្សចង់បានសម្រាប់កូនចៅរបស់ខ្លួន ហើយមាតាបិតាក៏អាចជួយដល់សកម្មភាពខ្លះរបស់សាលារៀនដែរ ។

ដើម្បីលើកកម្ពស់ទំនាក់ទំនងរបស់សហគមន៍តាមរយៈកម្មវិធីសិក្សារបស់សាលារៀន មុខវិជ្ជា"ការអប់រំដើម្បីការយោគយល់គ្នា" និង "កេរដំណែលវប្បធម៌" ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨៩សម្រាប់កុមារនៅសាលាបឋមសិក្សានិងមធ្យមសិក្សា ហើយគ្រប់សាលារៀនទាំងអស់នៅអៀរឡង់ខាងជើងបានបញ្ចូលមុខវិជ្ជានេះទៅក្នុងកម្មវិធីសិក្សារបស់ខ្លួននៅឆ្នាំ១៩៩២ ។

### ការអប់រំដើម្បីការយោគយល់គ្នា

មុខវិជ្ជានេះមានគោលបំណងសំខាន់ៗបួន ÷

១) លើកកម្ពស់ការគោរពខ្លួនឯងនិងអ្នកដទៃ កសាងទំនាក់ទំនងល្អ ជួយដល់កុមារក្នុងការអភិវឌ្ឍជំនឿចិត្តលើខ្លួនឯង កសាងសមត្ថភាពដើម្បីទទួលខុសត្រូវចំពោះខ្លួនឯង និងដឹងអំពីរបៀបធ្វើការនិងលេងជាមួយគ្នាដោយការទទួលយកបាននិងមិនមានការរើសអើងចំពោះភាពខុសគ្នា ។

២) អភិវឌ្ឍចំណេះដឹងអំពីសារជាតិនៃជម្លោះ របៀបក្នុងការប្រឈមមុខនិងកាត់បន្ថយជម្លោះ ។

៣) អភិវឌ្ឍចំណេះដឹងចាំបាច់ដើម្បីភាពឯករាជ្យនៅក្នុងគ្រួសារ សហគមន៍ និងពិភពលោក ។

៤) អភិវឌ្ឍចំណេះដឹងអំពីចំណុចស្រដៀងគ្នានិងខុសប្លែកគ្នារវាងប្រពៃណីវប្បធម៌របស់ប្រជាជននៅអៀរឡង់ខាងជើង ។

### កេរដំណែលវប្បធម៌

មុខវិជ្ជា "កេរដំណែលវប្បធម៌" ត្រូវបានបង្កើតឡើងដើម្បីឲ្យកុមារដែលសិក្សានៅតាមសាលារៀនបានដឹង យល់ និងវាយតម្លៃលើកេរដំណែលវប្បធម៌និងការពឹងផ្អែកគ្នាទៅវិញទៅមកនៃវប្បធម៌ ។ កម្មវិធីនេះមានទិសដៅសំខាន់ៗបីយ៉ាងៈ

*១) អន្តរកម្ម ការពឹងផ្អែកគ្នាទៅវិញទៅមក និរន្តរភាព និងការផ្លាស់ប្តូរៈ* ធ្វើឲ្យកុមារយល់ដឹង និងបង្កើនសមត្ថភាពនៃអន្តរកម្មនិងការពឹងផ្អែកគ្នាទៅវិញទៅមក ។

*២) លក្ខណៈខុសប្លែកគ្នានិងដូចគ្នាៈ* កសាងសមត្ថភាពរបស់កុមារអំពីលក្ខណៈខុសប្លែកគ្នានិងដូចគ្នានៃកេរដំណែលវប្បធម៌ ។

*៣) ឥទ្ធិពលអន្តរជាតិៈ* ផ្តល់ចំណេះដឹងដល់កុមារអំពីលក្ខណៈជាសកលនៃសង្គមបច្ចុប្បន្ន ។

### ១) សហគមន៍ ខរីមីឡា

សហគមន៍ខរីមីឡាជាសហគមន៍គ្រិស្តសាសនិកដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៦៦ ។ គោលបំណងសំខាន់របស់សហគមន៍នេះគឺលើកកម្ពស់ដល់សន្តិភាពនិងការផ្សះផ្សាជាតិនៅក្នុងចំណោមប្រជាជនអៀរឡង់ខាងជើង ។ យុទ្ធសាស្ត្ររបស់សហគមន៍គឺសម្រេចឲ្យបាននូវគោលបំណងនេះតាមរយៈការផ្តល់កន្លែងដល់ប្រជាជនអៀរឡង់ខាងជើងជួបពិភាក្សានិងសិក្សាពីគ្នាទៅវិញទៅមក ហើយការណ៍នេះមិនត្រឹមតែស្វែងរកទំនុកចិត្ត ការគោរព និងការទទួលស្គាល់គ្នាទៅវិញទៅមកប៉ុណ្ណោះទេ ថែមទាំងពង្រីកសហប្រតិបត្តិការរវាងមនុស្សមកពីក្រុមផ្សេងៗទៀត ។

សហគមន៍ខរីមីឡាយល់ឃើញថា ការកសាងសន្តិភាពនិងការផ្សះផ្សាជាតិនៅអៀរឡង់ខាងជើងត្រូវតែរួមបញ្ចូលទាំងកុមារនិងមនុស្សពេញវ័យ ។ សហគមន៍នេះបានបែងចែកការងាររបស់ខ្លួនជាបួនផ្នែកៈ ១) ការងារសាលា ២) ការងារយុវជន ៣) គ្រួសារ និង ៤) កម្មវិធីទ្រីថប (Treetops Programme) ។

### ការងារសាលា

សារសំខាន់នៃកម្មវិធី "ការងារសាលា" គឺដើម្បីអភិវឌ្ឍន៍ការយល់ដឹង ទស្សនៈ និងកម្មវត្ថុរបស់កម្មវិធី "ការអប់រំដើម្បីការយោគយល់គ្នា" និងដើម្បីសិក្សាអំពីជំនាញក្នុងការកសាងសន្តិភាពនៅក្នុងចំណោមគ្រូបង្រៀន និងសិស្សានុសិស្សតាមរយៈការធ្វើបាឋកថានៅក្នុងសាលា ឬបញ្ជូនបុគ្គលិកទៅជួយគ្រូបង្រៀននៅតាមថ្នាក់រៀន ។ សហគមន៍បានបង្កើតកន្លែងសម្រាប់គ្រូៗនិងសិស្សដើម្បីជួបជុំគ្នាជាក្រុមឬជាបុគ្គល ដើម្បីពិភាក្សានិងសិក្សាអំពីគ្នាទៅវិញទៅមក ។ កម្មវិធី"ការងារសាលា"ក៏មានផ្តល់កម្មវិធីហ្វឹកហ្វឺនអំពី"ការអប់រំដើម្បីការយោគយល់គ្នា"ដែរ ។

### ការងារយុវជន

នៅរៀងរាល់៦ខែ សហគមន៍ខរីមីឡាបានផ្តល់ឱកាសដល់យុវជននៅអៀរឡង់ខាងជើងក៏ដូចជានៅក្នុងប្រទេសផ្សេងៗទៀតបើកកិច្ចប្រជុំនិងចែករំលែកបទពិសោធន៍របស់ខ្លួនចំពោះគ្នាទៅវិញទៅមកនៅក្នុងរយៈពេលជាង៦សប្តាហ៍ ។ កម្មវិធីនេះបង្កើតឡើងសម្រាប់មនុស្សជំទង់ដែលមានអាយុពី១៨ទៅ២៥ឆ្នាំ ។ កម្មវិធីផ្សេងទៀតត្រូវបានបង្កើតឡើងសម្រាប់សិស្សដែលមានអាយុពី១៥ ទៅដល់១៧ឆ្នាំ ។ កម្មវិធីដែលត្រូវបានរៀបចំឡើងដោយមនុស្សដែលមានវ័យនៅក្មេងបានផ្តល់ជាសិក្ខាសាលាគាំទ្រដល់កម្មករដែលជាយុវជន ។ កម្មវិធីនេះបានផ្តល់ជំនាញបង្រៀនអំពីការគោរពខ្លួនឯង ការគោរពអ្នកដទៃ ធ្វើការងារជាក្រុម និងសហការណ៍គ្នាដោយសាមគ្គីភាព ។

### គ្រួសារ

កម្មវិធីនេះបានផ្តោតទៅលើកុមារ មនុស្សពេញវ័យ និងមនុស្សដែលមានវ័យចំណាស់ ដោយក្រឡេកមើលទៅបញ្ហានៃការពង្រឹងសមត្ថភាព កសាងទំនុកចិត្ត និងការអប់រំមនុស្សពេញវ័យ ។ កម្មវិធីនេះបានផ្តល់ការគាំទ្រនិងការប្រឹក្សាយោបល់ដល់មនុស្សដែលនៅជុំវិញខ្លួន ។ កម្មវិធីនេះក៏បានផ្តល់កន្លែងសម្រាប់រៀបចំកម្មវិធី ដូចជាសិល្បៈនិងសិប្បកម្ម ការសម្តែងដើម្បីជួយដល់មនុស្សដែលមានការប៉ះពាល់ផ្នែកស្មារតី ។

### កម្មវិធីទ្រីថប

កម្មវិធីទ្រីថបត្រូវបានបង្កើតឡើងដើម្បីឧបត្ថម្ភដល់កុមារដែលបានបាត់បង់ក្រុមគ្រួសារដោយសារជម្លោះ ។ ទស្សនាវដ្តី "ទ្រីថប"ត្រូវបានបង្កើតឡើងដើម្បីគាំទ្រកុមារដែលបាត់បង់ក្រុមគ្រួសារ និងចេញផ្សាយពីរដងក្នុងមួយឆ្នាំ ។ "បណ្តាញអប់រំ

សម្រាប់កុមារកំព្រា“ជាផ្នែកមួយនៃកម្មវិធីទ្រីថប ។ បណ្តាញនេះបានផ្តល់ជាសិក្ខាសាលានិងវគ្គហ្វឹកហ្វឺនដល់អ្នកដែលធ្វើការងារជាមួយក្រុមគ្រួសារដែលបាត់បង់ញាតិសន្តាន ដូចជា គ្រូបង្រៀន បុគ្គលិករដ្ឋ បព្វជិត ក្រុមអ្នកជំនាញវិជ្ជាជីវៈ និងក្រុមអ្នកស្ម័គ្រចិត្ត ដើម្បីជួយដល់អ្នកទាំងនេះក្នុងការធ្វើទំនាក់ទំនងល្អជាមួយកុមារដែលបានបាត់បង់ក្រុមគ្រួសារ ។

តើកម្មវិធីទាំងនេះមានទំនាក់ទំនងដូចម្តេចជាមួយប្រទេសកម្ពុជា?

## ជំពូកទី៤
## ការចាប់ផ្តើមការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា

### ១) សេចក្តីផ្តើម

ការស្រាវជ្រាវអំពីការអប់រំអំពីសន្តិភាពនិងប្រតិបត្តិការអប់រំអំពីសន្តិភាពក្រោយសង្គ្រាម អាចជាគ្រឹះដ៏សំខាន់ក្នុងការកសាងសន្តិភាពនៅកម្ពុជា ។

ការកំណត់យុទ្ធសាស្ត្រនៃការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជានឹងក្លាយជាចំណុចសំខាន់ដែលនឹងត្រូវពិភាក្សានៅក្នុងជំពូកនេះ និងត្រូវបានចែកចេញជាបួនផ្នែក ។ ផ្នែកទី១នឹងពិភាក្សាអំពីបទពិសោធន៍នៃការអប់រំសន្តិភាពក្នុងដំណាក់កាលក្រោយសង្គ្រាមនៅបណ្តាប្រទេសផ្សេងទៀត ។ ផ្នែកនេះនឹងពិភាក្សាជាមួយនឹងករណីដែលកើតឡើងនៅប្រទេសកម្ពុជា ហើយនៅទីបញ្ចប់នឹងផ្តល់យោបល់អំពីវិធីដែលមានប្រសិទ្ធភាពក្នុងការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា ។ ផ្នែកទី២នឹងពន្យល់ហេតុអ្វីបានជាប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមត្រូវបានបំភ្លេច និងផលវិបាកនៃការណ៍នេះ ។ ផ្នែកទី៣នឹងវាយតម្លៃវប្បធម៌នៃកម្ពុជា និងផ្តល់យោបល់ទៅលើការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា ។ ផ្នែកចុងក្រោយនឹងបរិយាយអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានធ្វើកិច្ចការលេចធ្លោមួយចំនួនពាក់ព័ន្ធទៅនឹងការអប់រំអំពីសន្តិភាព ។ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាកន្លែងតែមួយគត់ដែលមានសក្តានុពលភាពក្នុងការធ្វើការងារលើគម្រោងនេះ ។

### ២) តើកម្ពុជាគួរតែប្រើវិធីអ្វី?

ប្រទេសជាច្រើននៅលើពិភពលោកបានជំរុញការអប់រំអំពីសន្តិភាព ។ ប្រទេសរ៉្វាន់ដានិងប្រទេសអៀរឡង់ខាងជើងបានជ្រើសរើសការអប់រំអំពីសន្តិភាពជាវិធីមួយក្នុងការព្យាបាលសង្គមដែលបែកបាក់ ដោយការកសាងសន្តិភាព ការបង្រួបបង្រួមជាតិឡើងវិញ និងការផ្លាស់ប្តូរឥរិយាបថរបស់ប្រជាជនចំពោះអ្នកដទៃ ។

តាមរយៈការចែករំលែកការអប់រំអំពីសន្តិភាពនៅបណ្តាប្រទេសដទៃ ប្រទេសទាំងពីរនេះបានរកឃើញថា ការអប់រំរយៈពេលខ្លីអំពីសន្តិភាពមានសារសំខាន់សម្រាប់ប្រទេសដែលទើបតែបញ្ចប់ជម្លោះ និងប្រទេសដែលកំពុងតែប្រឈមមុខនឹងជម្លោះ ។ សង្គមរ៉្វាន់ដាត្រូវបានបែងចែកដោយសារតែការប្រកាន់ពូជសាសន៍ ។ ហេតុដូច្នេះ ប្រទេសរ៉្វាន់ដាបានអនុវត្តការអប់រំអំពីសន្តិភាពដោយផ្តោតសំខាន់ទៅលើការបង្រួបបង្រួមប្រជាជន និងបង្កឱកាសឲ្យប្រជាជនបាននិយាយគ្នា បានបញ្ចេញអារម្មណ៍របស់ខ្លួន និងចែករំលែកអារម្មណ៍នោះជាមួយអ្នកដទៃ ។ ជាលទ្ធផលអារម្មណ៍ភ័យខ្លាចនិងស្អប់ខ្ពើមបានកាត់បន្ថយ ហើយជំនួសមកវិញដោយការអាណិតអាសូរ ការសន្តោស និងការជួយគ្នា ។

ទស្សនវិស័យរបស់រដ្ឋាភិបាលរ៉្វាន់ដាសម្រាប់អនាគតគឺកសាងវប្បធម៌សន្តិភាពសម្រាប់ប្រជាជនរ៉្វាន់ដាជំនាន់ក្រោយ ។ ចេញពីចំណុចនេះនឹងគ្មានសង្គ្រាមតទៅទៀត ។ ជំនាញក្នុងការដោះស្រាយជម្លោះនិងការវិភាគរកមូលហេតុនៃអំពើប្រល័យពូជសាសន៍អាចនាំឲ្យប្រជាជនរ៉្វាន់ដាជំនាន់ក្រោយយល់ច្បាស់អំពីជម្រៅនៃប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន ចេះដោះស្រាយបញ្ហាដោយសន្តិវិធី និងចេះស្វែងរកសន្តិភាពសម្រាប់ពេលអនាគត ។

នៅក្នុងពេលជាមួយគ្នានេះ សង្គមអៀរឡង់ខាងជើងដែលត្រូវបានបែងចែកដោយសារតែជំនឿខុសៗគ្នា ត្រូវបានផ្សះផ្សាដោយការបង្កើតទីតាំងមួយដែលអាចឲ្យប្រជាជនស្គាល់គ្នាទៅវិញទៅមក បង្កើនការយល់អំពីគ្នាទៅវិញទៅមក និងទទួលយកភាពខុសគ្នា ។ អង្គការសាសនានានាដែលពីមុនធ្លាប់បានបង្រៀនមនោគមវិជ្ជាមិនត្រឹមត្រូវដល់ប្រជាជន ឥឡូវនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតសន្តិភាព ។

នៅអៀរឡង់ខាងជើង កម្មវិធីសិក្សានៅសាលាដំណើរការជាមួយកុមារដោយផ្អែកលើវប្បធម៌របស់ក្រុមកុមារទាំងនោះនិង

វប្បធម៌របស់ក្រុមដទៃ ។ គោលបំណងគឺដើម្បីឲ្យសិស្សយល់អំពីខ្លួនឯងនិងអំពីអ្នកដទៃ និងចេះទទួលស្គាល់និងគោរពអ្នកដទៃ ។

សរុបមក ការអប់រំពីអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដាបានផ្តល់ឱកាសឲ្យជនជាតិហ៊ូទូនិងជនជាតិទុតស៊ីបង្កើតសង្គមរ៉្វាន់ដាមួយ ហើយការអប់រំនៅប្រទេសអៀរឡង់ខាងជើង ដែលបង្រៀនអំពីកេរដំណែលនៃវប្បធម៌និងការយោគយល់គ្នាទៅវិញទៅមក អាចនាំអ្នកគោរពលទ្ធិប្រូតេស្តង់និងអ្នកគោរពលទ្ធិកាតូលិកមករកការយោគយល់គ្នាបានប្រសើរជាងមុន ។

តើការអប់រំបែបណាទើបអាចផ្សះផ្សាសង្គមខ្មែររវាងជនរងគ្រោះនិងអតីតជនដៃដល់?

យោងតាមវប្បធម៌ខ្មែរ ការរើសអើងរវាងជនរងគ្រោះនិងអតីតជនដៃដល់ខ្មែរក្រហមមិនបានលេចឡើងតាមរបៀបដូចការរើសអើងរវាងជនជាតិហ៊ូទូនិងជនជាតិទុតស៊ីនៅប្រទេសរ៉្វាន់ដា ឬរវាងអ្នកនិយមកាតូលិកនិងអ្នកនិយមប្រូតេស្តង់នៅប្រទេសអៀរឡង់ខាងជើងទេ ។ បើពិនិត្យជាទូទៅ ស្ថានភាពនៅកម្ពុជាមើលទៅគ្រាន់បើជាងនៅប្រទេសទាំងពីរ ។ អំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាមិនមែនសំដៅតែទៅលើក្រុមមួយទេ ប៉ុន្តែសំដៅជនជាតិផ្សេងៗនិងក្រុមសាសនាផ្សេងៗទៀតនៅទូទាំងប្រទេស ។ បើទោះជាពីដំបូងបដិវត្តន៍កម្ពុជាមើលទៅហាក់ដូចជាបដិវត្តន៍របស់អ្នកក្រប្រឆាំងនឹងអ្នកមាន ប៉ុន្តែនៅទីបញ្ចប់នៃរបបនោះ ទាំងអ្នកមានទាំងអ្នកក្រគឺជាជនរងគ្រោះដូចគ្នា ។

ទោះជាក្រុមជាតិពន្ធមួយចំនួនត្រូវបានសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ពិតមែន ប៉ុន្តែក្រុមទាំងនោះមិនមែនជាគោលដៅចម្បងនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជាទេ ។ គោលដៅចម្បងនៃអំពើប្រល័យពូជសាសន៍លេចចេញពីអារម្មណ៍របស់អ្នកក្រដែលស្អប់ ខឹង គុំកួននឹងអ្នកមាន និងលេចចេញពីគោលនយោបាយជ្រុលនិយមរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ការបាត់ទំនុកចិត្តរបស់មេដឹកនាំខ្មែរក្រហមចំពោះប្រជាជនក៏ជាមូលហេតុនៃការសម្លាប់រង្គាលដែរ ។ នៅក្រោម «គោលនយោបាយបន្សុទ្ធកម្ម» មេដឹកនាំខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯងដោយគ្មានការស្ទាក់ស្ទើរ ។ ប្រជាជនម្នាក់ដែលត្រូវបានសង្ស័យថាមានបំណងប្រឆាំងនឹងអង្គការបដិវត្តន៍ អាចត្រូវសម្លាប់ចោលយ៉ាងងាយ ។ ឧទាហរណ៍ពាក្យស្លោកមួយឃ្លារបស់ខ្មែរក្រហមសរសេរថា «សម្លាប់ច្រឡំមួយរយនាក់ប្រសើរជាងលែងច្រឡំមួយនាក់» ។

នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ការមិនទុកចិត្តគ្នានៅតែមាននៅក្នុងអារម្មណ៍ដែលស្អប់ ភ័យខ្លាច និងសងសឹក របស់ប្រជាជនកម្ពុជា ។ ដើម្បីកសាងសន្តិភាពនៅប្រទេសកម្ពុជា ប្រជាជនត្រូវតែសម្តែងអារម្មណ៍បែបនេះចេញមកក្រៅ ហើយទទួលយកការពិត និងបង្កើតការអាណិតអាសូរ សេចក្តីស្រលាញ់ និងការជួយយកអាសារគ្នាទៅវិញទៅមក ។ សម្តេចព្រះមហាឃោសនន្ទបានមានសង្ឃដីកាថា ដើម្បីកសាងសន្តិភាពនៅកម្ពុជា ប្រជាជនកម្ពុជាត្រូវតែលាងជម្រះចិត្តគំនិត និងបេះដូងឲ្យជ្រះស្រឡះជាមុនសិន ។

ការសិក្សាអំពីបទពិសោធន៍ដ៏រន្ធត់នៃប្រវត្តិសាស្ត្រគឺជាការសំខាន់ ។ នៅប្រទេសរ៉្វាន់ដា ការសិក្សាពីអំពើប្រល័យពូជសាសន៍ត្រូវបានអនុវត្តនៅក្នុងការស្រាវជ្រាវអំពីការអប់រំសន្តិភាព ។ ស្រដៀងគ្នានេះដែរនៅប្រទេសជប៉ុន ការអប់រំអំពីសន្តិភាពត្រូវបានបូកបញ្ចូលទាំងប្រវត្តិសាស្ត្រពីអតីតកាលអំពីការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរ ទោះជាសុបិនអាក្រក់នៃហ៊ីរ៉ូស៊ីម៉ានិងណាហ្កាសាគីបានរំលងផុតហើយក៏ដោយ ។ ឥឡូវនេះ ប្រជាជនជប៉ុនកំពុងតែធ្វើដំណើរឆ្ពោះទៅរកអនាគតដែលពោរពេញទៅដោយសន្តិភាព ។

ក្នុងករណីប្រទេសកម្ពុជាដែលមានបទពិសោធន៍នៃមហាវិនាសកម្ម គួរតែបង្កើតកម្មវិធីអប់រំអំពីសន្តិភាពដើម្បីឲ្យប្រជាជនបានរៀនសូត្រ ។ គោលដៅចម្បងនៃគម្រោងនេះគឺពញ្ញាក់អារម្មណ៍របស់ប្រជាជនអំពីរបបខ្មែរក្រហម និងដើម្បីចៀសវាងការកើតឡើងវិញសាជាថ្មីនៃរបបនេះនៅពេលអនាគត ។

គួរឲ្យសោកស្តាយ ប្រវត្តិសាស្ត្ររបបខ្មែរក្រហមត្រូវបានកាត់ឲ្យនៅត្រឹមតែប៉ុន្មានឃ្លាប៉ុណ្ណោះនៅក្នុងសៀវភៅសិក្សា ។

### ៣) ប្រវត្តិសាស្ត្រដែលត្រូវបានបំភ្លេច

ខ្ញុំភ្ជាប់សារសំខាន់នៃចំណុចនេះពីព្រោះខ្ញុំជឿជាក់ថា សង្គមមួយត្រូវតែយល់ច្បាស់អំពីប្រវត្តិសាស្ត្ររបស់ខ្លួនមុនពេលដំណើរការកិច្ចការដទៃទៀត ។

“ហេតុអ្វីខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម៉្លេះ?” គឺជាសំណួរមួយដែលប្រជាជនកម្ពុជាសួរជាទូទៅ និងជាសំណួរមួយដែលគ្មាននរណាម្នាក់អាចឆ្លើយបាន ។ តាំងពីឆ្នាំ១៩៧៩រហូតដល់បច្ចុប្បន្ន ប្រជាជនកម្ពុជាមិនដែលមានការយល់ដឹងដ៏ត្រឹមត្រូវមួយ និងមិនដែលបានទទួលការអប់រំត្រឹមត្រូវតាមប្រព័ន្ធអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជា អ្វីដែលប្រជាជនដឹងគឺការស្អប់ខ្ពើម កំហឹង ការគុំកួន និងការសងសឹកចំពោះខ្មែរក្រហម ។

ការកកើតឡើងនៃសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសបានផ្លាស់ប្តូរកម្ពុជាពីរបបកុម្មុយនិស្តទៅជាសង្គមប្រជាធិបតេយ្យ ។ គណបក្សនយោបាយជាច្រើនបានចូលរួមយ៉ាងសកម្មក្នុងឆាកនយោបាយ ។ ការនិយាយអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យក៏ស្ថិតនៅក្រោមផលប្រយោជន៍នយោបាយ ។ ដោយសារតែហេតុផលនេះទើបកម្មវិធីសិក្សាអំពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានកាត់ឲ្យនៅត្រឹមតែប៉ុន្មានឃ្លាប៉ុណ្ណោះ ។ តាមរយៈការរំឭកប្រជាជនកម្ពុជាអំពីរបបកម្ពុជាប្រជាធិបតេយ្យនៅគ្រប់យុទ្ធនាការឃោសនារកសំឡេងឆ្នោត គណបក្សប្រជាជនកម្ពុជារំពឹងថានឹងទទួលបានសំឡេងឆ្នោតគាំទ្រច្រើនលើសលប់ ។

បច្ចុប្បន្ននេះ យុវជនកម្ពុជាជំនាន់ក្រោយយល់ដឹងអំពីប្រវត្តិសាស្ត្រនៃប្រទេសរបស់ខ្លួនតាមរយៈការដំណាលប្រាប់របស់មនុស្សចាស់ៗនៅក្នុងគ្រួសារឬនៅក្នុងសហគមន៍ ។ ភាគច្រើន រឿងរ៉ាវដែលយុវជនជំនាន់ក្រោយបានឮគឺអំពីការសម្លាប់ ការធ្វើទារុណកម្ម និងការរើសអើងរវាងអ្នកក្រនិងអ្នកមាន និងរវាងអ្នកជនបទនិងអ្នកទីក្រុង ។ ឆ្អឹងលលាដ៍ក្បាលរាប់ម៉ឺនត្រូវបានរក្សាទុកនៅបូជនីយដ្ឋាននានា ដើម្បីឲ្យមនុស្សជំនាន់ក្រោយបានដឹងអំពីភាពឃោរឃៅរបស់ខ្មែរក្រហម ។ ការណ៍នេះពិតជាគួរឲ្យព្រួយបារម្ភណាស់ ព្រោះបើក្នុងអារម្មណ៍របស់ប្រជាជនគ្មានសន្តិភាពនិងសន្តិសុខទេ ការចងចាំអំពីអតីតកាលអាចបង្កជាអណ្តាតភ្លើងនៃការស្អប់ខ្ពើម កំហឹង និងការសងសឹក ។

## ៤) ការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា

មានបីចំណុចដែលគួរឲ្យចាប់អារម្មណ៍ក្នុងការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា ។ ទីមួយ គ្រួសារគឺជាកន្លែងសំខាន់ក្នុងការអប់រំកូនចៅជំនាន់ក្រោយ ។ ប្រជាជនកម្ពុជាស្ទើរតែទាំងអស់រស់នៅជាមួយឪពុកម្តាយតាំងពីពេលទើបចាប់កំណើតរហូតដល់ពេលរៀបអាពាហ៍ពិពាហ៍ ។ គ្រួសារគឺកត្តាសំខាន់បំផុតក្នុងការបណ្តុះបណ្តាលកូនចៅអំពីវប្បធម៌ ។ ទីពីរ ដោយសារតែគ្រួសារមួយចំនួនមានបន្ទុកធ្ងន់ដោយសារមានកូនចៅច្រើន កូនៗទាំងនោះគ្មានលទ្ធភាពបន្តការសិក្សានៅវិទ្យាល័យឡើយ ។ ដើម្បីធ្វើឲ្យប្រាកដថាកម្មវិធីនេះអាចផ្សព្វផ្សាយបានទូលំទូលាយ វាគួរតែគ្របដណ្តប់ទាំងសិស្សដែលមិនទាន់ចូលវិទ្យាល័យនិងសិស្សដែលមិនបានចូលវិទ្យាល័យ ។ ជាចុងក្រោយ ប្រហែល ៩៣ភាគរយនៃប្រជាជនកម្ពុជាគឺជាពុទ្ធសាសនិក ។ ព្រះពុទ្ធសាសនាបានប្រៀនប្រដៅអំពីសេចក្តីស្រលាញ់ មេត្តា ការសន្តោសអហិង្សា ខន្តី និងអំណត់ ។ កំហឹងអាចរំលត់បានដោយសេចក្តីស្រលាញ់ ។

ដូច្នេះ តើការអប់រំប្រភេទណាដែលអាចជួយប្រជាជនកម្ពុជាឲ្យរំលត់ការភ័យខ្លាចនិងកំហឹងនៅក្នុងចិត្ត? តើគួរតែដាក់បញ្ចូលប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យទៅក្នុងកម្មវិធីសិក្សាវិញដែរឬទេ?

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយថា:

*...យុវវ័យកម្ពុជាគួរតែរៀនសូត្រអំពីអតីតកាលនៃប្រទេសរបស់ខ្លួន ដើម្បីចៀសវាងការកើតឡើងវិញនូវកំហុសដដែលៗ ។ ការសិក្សាប្រវត្តិសាស្ត្រមិនមែនជាការចងគំនុំ មិនមែនជាការសងសឹក និងមិនមែនជាគំនិតមិនអភិវឌ្ឍន៍នោះទេ ប៉ុន្តែគឺជាការព្យាយាមបោះជំហានទៅមុខ ។ អ្នកណាដែលមិនមានការយល់ដឹងអំពីប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួន អ្នកនោះនឹងមានទោសដោយសារការប្រព្រឹត្តកំហុសដែលធ្លាប់កើតក្នុងអតីតកាល... ។*

ប្រជាជនកម្ពុជាមិនគួរបំភ្លេចប្រវត្តិសាស្ត្រទេ ហើយកាន់តែសំខាន់ទៀតនោះគឺគួរតែរៀនអំពីវិធីទទួលស្គាល់និងរំសាយអារម្មណ៍មិនល្អនិងការឈឺចាប់ដែលមកជាមួយនឹងការចងចាំទាំងអស់ ។ ប្រជាជនកម្ពុជាគួរតែសិក្សាអំពីអតីតកាលរបស់ខ្លួន

ដើម្បីចៀសវាងសោកនាដ្យកម្មដែលមិនគួរនឹងបណ្តោយឲ្យកើតឡើងជាថ្មីម្តងទៀតនៅពេលអនាគត ។

ខាងក្រោមនេះជាទិន្នន័យដែលមជ្ឈមណ្ឌលឯកសារកម្ពុជាស្រង់ចេញពីការស្ទង់មតិប្រជាជនកម្ពុជាទាក់ទងទៅនឹងជម្រើសក្នុងការសិក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ ÷

*សំណួរៈ តើការផ្សព្វផ្សាយប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យតាមវិធីណាដែលប្រសើរបំផុត?*

- ៦៣.៦២ភាគរយឆ្លើយថាតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដូចជា កាសែត វិទ្យុ និងទូរទស្សន៍ ។
- ៤៥.៦៥ភាគរយឆ្លើយថា បើកយុទ្ធនាការអប់រំប្រជាជនកម្ពុជាស្រទាប់ក្រោមតាមសាលារៀន ។
- ២២.៨៩ភាគរយឆ្លើយថាតាមរយៈភ្នាក់ងារឯកជនដូចជាអង្គការសិទ្ធិមនុស្សជាដើម ។
- ១៣.៦២ភាគរយឆ្លើយថាតាមរយៈភ្នាក់ងាររបស់រដ្ឋាភិបាលនៅគ្រប់ជាន់ថ្នាក់និងនៅតាមបណ្តាខេត្ត ។

យោងតាមពត៌មានដែលប្រមូលបានពីបណ្តាប្រទេសផ្សេងៗទៀត ខ្ញុំគិតថាកម្ពុជាគួរតែផ្តល់ការអប់រំអំពីសន្តិភាពក្នុងរយៈពេលបីឆ្នាំ ។ ទីមួយតាមរយៈការបញ្ចូលមុខវិជ្ជាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យនៅតាមថ្នាក់រៀន ។ ទីពីរតាមរយៈការបង្រៀនអំពីសន្តិភាពនិងការអភ័យទោសតាមផ្លូវសាសនា ។ ទីបីតាមរយៈការបង្កឱកាសឲ្យជនរងគ្រោះនិងជនដៃដល់បានពិភាក្សាគ្នា ដើម្បីចែករំលែកអារម្មណ៍ការសោកស្តាយ ការសុំអភ័យទោស និងលើកលែងទោស ។

ជាងនេះទៅទៀត វិទ្យុគឺជាប្រភពផ្តល់ពត៌មានមួយដ៏សំខាន់នៅប្រទេសកម្ពុជា ។ ស្ថានីយ៍វិទ្យុនីមួយៗអាចផលិតនិងផ្សព្វផ្សាយកម្មវិធីសន្តិភាពនិងការអប់រំសន្តិភាពតាមរយៈសាសនា ។

## ៥) មជ្ឈមណ្ឌលឯកសារកម្ពុជា

គោលដៅចម្បងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺប្រមូលចងក្រងឯកសារនៃរបបកម្ពុជាប្រជាធិបតេយ្យ និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ ដើម្បីសម្រេចបាននូវគោលដៅនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតនិងដំណើរការដោយជោគជ័យនូវកម្មវិធីជាច្រើនដូចជា ការធ្វើផែនទីរណ្តៅសាកសព ជនរងគ្រោះ ការវិភាគឆ្អឹងនិងលលាដ៍ក្បាលសាកសព ការចុះបញ្ជីឯកសារ ការបោះពុម្ពផ្សាយទស្សនាវដ្តីប្រចាំខែ ការបង្កើតកម្មវិធីវិទ្យុ ដំណើរការកម្មវិធីជំរុញឲ្យមានការទទួលខុសត្រូវ ការចងក្រងសាច់រឿងរបស់ជនរងគ្រោះដោយអំពើទារុណកម្ម និងដំណើរការសិក្សាអំពីការផ្សះផ្សាជាតិ ។

*ស្វែងរកការពិត* ជាទស្សនាវដ្តីប្រចាំខែរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបោះពុម្ពផ្សាយជាភាសាខ្មែរនិងភាសាអង់គ្លេស ។ ទស្សនាវដ្តីនេះផ្តល់ពត៌មានអំពីជីវិតរបស់ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្វែងរកយុត្តិធម៌ និងជំរុញឲ្យមានដំណើរការតុលាការមួយដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។ ដូច្នេះ ការធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតជនដៃដល់មានសារសំខាន់ក្នុងការផ្សព្វផ្សាយសេចក្តីសារភាពរបស់អតីតជនដៃដល់និងការទទួលស្គាល់របស់ជនរងគ្រោះ និងក្នុងការផ្តល់ឱកាសឲ្យជនរងគ្រោះបានបញ្ចេញសំឡេងរបស់ខ្លួន ។ តាមវិធីនេះ ទស្សនាវដ្តីស្វែងរកការពិតបានជួយព្យាបាលស្នាមរបួសរបស់ជនរងគ្រោះ ជួយរំសាយការភ័យខ្លាចរបស់ជនដៃដល់ និងផ្តល់ឱកាសឲ្យភាគីទាំងពីរយល់អំពីគ្នាទៅវិញទៅមក និងបង្កើនការទុកចិត្តគ្នា ។ បន្តិចម្តងៗការអភ័យទោសនឹងមកជំនួសការស្អប់ខ្ពើម កំហឹង និងការសងសឹក ។

ថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាទើបតែបានបង្កើតបន្ទប់ពត៌មានសាធារណៈដើម្បីបម្រើសាធារណជនសម្រាប់ការបើកវគ្គបណ្តុះបណ្តាលខ្លីៗ ការបើកអង្គប្រជុំ និងការពិភាក្សាក្នុងគោលបំណងបង្កឱកាសឲ្យសាធារណជនមានការយល់ដឹងថ្មីបានទាក់ទងជាមួយមនុស្សក្នុងមជ្ឈដ្ឋានថ្មី និងបានផ្លាស់ប្តូរទស្សនវិស័យទៅវិញទៅមក ។ នៅរៀងរាល់ថ្ងៃសៅរ៍នៃសប្តាហ៍ទីពីរនៃខែនីមួយៗ មជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ការទស្សនាដល់ភ្ញៀវដែលមកបន្ទប់ពត៌មានសាធារណៈអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងការដំណើរការដាក់ឲ្យទទួលខុសត្រូវ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានបង្កើតគម្រោងថ្មីមួយទៀតដែលមានឈ្មោះថា “ការសិក្សាអំពីការផ្សះផ្សានៅប្រទេសកម្ពុជា” សម្រាប់អ្នកដែលមានអាជីពកសាងសន្តិភាព ។ **(នៅមានត)**

**គីម កែវកន្និដ្ឋា**

# សេចក្តីថ្លែងការណ៍ស្តីអំពីការចូលជាធរមាននៃកិច្ចព្រមព្រៀងរវាង កម្ពុជានិងអង្គការសហប្រជាជាតិទាក់ទងនឹងការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ថ្ងៃទី២៩ មេសា ២០០៥

## ដោយឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមការងាររាជរដ្ឋាភិបាលសំរាប់កាត់សេចក្តីមេដឹកនាំខ្មែរក្រហម

នៅថ្ងៃ២៨ មេសា ២០០៥ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ឯកឧត្តម កូហ្វី អាណាន់ បានផ្ញើលិខិតមួយច្បាប់ជូនសម្តេច ហ៊ុន សែន ជូនពត៌មានថា តំរូវការផ្នែកច្បាប់ខាងភាគីអង្គការសហប្រជាជាតិសម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ ពេលនេះត្រូវបានបំពេញរួចហើយ ។

យោងទៅតាមមាត្រា៣២នៃកិច្ចព្រមព្រៀងបានចូលជាធរមានហើយកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ គឺមួយថ្ងៃបន្ទាប់ពីការជូនដំណឹងរបស់ឯកឧត្តម កូហ្វី អាណាន់ ដោយសារពីពេលមុន ឯកឧត្តម សុខ អាន បានផ្តល់ការជូនដំណឹងនៅក្នុងលិខិតរបស់ឯកឧត្តមចុះថ្ងៃទី១៦ វិច្ឆិកា ២០០៤ ផ្ញើជូនលោក នីកូឡាស់ មីសែល ថាតំរូវការផ្នែកច្បាប់ខាងភាគីកម្ពុជាត្រូវបានបំពេញរួចហើយ ។

សម្តេចនាយករដ្ឋមន្ត្រីបានឆ្លើយតបទៅលោកអគ្គលេខាធិការថា នៅទីបំផុតយើងបានឈានដល់ចុងបញ្ចប់នៃដំណាក់កាលរៀបចំ ហើយឥឡូវនេះយើងអាចឈានទៅអនុវត្តភារកិច្ចដែលយើងបានរង់ចាំអស់រយៈពេលជាយូរមកហើយ គឺការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងន័យនេះ ភាគីទាំងពីរបានធានាអះអាងថានឹងខិតខំប្រឹងប្រែងអស់ពីចិត្តកាយ និងត្រៀមជាស្រេចដើម្បីចាប់ផ្តើមដំណើរការជាបន្ទាន់ ។

យើងមានសេចក្តីពេញចិត្តជាខ្លាំងចំពោះលទ្ធផលនៃសន្និសីទស្តីពីការសន្យាផ្តល់វិភាគទានដែលប្រព្រឹត្តទៅនៅទីស្នាក់ការធំរបស់ អ.ស.បនាទីក្រុងញូវយ៉កកាលពីថ្ងៃទី២៨ មីនា ២០០៥ ។ ប្រទេសជប៉ុនបានផ្តល់វិភាគទានដ៏ច្រើនមហិមា គឺចំនួន២១,៦លានដុល្លារ គឺចំនួន៥០% នៃការចំណាយរបស់ អ.ស.ប នៅក្នុងគំរោងថវិកា ។

បន្ថែមលើសេចក្តីអំពាវនាវរបស់លោកអគ្គលេខាធិការរកវិភាគទានសម្រាប់អន្តរជាតិនោះ យើងសូមអំពាវនាវដល់បណ្តាប្រទេសដែលមានការចាប់អារម្មណ៍ មេត្តាជួយដល់កម្ពុជាដើម្បីបំពេញចំណែករបស់ខ្លួននៅក្នុងគំរោងដែលមានទឹកប្រាក់ចំនួន១៣,៣លានដុល្លារ ។ រាជរដ្ឋាភិបាលកម្ពុជានឹងចេញថវិកាចំនួន៦,៧លានដុល្លារ (រួមមាន១,៥ដុល្លារជាសាច់ប្រាក់ និង៥,២លានដុល្លារទៀតគឺជាការចំណាយក្រៅគម្រោង) ។ ការសន្យាផ្តល់របស់កម្ពុជានេះមានចំនួនលើសពី១០%នៃចំណាយសរុបរបស់អង្គជំនុំជម្រះវិសាមញ្ញ (៦១,៥លានដុល្លារ គឺ៥៦,៣លានដុល្លារក្នុងគំរោងបូកនឹង៥,២លានដុល្លារជាការចំណាយក្រៅគំរោង) ។

ប្រទេសជាច្រើនបានសំដែងឲ្យឃើញថា ពួកគេនឹងផ្តល់វិភាគទានទៅភាគីដើម្បីជួយបង្គ្រប់ចំនួនសរុបនៃការចំណាយរបស់ភាគីកម្ពុជា ហើយនឹងសង្ឃឹមថានឹងអាចធ្វើការជូនដំណឹងអំពីលទ្ធផលនៃកិច្ចការនេះក្នុងរយៈពេលដ៏ខ្លី ។ ខ្ញុំសូមគូសបញ្ជាក់ថា ចំណែកទាំងសងខាងនៃថវិកាមានសារសំខាន់ដូចគ្នាចំពោះភារកិច្ចដ៏ធ្ងន់ធ្ងរក្នុងការបង្កើតដំណើរការត្រឹមត្រូវដែលប្រកបដោយស្តង់ដារអន្តរជាតិ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឥស្សរជននិងអង្គការទាំងឡាយទាំងនៅក្នុងកម្ពុជានិងនៅជុំវិញពិភពលោកដែលបានខិតខំធ្វើការដោយឥតគិតនឿយហត់ដើម្បីស្វែងរកយុត្តិធម៌ក្នុងបុព្វហេតុនេះអស់រយៈកាលជាង២៥ឆ្នាំហើយ ។

យើងមានជំនឿយ៉ាងមាំថា រូបមន្តដែលយើងបានឯកភាពគ្នាដើម្បីបង្កើតឡើងនេះមិនត្រឹមតែបំពេញសេចក្តីត្រូវការយុត្តិធម៌របស់ប្រទេសយើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយដំណើរការទូទៅនៃការកែទម្រង់ច្បាប់និងយុត្តិធម៌ផងដែរ ដោយផ្តល់នូវតុលាការគំរូមួយដែលមានស្តង់ដារអន្តរជាតិ ។ ម្យ៉ាងទៀតយើងជឿជាក់ថា គំរូកម្ពុជាអាចផ្តល់ជាគំនិតយោបល់សំរាប់ប្រទេសផ្សេងៗទៀត

ក្នុងការស្វែងរកយុត្តិធម៌របស់ខ្លួន ។

ពេលនេះ នៅពេលដែលយើងរៀបនឹងចាប់ផ្តើមបង្កើតអង្គជំនុំជម្រះវិសាមញ្ញគឺជាពេលវេលាសំរាប់ប្រជាជនកម្ពុជាគ្រប់រូបនិងអ្នកដែលស្នេហាយុត្តិធម៌នៅទូទាំងពិភពលោកត្រូវខិតខំឲ្យអស់ពីចិត្តកាយ ដើម្បីធ្វើឲ្យដំណើរការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមទទួលបានជោគជ័យ ទោះបីពីពេលមុនយើងធ្លាប់មានយោបល់ខុសៗគ្នាអំពីថាតើទម្រង់នៃតុលាការកាត់សេចក្តីបុគ្គលៈកម្មការមួយណាដែលសមស្របបំផុត ។ យើងសន្យារួមសហការគ្នាឈានទៅរកគោលដៅនេះដោយចាត់ទុកថាការប្តេជ្ញាចិត្តរបស់យើងសម្រាប់ឆ្នាំខាងមុខ ។

មួយជំនាន់មនុស្សកន្លងផុតទៅហើយរាប់ពីពេលបទឧក្រិដ្ឋទាំងនោះត្រូវបានប្រព្រឹត្ត ។ យើងមិនគួរបណ្តោយឲ្យពេលវេលានេះបាត់បង់តទៅទៀតទេ ។ ខ្ញុំអាចធានាអះអាងថា រាជរដ្ឋាភិបាលកម្ពុជានឹងខិតខំអស់ពីចិត្តកាយ ដើម្បីធានាឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើមដំណើរការក្នុងពេលឆាប់រហ័សដែលអាចធ្វើទៅបាន និងប្រកបដោយស្តង់ដារអន្តរជាតិដែលភាគីទាំងសងខាងបានឯកភាពគ្នានិងដើម្បីឆ្លើយតបចំពោះសេចក្តីត្រូវការយុត្តិធម៌របស់ប្រជាជនកម្ពុជានិងមនុស្សជាតិទូទៅ ។ រាជធានីភ្នំពេញ, ថ្ងៃទី០៣ ឧសភា ២០០៥

## កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញ បានចូលជាធរមានហើយ

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញសម្រាប់កាត់សេចក្តីមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ បានចូលជាធរមានកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ដែលនេះជាការត្រួសត្រាយផ្លូវសម្រាប់អង្គជំនុំជម្រះវិសាមញ្ញដើម្បីចាប់ផ្តើមដំណើរការរបស់ខ្លួន ។

អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានជូនដំណឹងដល់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងលិខិតមួយកាលពីថ្ងៃម្សិលមិញថា អង្គការសហប្រជាជាតិបានបញ្ចប់កាតព្វកិច្ចតាមផ្លូវច្បាប់របស់ខ្លួនដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងដែលអនុម័តដោយមហាសន្និបាតកាលពីឆ្នាំ២០០៣រួចហើយ ។ កម្ពុជាបានផ្ញើសេចក្តីជូនដំណឹងរបស់ខ្លួនទៅជូនអង្គការសហប្រជាជាតិកាលពីខែវិច្ឆិកា ។

បើយោងតាមសេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិ ឥឡូវនេះការសន្យាឧបត្ថម្ភថវិកាមានគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ដល់អង្គជំនុំជម្រះវិសាមញ្ញទាំងពីរថ្នាក់នៅក្នុងប្រព័ន្ធយុត្តិធម៌ដែលមានស្រាប់ ដែលក្នុងនេះអង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូងនឹងជំនុំជម្រះជនសង្ស័យពីបទសម្លាប់ជនស៊ីវិលរាប់លាននាក់នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ និងអង្គជំនុំជម្រះនៃតុលាការកំពូលដើម្បីជំនុំជម្រះបណ្តឹងសាទុក្ខ ហើយអង្គជំនុំជម្រះទាំងពីរថ្នាក់នេះនឹងមានដំណើររបស់ខ្លួននៅក្នុងរយៈពេលកំណត់មួយ ។

ថវិកាដែលនឹងត្រូវចំណាយសម្រាប់រយៈពេល៣ឆ្នាំរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺប្រមាណជា៥៦,៣លានដុល្លារ ដែលក្នុងនេះ៤៣លានដុល្លារជាបន្ទុករបស់អង្គការសហប្រជាជាតិ និង១៣,៣លានដុល្លារជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជា ។ សន្និសីទរៃអង្គាសថវិការបស់អង្គការសហប្រជាជាតិដើម្បីឧបត្ថម្ភដល់ដំណើការរបស់អង្គជំនុំជម្រះវិសាមញ្ញកាលពីខែកន្លងទៅ ប្រមូលថវិកាបានប្រមាណ៣៨,៥លានដុល្លារនៃចំនួនថវិកាដែលជាចំណែកទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិ ។

សេចក្តីថ្លែងការណ៍នោះបានសរសេរថា “អគ្គលេខាធិការអង្គការសហប្រជាជាតិបានអះអាងសាជាថ្មីទៀតថា អង្គការសហប្រជាជាតិទន្ទឹងរង់ចាំមើលការអនុវត្តដែលរហ័សនិងមានប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងនោះ ហើយអង្គការសហប្រជាជាតិនឹងមិនព្រងើយកន្តើយចំពោះកិច្ចខិតខំប្រឹងប្រែងណាមួយដែលអាចជួយធានាថាអង្គជំនុំជម្រះវិសាមញ្ញនិងស្ថាប័នពាក់ព័ន្ធរបស់វានឹងត្រូវបានបង្កើតឡើងក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន និងថាអង្គជំនុំជម្រះវិសាមញ្ញនឹងអាចចាប់ផ្តើមដំណើរការក្នុងពេលឆាប់ៗខាងមុខនេះ ។ ការរៀបចំរដ្ឋបាលនៅក្នុងកំពុងតែដំណើរការ” ។

**ប្រែសម្រួលពី** *UN News Center*

**ដោយ ឌី ធេរិទ្ធ**

# ឪពុកខ្ញុំ

### *ឆ្នាំ១៩៧៤*

*ពេលនោះខ្ញុំមានអាយុ៤ឆ្នាំ ។ ថ្ងៃមួយ ខ្ញុំអង្គុយនៅរានហាលមុខផ្ទះតែម្នាក់ឯង ពុំមានអ្នកណានៅផ្ទះជាមួយខ្ញុំឡើយ ។ ស្នូរគ្រាប់កាំភ្លើងផ្ទុះ ផាំងៗ! ហោះវឺតៗមកប៉ះនឹងជញ្ជាំងផ្ទះ ។ យន្តហោះក្រឡឹងទៅមកៗលើដំបូលផ្ទះខ្ញុំឡើងរញ្ជួយញដី ។ ខ្ញុំភ័យខ្លាំងណាស់ ។ ខ្ញុំរត់ឆ្វេឆ្វាចុះឡើងៗរកមើលពុកនិងម៉ែ ។ ពេលនោះពុកនិងម៉ែក៏មកដល់ ។ ពីរបីថ្ងៃក្រោយមក ក្រុមគ្រួសារខ្ញុំរៀបចំអីវ៉ាន់រត់ចូលទីរួមខេត្តកំពត ។ ម្តាយខ្ញុំនិយាយថា កងទ័ព លន់ណុល ចុះចាញ់ខ្មែរក្រហមហើយ ។*

*ក្រុមគ្រួសារខ្ញុំរស់នៅក្នុងខេត្តកំពតបានប្រហែលបីខែ កងទ័ពខ្មែរក្រហមដណ្តើមកាន់កាប់បានខេត្តកំពតទាំងមូល ។ ខ្ញុំឃើញកងទ័ពពាក់ខោអាវខ្មៅបណ្តេញប្រជាជនចេញពីទីរួមខេត្ត ដោយប្រាប់ថាចេញតែបីថ្ងៃទេត្រឡប់មកវិញហើយ មិនចាំបាច់យករបស់របរទៅច្រើនពេកទេ ជាពិសេសស្បៀងអាហារ ពីព្រោះអង្គការនឹងខបត្តម្ភ ។ «ចេញទៅៗ! ចេញឲ្យលឿនទៅ!» ។ ទិដ្ឋភាពប្រជាជនជម្លៀសចេញពីទីរួមខេត្តមើលទៅអ៊ូអរនិងរញ៉េរញ៉ៃណាស់ ។ ខ្លះអូសរទេះ ខ្លះរែកកូនរែកចៅ ខ្លះដឹកដៃអ្នកជំងឺនិងចាស់ជរា ។ អ្នកជំងឺមួយចំនួនមានព្យួរសេរ៉ូមជាប់នឹងដៃដេកលើរទេះ ។ ជនពិការជាច្រើននាក់ ខ្លះរំកិលគូថតាមចិញ្ចើមថ្នល់ ខ្លះកាន់ឈើច្រត់ដើររញេរញ៉័រទាំងត្រដាបត្រដួស ។ ឪពុកមានិងជីតាខ្ញុំក៏កំពុងតែមានជំងឺ ។ ជីដូនខ្ញុំដែលខ្វិនដើរមិនរួចបានរំកិលគូថតាមចិញ្ចើមថ្នល់ ។ កងទ័ពអាវខ្មៅយកកាំភ្លើងភ្ជង់អ្នកជំងឺ ហើយពោលពាក្យគំរោះគំរើយគួរឲ្យស្អប់ ។*

*ការធ្វើដំណើរកាន់តែឆ្ងាយ ការវិលវិញក៏គ្មាន ភាពវេទនារបស់ប្រជាជនកាន់តែខ្លាំងឡើងៗ ។ នេះជាថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ។*

*បីថ្ងៃក្រោយមក ក្រុមគ្រួសារខ្ញុំបានទៅដល់ស្រុកកំពង់ត្រាច ឃុំកោះស្តៅ ខាងកើតវត្តភ្នំសាឡី ។ ពេលនោះបងប្រុសទីមួយរបស់ខ្ញុំត្រូវបែកពីក្រុមគ្រួសារ ព្រោះគាត់ជានិស្សិតរបស់លោក រស់ សាវង្ស អភិបាលខេត្តកំពត ។ ម្តាយឪពុកខ្ញុំខ្វល់ខ្វាយយ៉ាងខ្លាំង ។*

*មួយខែកន្លះក្រោយមក អង្គការបានប្រកាសឲ្យប្រជាជនវិលទៅស្រុកកំណើតវិញ ។ ម្តាយឪពុកខ្ញុំអរខ្លាំងណាស់ នាំគ្នារៀបចំអីវ៉ាន់ដាក់រទេះក្របី បងប្រុសខ្ញុំបីនាក់រែកអង្រែកម្នាក់មួយវិលមកស្រុកកំណើតតាមពាក្យអង្គការប្រកាស ។ ធ្វើដំណើរមកដល់ផ្លូវចូលវត្តកំពង់នង់ អង្គការប្រាប់ថាមិនអាចវិលមកផ្ទះវិញបានទេ ពីព្រោះតំបន់នោះគ្មានមនុស្សរស់នៅ អង្គការមិនទទួលខុសត្រូវទេ ។ ក្រុមគ្រួសារខ្ញុំនិងប្រជាជនជាច្រើនទៀតបានធ្វើដំណើរតាមបញ្ជារបស់អង្គការមកដល់ភូមិត្រពាំងកក់ក្នុងឃុំកូនសាត់ ស្រុកកំពត ខេត្តកំពត ។ យើងបានជម្រះស្មៅសង់កូនខ្ទមតូចមួយដែលមានបណ្តោយ៤ម៉ែត្រនិងទទឹង៣ម៉ែត្រ ប្រក់ស្បូវ ជញ្ជាំងបាំងដោយធាងដូង នៅលើទួលខ្ពស់មួយនៅកណ្តាលព្រៃ ។ យើងរស់នៅជួបជុំគ្នា ។ ពេលនោះខ្ញុំមានអារម្មណ៍កក់ក្តៅជាងមុនបន្តិច ។*

*បួនខែក្រោយមក អង្គការឲ្យបងប្រុសទីពីររបស់ខ្ញុំចូលកងចល័តនៅកោះស្លា ចំណែកបងប្រុសទីបីចូលកងចល័តមើលគោ ។ ខ្ញុំនៅផ្ទះជាមួយបងស្រីទីប្រាំមួយនិងជីតារបស់ខ្ញុំដែលមានអាយុ៨៥ឆ្នាំ ។ ឪពុករបស់ខ្ញុំត្រូវទៅយាមចម្ការនៅលើភ្នំរាបដែលមានចម្ងាយពីផ្ទះ៣គីឡូម៉ែត្រ ។ គាត់យាមតែម្នាក់ឯងប៉ុណ្ណោះ ។ ម្តាយខ្ញុំត្រូវទៅធ្វើការតាំងពីម៉ោង៥ភ្លឺរហូតដល់ម៉ោង១១ថ្ងៃត្រង់ទើបហូបបបរមួយវែកហើយត្រឡប់មកផ្ទះ ។ ខ្ញុំត្រេកអរខ្លាំងណាស់ពេលបានឃើញមុខម៉ែម្តងៗ ។ ម៉ោង១២កន្លះ ម្តាយខ្ញុំត្រូវត្រឡប់ទៅធ្វើការវិញ ។*

*ពីរខែក្រោយមក ជីតាខ្ញុំធ្លាក់ខ្លួនឈឺជាទម្ងន់ដោយសារខ្វះចំណីអាហារ ។ គាត់គ្រុនរើរវាយ ។ អង្គការបញ្ជូនគាត់ទៅព្យាបាលនៅមន្ទីរពេទ្យវត្តកូនសាត់នៅថ្ងៃ១៥កើតខែចេត្រ*

ឆ្នាំ១៩៧៦ ។ ម្តាយខ្ញុំសុំច្បាប់គណៈកងដើម្បីទៅមើលជីតាខ្ញុំនៅមន្ទីរពេទ្យ ។ គណៈកងឆ្លើយថា "មីងមិនបាច់ទៅមើលទេ មីងមិនមែនជាពេទ្យទេ អង្គការមានពេទ្យហើយ" ។ រសៀលម៉ោង៤ថ្ងៃដដែល មានមនុស្សមកប្រាប់ម្តាយខ្ញុំថា ជីតាខ្ញុំស្លាប់ហើយ ។ ម្តាយខ្ញុំមកមើលសពជីតាខ្ញុំនៅមន្ទីរពេទ្យ ។ កម្មាភិបាលពេទ្យបញ្ជាឲ្យយកសពជីតាខ្ញុំទៅបញ្ចុះនៅម៉ោង៥ល្ងាចថ្ងៃដដែល ។

មួយខែកន្លងផុតទៅ ម្តាយខ្ញុំធ្លាក់ខ្លួនឈឺធ្ងន់ ។ គាត់ត្រូវអង្គការបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។ បងស្រីខ្ញុំអាយុ៩ឆ្នាំបានទៅថែទាំម្តាយខ្ញុំនៅមន្ទីរពេទ្យ ។ ពេលនោះបងស្រីឈឺក្បាលក្តៅខ្លួន ចង់ក្អួតចង្អោរ ម្តាយខ្ញុំប្រាប់ពេទ្យ ពេទ្យក៏យកថ្នាំមកចាក់បងខ្ញុំឲ្យមួយម្ជុល ហើយយកសេរ៉ូមមកព្យួរឲ្យគាត់ ។ បួនម៉ោងក្រោយមកអស់សេរ៉ូមពីថ្លោក បងស្រីខ្ញុំបញ្ឈរភ្នែកហៅលែងឆ្លើយ ។ គាត់បានស្លាប់បាត់ទៅហើយ ។ ឪពុកខ្ញុំយំខ្សឹកខ្សួលឱបសពបងស្រីខ្ញុំខ្ទប់នឹងដើមទ្រូង ។ ម្តាយខ្ញុំហាមមិនឲ្យពុកយំទេព្រោះខ្លាចអង្គការឃើញ ប៉ុន្តែម៉ែខ្លួនឯងក៏មិនអាចទប់ទឹកភ្នែកបានដែរ ។ ទឹកភ្នែកម៉ែហូរតិចៗ គាត់ជូតចេញយ៉ាងរហ័ស ។

ទឹកភ្នែកខ្ញុំហូរឥតឈប់ ។ ខ្ញុំបាត់បង់បងស្រីមួយហើយ ។ ប៉ុន្មានថ្ងៃក្រោយមក ម្តាយខ្ញុំជាសះស្បើយពីជំងឺហើយវិលមកត្រពាំងកក់វិញ ។ ម្តងនេះខ្ញុំកាន់តែឯកោខ្លាំងឡើង ។ វេលាយប់ប្រហែលម៉ោង១០ ខ្ញុំដេកពីរនាក់ម្តាយខ្ញុំ ស្រាប់តែឮស្នូរអ្វីមួយប៉ះនឹងជញ្ជាំងប្រោកៗ ខ្ញុំញ័រខ្លួនទទ្រើក ស្ទុះទៅឱបម៉ែជាប់ ។ ម៉ែនិយាយទាំងញ័រៗ "កុំខ្លាចកូន កុំខ្លាចអី ជ្រូកព្រៃកំពុងឈ្ងុសដំឡូងយើងទេ" ។ មួយសន្ទុះក្រោយខ្ញុំដឹងខ្លួនម្តងទៀតយកដៃរាវរកម្តាយខ្ញុំ ប៉ុន្តែមិនប៉ះគាត់សោះ ។ បេះដូងខ្ញុំលោតឌឹបៗ ខ្ញុំក៏ប្រឹងស្ទុះងើបឡើងទើបដឹងថាខ្ញុំដេកនៅក្រោមរាន ពុំដឹងធ្លាក់ពីលើរានតាំងពីពេលណា ។ ចុងដៃចុងជើងខ្ញុំត្រជាក់ស្រេប ខ្ញុំអរខ្លាំងណាស់ពេលរាវទៅប៉ះម៉ែ ហើយក៏លង់លក់បន្តទៀត ។

ម៉ោងប្រាំម្តាយខ្ញុំត្រូវចេញទៅធ្វើការ ។ ខ្ញុំនឹកគាត់ មិនចង់ឲ្យគាត់ឃ្លាតឆ្ងាយពីខ្ញុំទេ ។ ខ្ញុំយំរត់តាមម្តាយ ខ្ញុំចង់ទៅធ្វើការដែរ ប៉ុន្តែម្តាយខ្ញុំអង្វរថា "កូនស្រីម៉ែ កូននៅផ្ទះកុំតាមម៉ែអី កន្លែងធ្វើការឆ្ងាយណាស់ បន្តិចទៀតម៉ែមកវិញហើយ កូនស្រីម៉ែអាណិតម៉ែណា៎ កូនម៉ែល្អណាស់" ។ ទឹកភ្នែកខ្ញុំហូរតក់ៗ ដើរយឺតៗត្រឡប់ក្រោយវិញទាំងសោកសង្រេង ។ មកដល់ផ្ទះវិញ ខ្ញុំឈរលើកដៃសំពះទៅទិសខាងកើតដែលមានភ្នំមួយធំខ្ពស់ហើយមានសត្វទោចយំរាល់ថ្ងៃ ។ ខ្ញុំបន់ថា "សត្វទោចអើយឆាប់យំទៅ ឆ្អាលម៉ែខ្ញុំត្រឡប់មកវិញ" ។ ទោះខ្ញុំខំបន់ស្រន់យ៉ាងណាក៏សត្វទោចមិនយំដែរ ។ ដល់ម៉ោង១០ទើបសត្វទោចចាប់ផ្តើមយំ ខ្ញុំអរខ្លាំងណាស់ ប៉ុន្តែរហូតដល់ម៉ោង១១កន្លះទៅហើយ នៅតែមិនឃើញម្តាយខ្ញុំមកវិញ ។ ពេលនោះទឹកភ្នែកខ្ញុំហូរទៀតហើយ ។ ខ្ញុំក្រឡេកមើលទៅទិសឥសានឃើញមនុស្សស្រីម្នាក់ពាក់ដូនសៗ ខ្ញុំអរស្ទើរហើបជើងពីដី ។ ខ្ញុំរត់ទាញទៅឱបម្តាយភ្លាម ។ ម៉ែសួរខ្ញុំថា "ហេវទេកូន? ថ្ងៃនេះរោងបាយខ្វះបបរ គេចែកដំឡូងមីស្ងោរឲ្យម្នាក់ប៉ុនមេជើងមួយចំអាមប៉ុណ្ណោះ ។ ហូបទៅកូន" ។ ពេលនោះឪពុកខ្ញុំមកដល់ល្មម ។ ពុកនិយាយថា "ពុកហេវណាស់ ឲ្យពុកសុំដំឡូងនេះមក" ។ ពុកលូកដៃមករកខ្ញុំ ប៉ុន្តែម៉ែស្តីឲ្យពុកថា "កុំសុំវា! យើងចាស់អាចទ្រាំបាន វាក្មេងទ្រាំមិនបានទេ" ។ ទឹកភ្នែកពុកហូរធ្លាក់មកលើថ្ពាល់តក់ ហើយទឹកភ្នែកខ្ញុំក៏ហូរដែរ ប៉ុន្តែខ្ញុំមិនបានឲ្យដំឡូងទៅពុកទេ ។ ពុកខាំធ្មេញក្រឹតៗ ។ គាត់គ្រវីក្បាលមិននិយាយអ្វីមួយម៉ាត់សោះ ។

មួយខែកន្លងផុតទៅ ។ ថ្ងៃមួយ ខ្ញុំដើរពីរនាក់ ប៉ាត់ (ប្អូនជីទួតមួយខ្ញុំ) ។ ប៉ាត់ មានអាយុ៥ឆ្នាំ ។ ប៉ាត់ បបួលខ្ញុំថា "តោះ! យើងទៅកាច់ពោតម្នាក់មួយ" ។ ខ្ញុំឆ្លើយថា "ខ្ញុំខ្លាចណាស់ ខ្ញុំមិនហ៊ានទៅទេ" ។ ប៉ាត់ ធានាថា "មិនអីទេ ខ្ញុំជាអ្នកកាច់" ។ កាច់រួចខ្ញុំលាក់ផ្លែពោតនៅក្បែរភ្លឺស្រែ រួចហើយយើងទាំងពីរនាក់ធ្វើជាទៅដងទឹកឲ្យយាយរបស់ ប៉ាត់ ។ ពេលដែលយើងត្រឡប់មកវិញឃើញអ្នកយាមចម្ការពោតអង្គុយចាំកន្លែងដែលខ្ញុំលាក់ផ្លែពោត ។ ពេលនោះ ប៉ាត់ និងខ្ញុំ មិនខ្លាចទេ ព្រោះគិតថាយើងលួចពោតតែមួយផ្លែប៉ុណ្ណោះ ។ អ្នកចាំចម្ការកាន់ពោតនៅក្នុងដៃជាស្រេច ហើយសួរយើងទាំងពីរនាក់ថា "ឯងទាំងពីរនាក់លួចកាច់ពោតមែនទេ? អញនឹងយករឿងនេះទៅប្រាប់អង្គការ" ។ យើងទាំងពីរនាក់នៅស្ងៀម ហើយដើរចេញទៅ ។ ខ្ញុំអង្គុយម្នាក់ឯងនៅក្នុងខ្ទម ។ ថ្ងៃកាន់តែទាបទៅៗ ម៉ោង៧មេឃក៏ងងឹត ខ្ញុំភ័យខ្លាំងណាស់ព្រោះមិនឃើញម៉ែត្រឡប់មកវិញ ។ សត្វ

មៀមយំ ចាក់ហ៊ីវៗ! លើក្បាលដំណេករបស់ខ្ញុំ ។ ខ្លួនខ្ញុំញ័រទទ្រើក ។ ក្នុងមួយជីវិតនេះខ្ញុំខ្លាចសត្វមៀមជាទីបំផុត ។ ភាពងងឹតសូន្យសុងរកចាក់ភ្នែកមិនយល់ ទឹកភ្នែកខ្ញុំហូររហាម ។ ខ្ញុំស្រែកហៅម៉ែតិចៗ "ម៉ែ! ម៉ែនៅឯណា?" ដៃខ្ញុំទាំងពីររាវរកបានភួយស្បៃងជីខ្សាច់កញ្ចាស់មួយមករុំខ្លួនយ៉ាងណែន ។ ភ្លៀងក៏ធ្លាក់ផ្គររន្ទះដាំងជះពន្លឺតាមជញ្ជាំងដែលរហែករយ៉ៃ ។ ភួយនោះហាក់ផ្តល់ភាពកក់ក្តៅដល់ខ្ញុំ ។ ខ្ញុំខាំមាត់គិតក្នុងចិត្តថា "ម៉ែដេកក្បែរនេះទេ កុំខ្លាចឲ្យសោះ" ។ ខ្ញុំក៏លង់លក់ដោយអស់កម្លាំងនិងហេវហត់ ។ បន្តិចក្រោយមកមានដៃមួយរាវថ្នមៗមកប៉ះខ្លួនរបស់ខ្ញុំ "ញ៉ាញ់ៗ ក្រោកឡើងកូន មកហូបបបរ ម៉ែដើរជើពប់ជើងនឹងផ្លូវខ្មោចកំពប់បបរជិតអស់ នៅសល់តែបន្តិចប៉ុណ្ណោះ" ។ ខ្ញុំស្ទុះងើបឡើងទទួលថ្ពិលបបរពីម៉ែហើយលើកហុតដូចទឹកបានពីរបីក្អឹកក៏អស់ទៅ ។ ម៉ែសួរខ្ញុំថា "ឯងលួចកាច់ពោតមែនទេ?" ខ្ញុំឆ្លើយថា "ចា៎!" ម៉ែបន្តថា "តាសាន តាទុយ និងកម្មាភិបាលជាច្រើនទៀត បានហៅប្រជាជនទូទាំងរោងបាយមកប្រជុំទិតៀនពីរឿងឯងក្បត់សមូហភាព ក្បត់អង្គការបក្ស ហើយឲ្យប្រជាជនទាំងអស់ (ប្រហែលជិតពីរយនាក់) កាត់ក្តី ។ បើមិនឆ្លើយអង្គការមិនឲ្យហូបបបរទាំងអស់គ្នា" ។ នៅក្នុងអង្គប្រជុំនោះ ឪពុកខ្ញុំបានស្ទុះក្រោកឈរឡើងតវ៉ា ប៉ុន្តែត្រូវម្តាយខ្ញុំចាប់គោងអាវគាត់ជាប់មិនឲ្យនិយាយអ្វីទាំងអស់ ។ ម្តាយខ្ញុំក្រោកឈរឡើងនិយាយ "ខ្ញុំសុំសារភាពទទួលកំហុស ហើយសន្យាថានឹងប្រដៅកូនបន្ថែមទៀត ព្រោះវានៅក្មេងទើបតែមានអាយុ៦ឆ្នាំប៉ុណ្ណោះ ខ្ញុំមិនឲ្យមានជាលើកទី២ទៀតទេ" ។ តាសាន និងកម្មាភិបាលទាំងអស់ងក់ក្បាលទាំងសោះកក្រោះ ហើយរំសាយប្រជាជនឲ្យទៅហូបបបរទាំងអស់គ្នា ។ ពេលនោះម៉ោងប្រហែលជិត១១អធ្រាត្រ ។

ពីរបីថ្ងៃក្រោយមក ពុកឡើងភ្នំទាំងយប់ដើម្បីយាមចម្ការ ។ គាត់ដឹកដៃខ្ញុំដើរតាមភ្លឺស្រែកាត់មុខផ្ទះ តាសាន ដើរបណ្តើរនិយាយបណ្តើរថា "កូនស្រីមាសឪពុក បើថ្ងៃណាមួយបាត់ពុក កូនកុំយំរកពុកឲ្យសោះណា៎ កូនត្រូវថែរក្សាខ្លួនដឹងទេ" ។ ពុកនិយាយបណ្តើរអង្អែលក្បាលខ្ញុំបណ្តើរ ។ ខ្ញុំសម្លឹងមុខពុកឃើញទឹកភ្នែករមៀលធ្លាក់លើថ្ពាល់របស់គាត់ ខ្ញុំរលីងរលោងទឹកភ្នែកហើយឆ្លើយ "ចា៎" ។ បន្ទាប់មកយើងទាំងពីរនាក់អួលដើមកនិយាយតទៅទៀតលែងរួច ។ បីថ្ងៃក្រោយមក ពុកមកផ្ទះដើម្បីដឹកក្របីឲ្យស៊ីស្មៅ ។ ពុកនិយាយជាមួយខ្ញុំថា "កូនមាសឪពុក កូននៅកន្លែងហ្នឹងហើយ ពុកទៅនោះមួយភ្លែត កុំយំរកពុកណា៎" ។ ប្រហែលប្រាំនាទីក្រោយមក ខ្ញុំស្រែកហៅ "ពុក! ពុក!" ។ មិនឮពុកឆ្លើយសោះ ។ ខ្ញុំទ្រហោយំមួយរំពេច ។ ខ្ញុំខ្លាចបាត់ពុកណាស់ ។ រំពេចនោះពុកក៏ចេញមកវិញ ដៃកាន់ផ្លែត្របែកពីរបីហុចឲ្យខ្ញុំ ។ ខ្ញុំអរណាស់ជូតទឹកភ្នែកចេញ ហើយហូបផ្លែត្របែកយ៉ាងសុខសាន្តបំផុត ។

បីខែក្រោយ ក្នុងឆ្នាំ១៩៧៧ អង្គការប្រកាសថា "ប្រជាជនទាំងអស់ត្រូវប្តូរទីលំនៅទៅក្រោម គឺទៅភូមិតស៊ូ ឃុំកូនសាត់ ស្រុកកំពត" ។ ពុកដឹកក្របី ម៉ែរែកអីវ៉ាន់បន្តិចបន្តួចសល់ពីអង្គការដកហូត ខ្ញុំយួរកន្ត្រកមួយទាំងមិនដឹងថាមានអ្វីខ្លះនៅក្នុងនោះផង ។

អង្គការប្រកាសដាច់ខាតមិនឲ្យប្រជាជនណាយឺតយ៉ាវហួសពីថ្ងៃនេះឡើយ ។ បើនរណាចេញមិនទាន់ អង្គការចាត់ទុកថាជាខ្មាំង ។ ពេលនោះមានមនុស្សចាស់ជរានិងអ្នកជំងឺមួយចំនួនដែលគ្មានកូនចៅជួយ ត្រូវអង្គការសម្លាប់ចោលភ្លាមៗ ។ រសៀលម៉ោង៤ ក្រុមគ្រួសារខ្ញុំមកដល់ភូមិតស៊ូ ។ យើងរស់នៅរួមគ្នាក្នុងរោងវែងមួយដែលមានប្រជាជនប្រហែល២០គ្រួសារ ។ ម្តងនេះខ្ញុំមានអារម្មណ៍អាប់អួរណាស់ ។ បងប្រុសទីពីររបស់ខ្ញុំមិនបានមកជាមួយយើងទេ ព្រោះគាត់ជាប់រវល់ឃ្វាលគោ ។

បីថ្ងៃក្រោយ ម្តាយខ្ញុំសួរប្រធានក្រុមឈ្មោះ លី ថា "ពូ! ម៉េចមិនឃើញកូនប្រុសខ្ញុំមក? វានៅឯណា?" លី ឆ្លើយទាំងព្រងើយថា "ខ្ញុំមិនដឹងទេ ខ្ញុំឲ្យមកពីរបីថ្ងៃហើយ អីឯងមិនឃើញទេឬ?" ។ គ្រាន់តែឮពាក្យបែបនេះម៉ែឱនមុខចុះហើយដើរចេញទាំងទឹកភ្នែកដាមពេញរង្វង់ភ្នែក ។ ម៉ែខាំមាត់មិនហ៊ានយំឲ្យអ្នកណាឃើញឡើយ ។ ម៉ែនិយាយប្រាប់ខ្ញុំទាំងអួលដើមកថា "បងអិនរបស់ឯងត្រូវអង្គការសម្លាប់ហើយ" ។ ទឹកភ្នែកខ្ញុំដាមពេញរង្វង់ភ្នែក ខ្ញុំទន់ដៃទន់ជើងស្ទើរឈរមិននឹង ។ ម្តាយខ្ញុំឱបខ្ញុំជាប់ មិននិយាយអ្វីមួយម៉ាត់ ។ ក្នុងចិត្តខ្ញុំគិតថា "ឱ! បងប្រុសជាទីស្រលាញ់របស់ខ្ញុំអើយ ស្លាប់ចោលខ្ញុំម្នាក់ទៀតហើយ" ។

**ឪពុករបស់ខ្ញុំ**

ព្រលឹមស្រាងៗ ពុកលីនង្គ័លនិងរនាស់ព្រមទាំងដឹកក្របីទៅភ្ជួរ ដល់ម៉ោង១១ ទើបអង្គការឲ្យសម្រាកហូបបបរពីរវែក ។ ហូបរួចត្រូវទៅមើលក្របីស៊ីស្មៅ ។ ម៉ោង១ចុះភ្ជួរម្តងទៀត ។

ធ្វើការយ៉ាងនេះរាល់ថ្ងៃ ចំណីអាហារក៏គ្មាន មិនយូរប៉ុន្មានជើងទាំងពីររបស់ពុកឡើងតឹងហើមស្មើរចេញទឹក ។ ពុកស្ពឹកជើងដើរមិនចង់រួច គាត់សុំប្រធានកងឈប់សម្រាកបន្តិចដើម្បីកុំឲ្យហើម ។ ប្រធានកងនិងកម្មាភិបាលក៏សម្រេចឲ្យពុកទៅសម្រាកព្យាបាលនៅពេទ្យវត្តកូនសាត់ ។ ព្រលឹមស្រាងៗពុករៀបចំខោអាវមួយកំប្លេ កំសៀវមួយ ចានមួយ ស្លាបព្រាមួយ រួចចេញទៅ ។ អង្គការមិនឲ្យម្តាយខ្ញុំនិងខ្ញុំជូនដំណើរពុកឡើយ ព្រោះម៉ែមានភារកិច្ចចុះស្ទូងឲ្យបានមុនម៉ោង៥កន្លះ ដើម្បីប្រឡងប្រណាំងយកក្រុមគំរូ ។ ស្ទូងបណ្តើរ ម៉ែរើសក្តាមខ្យងបណ្តើរបានប្រហែលពីរថ្នក់អាវ ។

ស្អែកឡើងម៉ែមិនទៅស្ទូងទេ ។ ម៉ែសុំមេកងសម្រាកមួយព្រឹកដើម្បីទៅមើលពុកនៅពេទ្យ ។ ម៉ោង៥កន្លះ ម៉ែងើបឡើងស្ងោរខ្យងក្តាមរួចដាក់ក្នុងកំប៉ុងមួយយកទៅផ្ញើពុក ។ ម៉ែមិនឲ្យខ្ញុំហូបទេ ។ ថ្ងៃចាប់ផ្តើមរះ យើងទាំងពីរនាក់ចេញដំណើរ ។ ដើរដល់ពាក់កណ្តាលផ្លូវយើងបានជួបយាយធឹម ។ គាត់ប្រាប់ម៉ែថា "ប្តីឯងគេឲ្យទៅដេកពេទ្យតំបន់តាំងពីម៉ោង៤ល្ងាចម្សិល មានរទេះគោដឹកទៅផងព្រោះគាត់ដើរមិនរួច" ។ យាយធឹមនិងម៉ែសុទ្ធតែដឹងថា បើអង្គការបញ្ជូនទៅពេទ្យតំបន់គឺយកទៅសម្លាប់ចោលហើយ ការយករទេះមកដឹកគ្រាន់តែធ្វើឲ្យល្អមើលប៉ុណ្ណោះ ។ យាយធឹម ដើរហួសទៅ ម៉ែប្រាប់ខ្ញុំថា "ពុកឯងត្រូវអង្គការសម្លាប់ចោលហើយ ចាប់ពីពេលនេះតទៅកូនលែងបានជួបមុខពុកទៀតហើយ" ។ ទឹកភ្នែកម៉ែហូរតក់ៗ ខ្ញុំទម្លាក់ខ្លួនអង្គុយទាំងទឹកភ្នែកហូរឥតឈប់ ។ ខ្ញុំមិននិយាយអ្វីទាំងអស់ ម៉ែទម្លាក់ខ្លួនអង្គុយក្បែរភ្លឺស្រែហើយលួងលោមខ្ញុំ "កុំយំអីកូនខ្លាចគេឃើញ ឆាប់ហូបខ្យងនេះឲ្យអស់ទៅ យើងគ្មានអ្នកណាត្រូវផ្ញើទៀតទេ" ។ ខ្ញុំអង្គុយទល់មុខម៉ែទាំងទឹកភ្នែក ។ ខ្ញុំឃ្លានខ្លាំងណាស់ ប៉ុន្តែខ្ញុំហូបអស់តែខ្យងពីរប៉ុណ្ណោះ ព្រោះខ្ញុំលេបមិនចូល ។ យើងទាំងពីរនាក់ក្រោកឡើង ម៉ែដឹកដៃខ្ញុំ "តោះ! យើងទៅផ្ទះវិញ" ។ ខ្ញុំនិយាយតិចៗតែម្នាក់ឯងថា "ពុកអើយ! ពុកទៅចោលខ្ញុំហើយ ខ្ញុំនឹកពុកណាស់ ពុកនៅឯណា" ។

មកដល់ផ្ទះ ក្របីខ្ញុំដែលចងក្នុងចំណាំងបានរាត់ផ្តាច់ខ្សែរត់ពេញភូមិ ។ អាឈ្មោលកាចណាស់ ទាល់តែពុកខ្ញុំទើបចាប់វាបាន ។ ខ្ញុំយំបណ្តើរអង្វរប្រជាជនមូលដ្ឋានឲ្យជួយចាប់ក្របីបណ្តើរ ។ ពេលចាប់បានហើយ យើងទាំងពីរនាក់ម៉ែកូនបានលែងវាឲ្យស៊ីស្មៅនៅក្បែរជើងភ្នំ ។ រសៀលម៉ោង៤ ខ្ញុំទៅរកក្របីតែរកមិនឃើញសោះ ។ ម៉ែឈឺភ្នែកមើលមិនឃើញ គាត់ចេះតែទៅមុខ កាត់ព្រៃចូលវាល ។ ខ្ញុំភ័យណាស់ខំស្រែក "ម៉ែកុំទៅ បុកភ្នំហើយ!" ។ ពេលនោះខ្ញុំចេះតែស្រែក ព្រោះឃើញភ្នំធំហើយខ្ពស់ទៀត (ខ្ញុំមិនដឹងថាមនុស្សមិនអាចបុកភ្នំទេ) ។ ម៉ែឆ្លើយថា "មិនអីទេកូន" ។ ប្រមាណមួយម៉ោងក្រោយមក ខ្ញុំឃើញក្របីកំពុងស៊ីស្មៅ ខ្ញុំអរខ្លាំងណាស់ ។ យើងទាំងពីរនាក់ដឹកក្របីមកផ្ទះវិញ ។

ស្អែកឡើង ម៉ែប្រាប់កម្មាភិបាលអង្គការឲ្យយកក្របីប្រគល់ឲ្យអ្នកផ្សេងកាន់ចុះ ព្រោះគាត់ជាស្ត្រីមិនអាចកាន់បានទេ ។ មេកងម្នាក់ក៏មកយកក្របីពីម៉ែទៅ ។

ដប់ថ្ងៃក្រោយមក បងប្រុសទីពីររបស់ខ្ញុំមកពីកងចល័តកោះស្លាចំពេលម្តាយខ្ញុំនិងខ្ញុំមិននៅផ្ទះ ។ គាត់បានផ្ញើកាំបិតផ្គាក់មួយទុកឲ្យម៉ែ ផ្តាំសួរសុខទុក្ខរួចក៏ចេញដំណើរទៅតាមក្រុមរបស់គាត់ទៅ ។ នៅពេលឮដំណឹងនេះខ្ញុំសែនក្តុកក្តួល ។

ពីរថ្ងៃក្រោយមក ម៉ែបានឮដំណឹងខ្សឹបខ្សៀវថា ក្រុមកងចល័តកោះស្លាចំនួន១៣០នាក់ត្រូវអង្គការហៅទៅប្រជុំនៅវិហារវត្តកំពង់ត្រឡាច ដោយប្រាប់ឲ្យដោះខោអាវចាស់ចេញឲ្យអស់ ទុកនៅខាងក្រៅ អង្គការនឹងចែកខោអាវថ្មី និងធ្វើម្ហូបឲ្យហូបឆ្អែត ។ ការពិតអង្គការចាក់សោបង្អត់បាយមួយថ្ងៃមួយយប់ រួចយកខ្សែចងហើយចាក់សម្លាប់ចោលទាំងអស់ ។ ដំណឹងនេះធ្វើឲ្យម្តាយខ្ញុំខ្វឹកខ្វល់ជាខ្លាំង គាត់ពុំព្រមសម្រាន្តទេ ។

ក្រោយពីអ្នកជាទីស្រលាញ់ទាំង៨នាក់របស់ខ្ញុំឃ្លាតឆ្ងាយទៅ ខ្ញុំមានអារម្មណ៍កណ្តោចកណ្តែងខ្លាំងណាស់ ។ ណាមួយខ្វះជាតិអាហារផង ខ្ញុំធ្លាក់ខ្លួនស្គមរីងរៃ ឈឺគ្មានលោះថ្ងៃ ។ កូនអ្នកមូលដ្ឋានមួយចំនួនហៅខ្ញុំថា "មីសំគមកូនកសិករ១៧មេសា" ។

ថ្ងៃមួយ ក្មេងស្រីម្នាក់ធំជាងខ្ញុំបន្តិចប្រើខ្ញុំឲ្យយួរសម្លមួយ

បានស្រោក់យកទៅឲ្យរោងបាយ ។ ក្មេងស្រីនោះឈ្មោះ គួន មានបងប្អូនពីរនាក់ ម្នាក់ឈ្មោះ ឃឿន និងម្នាក់ទៀតឈ្មោះ ច្រិប ។ ក្រៅពីនោះមានក្មេងស្រីពីរនាក់ទៀតដែលជាបងប្អូនបង្កើតនឹងគ្នា ម្នាក់ឈ្មោះ ញ៉ាញ់ ដូចខ្ញុំដែរ ហើយម្នាក់ទៀតឈ្មោះ ម៉ូវ ។ គួន មិនឲ្យអ្នកទាំងបួននោះយួរសម្លទេ ព្រោះខ្លាចគេហូបអស់ ។ គួន និយាយជាមួយខ្ញុំថា «ឯងកាន់ចាកស្រោក់នេះកុំឲ្យពួកនោះកាន់ឲ្យសោះ ចាំណាំ» ខ្ញុំឆ្លើយថា «ចាំ!» ។ គួន ចេញដំណើរទៅរោងបាយមុន ព្រោះ គួន មាននាទីមើលកុមារ ។ យើងខ្ញុំទាំងប្រាំនាក់ដើរទៅតាមក្រោយ ។ លុះដើរបានបន្តិចដល់ខ្ទង់ទំនប់មួយ ក្មេងទាំងបួនក៏ខ្សឹបគ្នាថា «យើងយកសម្លពីដៃវាស៊ីឲ្យអស់ ហើយឲ្យចានស្រោក់ទៅវាកាន់វិញ បើគួនសួរ យើងទាំងអស់គ្នាត្រូវឆ្លើយថាវាស៊ី» ។ ពាក្យទាំងអស់នេះខ្ញុំឮច្បាស់ពេញត្រចៀក ប៉ុន្តែខ្ញុំមិនដឹងធ្វើដូចម្តេច ។ ខ្សឹបគ្នារួច ឃឿន ជាប្អូនរបស់ គួន មកដណ្តើមចានស្រោក់ពីដៃខ្ញុំ «ឲ្យអញ! បើមិនឲ្យអញទេ អញវ៉ៃឯងឲ្យងាប់» ។ ខ្ញុំហូរទឹកភ្នែករហាម ដៃខ្ញុំកាន់ចានស្រោក់យ៉ាងណែន ។ ឃឿន ក៏ប្រឡេះចានស្រោក់ពីដៃខ្ញុំទៅ ។ ខ្ញុំឈរយំម្នាក់ឯង ។ ក្មេងទាំងបួននាក់នាំគ្នាហូបសម្លអស់ រួចយកចានស្រោក់មកឲ្យខ្ញុំកាន់វិញ ហើយគំរាមថា «បើឯងហ៊ានប្រាប់ គួន ថាពួកអញស៊ី ពួកអញនឹងវ៉ៃឯងទាល់តែងាប់» ។ ខ្ញុំទទួលចានស្រោក់ពី ឃឿន ហើយក៏បន្តដំណើរជាមួយគ្នា ។ មួយសន្ទុះក្រោយមក គួន មកដល់ល្មម ហើយសួរខ្ញុំថា «ញ៉ាញ់ ឯណាសម្លអញ?» ខ្ញុំឆ្លើយថា «ពួកនោះហូបអស់ហើយ» ។ ក្មេងទាំង៤នាក់ឆ្លើយព្រមគ្នាថា «កុំជឿ វាស៊ីអស់ហើយ» ។ គ្រាន់តែឮភ្លាម គួន ខឹងខ្លាំងណាស់ហក់មកទះកំភ្លៀងខ្ញុំជាំង វាយខ្នងខ្ញុំពីរបីដៃ ធាក់ខ្ញុំមួយជើង ហើយស្រែកប្រាប់គេឯងថា «មីមួយនេះប្រើឲ្យកាន់សម្លបន្តិចមិនបាន ហ៊ានលួចស៊ីអស់» ។ ខ្ញុំយំតិចៗមិនឲ្យឮសំឡេង ។ ខ្ញុំតូចចិត្តខ្លាំងណាស់ ដើរបណ្តើរយំបណ្តើរ នឹកអនិច្ចាខ្លួនជាពន់ពេក ។ ខ្ញុំគិតថា ប្រសិនបើមានបងម្នាក់ម្ល៉េះ ខ្ញុំមិនធ្លាក់ខ្លួនដល់ថ្នាក់នេះទេ ។ ពេលនោះខ្ញុំមានអាយុ៨ឆ្នាំហើយ តែខ្លួនខ្ញុំស្គមស្លេកស្លាំងមានតែឆ្អឹង ទោះជាក្មេងប៉ុន្មាននាក់មករករឿងខ្ញុំក៏ខ្ញុំពុំហ៊ានតបតដែរ ព្រោះខ្ញុំមើលឃើញអ្នកណាក៏ធំជាងខ្ញុំដែរ ។

ខ្ញុំធ្លាក់ខ្លួនឈឺមិនអាចទៅបេះទន្ទ្រានខែត្របាន ។ ខ្ញុំឈឺក្បាលខ្លាំងណាស់ងើបពីកន្ទេលមិនរួច ។ កុមារម្នាក់ស្រែកដាក់ត្រចៀកខ្ញុំថា «នែ! កាញ៉ាញ់ ទៅបេះទន្ទ្រានខែត្រទេ? បើឯងមិនទៅ អញប្រាប់ចុងភៅនៅរោងបាយមិនឲ្យបាយឯងស៊ីទេ» ។ ខ្ញុំងើបឡើងឆ្លើយថា «ខ្ញុំឈឺក្បាលខ្លាំងណាស់ ទៅមិនរួចទេ» រួចហើយខ្ញុំទម្លាក់ខ្លួនគ្របមុខជិតសម្ងំដេកទៀត ។ ពេលខ្ញុំដឹងខ្លួនឡើងគ្មាននរណាម្នាក់នៅជិតខ្ញុំទេ ។ ពេលនោះម៉ោងប្រហែល ១០កន្លះ ខ្ញុំងើបឡើងដើរទាំងញាក់ញ័រដើរទៅរោងបាយ ។ ម៉ែអត់នៅទេ ម៉ែត្រូវអង្គការឲ្យទៅច្រូតស្រូវនៅស្រុកលិចរយៈពេលមួយខែកន្លះ ចម្ងាយ៣៥គីឡូម៉ែត្រពីភូមិកូនសាត់ ។ មកដល់រោងបាយ ទាំងអស់គ្នាសម្លក់ខ្ញុំ តែខ្ញុំមិនរវល់មើលអ្នកទាំងនោះវិញទេ ។ ខ្ញុំចូលយករបបបបរដូចគេគ្រប់គ្នា ។ ចុងភៅម្នាក់សួរខ្ញុំថា «ឯងអត់ទៅធ្វើការទេមែនទេ?» ខ្ញុំឆ្លើយថា «ខ្ញុំឈឺក្បាល» ។ ចុងភៅក៏ដួសបបរមួយវែកដាក់ឲ្យខ្ញុំដូចកុមារដទៃទៀតដែរ ។ ខ្ញុំអរខ្លាំងណាស់ ។

## ចុងឆ្នាំ១៩៧៨

នៅរោងបាយ អង្គការប្រកាសឲ្យធ្វើនំបញ្ចុកហូប ។ ប្រជាជនហូបយ៉ាងរីករាយ ព្រោះមិនដែលបានហូបសោះ ។ ខ្លះហូប ខ្លះកំពុងរៀបចំធ្វើនំជាបន្តបន្ទាប់ ។

ស្រាប់តែមានពត៌មានខ្សឹបខ្សៀវពីប្រជាជនមូលដ្ឋានថា ហូបនំបញ្ចុកហើយ ទាំងមូលដ្ឋានទាំងអ្នក១៧មេសានឹងត្រូវអង្គការសម្លាប់ចោលទាំងអស់គ្នា ។ ក្នុងពេលនោះក៏មានយន្តហោះមួយគ្រឿងហោះក្រឡឹងជុំៗទៅមកនៅលើអាកាស ខ្ញុំឮអ្នកស្រុកហៅថាអាចានស្រោក់ ។ ម៉ែគេគ្រប់គ្នាបានមកដល់រោងបាយនាំគ្នាហូបបាយរួចប្រមូលកូនចៅដែលនៅមណ្ឌលឲ្យមកជួបជុំគ្នារៀបចំអីវ៉ាន់រត់ទៅត្រពាំងកក់ដែលជាតំបន់ព្រៃស្មសាន ។ ខ្លះកើបបាយ ខ្លះដងទឹក រៀបចំចេញដំណើរទាំងស្ទន់ស្ទោ ។

ចំណែកខ្ញុំឆ្ងែឆ្ងាដូចមាន់រកពង ព្រោះមិនឃើញម៉ែមក ។ ខ្ញុំភ័យញ័រអស់សព៌ាង្គកាយ ខ្ញុំឈរយំ ភ្នែករំពៃរកម្តាយ ។ ខ្ញុំឃើញមីងម្នាក់ដើរកោងៗស្មានថាម៉ែ តែពេលគាត់ងាកមុខមកមិនមែនម៉ែខ្ញុំសោះ ។ ខ្ញុំសួរមនុស្សគ្រប់គ្នាថា «មានឃើញម៉ែខ្ញុំទេ?» គេឆ្លើយថា «អត់ទេ» ។ «យាយ អ៊ំ ឃើញម៉ែខ្ញុំទេ?» «អត់ទេ» ។ ខ្ញុំអួលដើមក ។ ប្រមាណជាងមួយម៉ោងក្រោយមក

ស្ត្រីម្នាក់ពាក់ដួន សៀកខោខ្មៅពាក់អាវខ្មៅលីចបដើរតម្រង់មករករោងបាយ ។ ខ្ញុំស្រែកហៅ "ម៉ែៗ" ។ ខ្ញុំអរខ្លាំងណាស់ ប៉ុន្តែបែរជាយំយ៉ាងខ្លាំង ក្តៅពេញស្លឹកត្រចៀក ខ្ញុំយំពុំព្រមឈប់ ។ ម៉ែសួរថា "យំអី?" ខ្ញុំឆ្លើយថា "ខ្លាចបាត់ម៉ែ ម៉ែទៅណាអីក៏យូរម្ល៉េះ?" ម៉ែឆ្លើយថា "ម៉ែរវល់ជញ្ជូនកណ្តាប់ទម្លាក់ទឹក ព្រោះគេរត់ចោលម៉ែអស់ហើយ ។ ម៉ែធ្វើការរបៀបនេះទើបម៉ែអាចរស់បាន ។ កូនឈប់យំទៅ" ។ ខ្ញុំប្រាប់ម៉ែថា "គេទៅអស់ហើយអត់មានបាយទេ" ។ យើងពីរនាក់ម្តាយកូនក៏ប្រញាប់រត់ទៅខ្ទមយកស្បោងកម្មសិទ្ធិតូចមួយរបស់ម៉ែរត់តាមក្រោយគេ ។ ទៅដល់ត្រពាំងកក់ ប្រជាជនដទៃឲ្យបាយម៉ែម្នាក់មួយដុំៗ យើងទាំងពីរមិនខ្វះហូបឡើយ ហើយថែមទាំងមានអំបិលម្នាក់ពីរបីគ្រាប់ទៀត ។ ទៅដល់ទីនោះយើងសម្រាកមួយយប់ ល្ងាចនោះអង្គការបានប្រមូលផ្តុំអ្នកមូលដ្ឋាននៅមួយកន្លែង ប្រជាជនថ្មីនៅមួយកន្លែង ។ ពេលនោះខ្ញុំឃើញខោអាវមួយគំនរធំ ។ កងទ័ពអាវខ្មៅដើរទៅមកជាជួរៗ ។ ខ្ញុំឮចាស់ៗនិយាយគ្នាថា "អង្គការចែកបាយឲ្យយើងហូបគ្រប់គ្នារួចហើយកងទ័ពនឹងបោកគ្រាប់បែកសម្លាប់យើងឥឡូវហើយ" ។ ខ្ញុំបានឃើញខ្មែរក្រហមជីករណ្តៅទទឹង៣ម៉ែត្របណ្តោយ៥ម៉ែត្រជាច្រើនកន្លែង ។ រណ្តៅខ្លះជីករួច ខ្លះមិនទាន់រួច មានប្រជាជនខ្លះសួរកម្មាភិបាលថា "នេះជារណ្តៅអ្វី?" កម្មាភិបាលឆ្លើយថា "រណ្តៅនេះជីកសម្រាប់ពួនគេចពីយន្តហោះវៀតណាមទម្លាក់គ្រាប់បែក" ។

នៅវេលាម៉ោង៩ និង៣០នាទីល្ងាច មានសន្ធឹកខ្ទ័រប្រថពីដូចភ្នំភ្លើងផ្ទុះ ។ សន្ធឹកនេះចេញមកពីទិសខាងកើតម្តុំភ្នំវល្លិ៍ ។ សន្ធឹកនេះដូចព្យុះបន្ទិចដូចរថក្រោះបន្តិច ធ្វើឲ្យប្រជាជនទាំងអស់ភ័យរត់ឆ្វេឆ្វាបែកខ្ញែកគ្នា ខ្លះរត់ចូលព្រៃ ខ្លះរត់ចុះមកក្រោមវិញ ។ ប្រជាជនខ្លះស្រែកថារថក្រោះយួនមកហើយ ខ្លះនិយាយថាបារមីទេវតាអង្រួនភ្នំ ខ្លះថាបាតុភូតធម្មជាតិ ។ ហេតុការណ៍នេះធ្វើឲ្យផែនការខ្មែរក្រហមពេលនោះត្រូវរលាយ ។ យើងទាំងអស់គ្នាមកដល់ភូមិកូនសាត់វិញជាមួយក្រុមគ្រួសារដទៃទៀត ។ សូមបញ្ជាក់ថា ភូមិកូនសាត់នេះក្នុងឆ្នាំ១៩៧៦មានប្រជាជនចំនួន៧០០គ្រួសារ តែចុងឆ្នាំ១៩៧៨នេះនៅសល់តែ៧០គ្រួសារប៉ុណ្ណោះ ហើយសុទ្ធតែជាស្ត្រីមេម៉ាយទាំងអស់ ។

ឆ្នាំ១៩៧៩ ក្រុមគ្រួសារខ្ញុំមកដល់ភូមិកំណើតវិញ នាំមកជាមួយនូវក្មួយកំព្រាពីរនាក់និងស្បោងកម្មសិទ្ធិតូចមួយរបស់ម៉ែ ។ ពេលនោះម៉ែគ្មានចង់បានអ្វីក្រៅពីស្វែងរកដំណឹងបងទីមួយរបស់ខ្ញុំទេ ។ គាត់បានទទួលដំណឹងថា មានអ្នកឃើញបងប្រុសខ្ញុំពាក់ខោអាវរហែករយ៉ែដឹកឆ្កែមួយក្បាល គឺជាឆ្កែរបស់លោក រស់ សារង្ស ហើយត្រូវអង្គការយកទៅសម្លាប់នៅវត្តស្ទឹងត្រាំអំប្រាង ក្នុងស្រុកជុំគិរី ខេត្តកំពតនេះឯង ។ ដំណឹងនេះនាំមកនូវក្តីឈឺចាប់និងអស់សង្ឃឹមដល់ម្តាយខ្ញុំ ។

យើងពីរនាក់ម្តាយកូនដូចក្បូនរសាត់គ្មានត្រើយ ។ ក្រុមគ្រួសារខ្ញុំមានសមាជិក១០នាក់ ពេលវិលមកវិញមានតែពីរនាក់ប៉ុណ្ណោះ ។

រឿងរ៉ាវទាំងប៉ុន្មានកន្លងផុតទៅហើយក្តី ប៉ុន្តែខ្ញុំមិនអាចបំភ្លេចបានឡើយ ។ ជួនកាល ពេលនឹកឃើញសម្តីរបស់ឪពុកខ្ញុំដែលផ្តាំថា "កូនស្រីមាសឪពុក បើពុកមិននៅកុំយំរកពុកណា កូនថែរក្សាខ្លួនឯងផង" ខ្ញុំអួលដើមកទឹកភ្នែកហូរមួយរំពេច ។ ពេលមានពិធីបុណ្យបង្សុកូលម្តងៗ លោកអាចារ្យអានឈ្មោះរបស់ពុក ធ្វើឲ្យខ្ញុំទប់អារម្មណ៍មិននឹងចង់តែស្រែកយំ ។ បើខ្ញុំខំប្រឹងទប់កាន់តែខ្លាំង ទ្រូងខ្ញុំរឹតតែចុកណែន ។ ខ្ញុំខាំមាត់ក្តាប់ដៃកុំឲ្យខ្មាសគេ ប៉ុន្តែទីបំផុតខ្ញុំស្រែកទ្រហោយំខ្លាំងៗ "ពុក! ពុក! ពុកនៅឯណា?" ។ ខ្ញុំប្រកាច់ប្រកិនផ្អើលគេឯង ។ មានអ្នកខ្លះនិយាយថាខ្មោចឪពុកខ្ញុំចូល ខ្លះថាមកពីខ្ញុំនឹកគាត់ពេក ។ ខ្ញុំយល់សប្តិអាក្រក់ជារឿយៗ ។ សព្វថ្ងៃនេះ ខ្ញុំឧស្សាហ៍ឈឺក្បាលហើយរាងកាយស្គមស្គាំងជាប្រចាំ ។

ពាក្យពេចន៍ដែលខ្ញុំសរសេរនេះគឺរៀបរាប់ត្រួសៗអំពីហេតុការណ៍ដែលខ្ញុំជួបប្រទះពីអាយុ៨ឆ្នាំដល់៩ឆ្នាំ ។ នៅមានរឿងរ៉ាវជាច្រើនទៀតដែលខ្ញុំមិនអាចរៀបរាប់អស់" ។ ខ្ញុំសូមសួរទៅមេដឹកនាំខ្មែរក្រហមថា÷

១) ពេលដែលប្រទេសជួបរឿងនេះ តើមេដឹកនាំខ្មែរក្រហមទាំងនោះនៅឯណា? ហើយបានឃើញទិដ្ឋភាពនេះដែរឬទេ?

២) តើរដ្ឋាភិបាលរំដោះជាតិខ្មែរក្រហមប្រល័យពូជសាសន៍ឯងដូចគ្នានេះដើម្បីអ្វី?

**ព្រុំ សាម៉ុន**

# ជីវិតក្នុងភាពនឹងថ្កល់

## អួន ឡុងឌី
## ប្រធានមន្ទីរកងពល៣១០


អួន ឡុងឌី ថតក្នុងឆ្នាំ១៩៧៥

*(បទសម្ភាសន៍ជាមួយ អួន ហ៊ិចហួន អាយុ៤៧ឆ្នាំ ត្រូវជាប្អូនស្រី នៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម)*

ខ្ញុំមានបងប្អូន៧នាក់ ៥នាក់បានចូលធ្វើបដិវត្តន៍ ។ បងប្រុសខ្ញុំឈ្មោះ ឈួងហ៊ីង, ឈួងកុច, ឡុងឌី និងប្អូនស្រីខ្ញុំម្នាក់ទៀតឈ្មោះ ហ៊ិចអេង សុទ្ធតែស្លាប់ក្នុងរបបប៉ុលពត ។

ពេលបង ឡុងឌី ទើបចប់ថ្នាក់វិទ្យាល័យ គាត់មានអាយុប្រហែល១៨ឆ្នាំ ។ កាលណោះ បងឈួងហ៊ីង បាននាំ បងឡុងឌី ចូលរួមជាមួយខ្មែរក្រហម ។ បងឡុងឌី ចង់ចូលរួមបដិវត្តន៍ខ្លាំងណាស់ ។ គាត់ទទូចសុំពុកម៉ែជាច្រើនលើកច្រើនសាទើបពុកម៉ែអនុញ្ញាតឲ្យគាត់ទៅ ។ បងស្រីបងប្រុសខ្ញុំទាំងប៉ុន្មាននាក់រីករាយណាស់ដែលទីបំផុត បងឡុងឌី បានទៅចូលរួមនិងបូជាគ្រប់យ៉ាងដើម្បីបម្រើបដិវត្តន៍ ។

អស់ពេលយ៉ាងយូរ យើងមិនបានដំណឹងអ្វីពី បងឡុងឌី បន្តិចសោះ ។ ម្តាយខ្ញុំស្តីបន្ទោស បងឈួងហ៊ីង យ៉ាងខ្លាំងពីរឿងនេះ ។ តាមពិត បងឈួងហ៊ីង មានដំណឹងពី បងឡុងឌី ប៉ុន្តែគាត់លាក់មិនឲ្យម៉ែដឹង ព្រោះ បងឡុងឌី ត្រូវអង្គការបញ្ជូនទៅសមរភូមិមុខ ហើយគាត់មិនចង់ឲ្យម៉ែបារម្ភពីរឿងនេះ ។

ក្រោយមក នៅឆ្នាំ១៩៧៤ បងឡុងឌី ជិះម៉ូតូមកលេងផ្ទះដោយមានទាំងកាំភ្លើងខ្លីនិងអង្គរក្សម្នាក់មកជាមួយផង ។ គាត់បានប្រាប់យើងថា អង្គការគ្រោងវាយយកភ្នំពេញឲ្យបាននៅឆ្នាំ១៩៧៥ ។

នៅឆ្នាំ១៩៧៥ ម្តាយខ្ញុំបានទៅភ្នំពេញដើម្បីចូលរួមពិធីរៀបការ បងឡុងឌី ។ អង្គការអនុញ្ញាតឲ្យពុកម៉ែទៅចូលរួមគឺដោយសារតែ បងឈួងហ៊ីង កាលណោះជានាយទាហានជាន់ខ្ពស់មានអភ័យឯកសិទ្ធិ ។ បងឡុងឌី នាំប្រពន្ធគាត់មកលេងស្រុកនៅចុងឆ្នាំ១៩៧៥ ។ ប្រពន្ធគាត់ឈ្មោះ លីន ជាគ្រូពេទ្យ ។ ប្រពន្ធគាត់ស្អាតណាស់ ។ កាលណោះប្តីប្រពន្ធគាត់ស្នាក់នៅកំពង់ចាមបានប្អូនប្រាំថ្ងៃដែរ ។

ពេលនោះខ្ញុំនៅកងចល័ត អង្គការបញ្ជូនឲ្យទៅធ្វើការឆ្ងាយៗពីផ្ទះ ។ ម្តាយខ្ញុំសុំឲ្យ បងឡុងឌី យកខ្ញុំនិងប្អូនស្រីខ្ញុំទៅធ្វើការនៅភ្នំពេញ ព្រោះគាត់គិតថាប្រហែលជាប្រសើរជាងរស់នៅទីនេះ ។ ខ្ញុំធ្វើការនៅអង្គភាពដេរសម្លៀកបំពាក់នៅផ្សារអូរឫស្សី ប្អូនស្រីខ្ញុំធ្វើការនៅពេទ្យ ។

ខ្ញុំបានជួប បងឡុងឌី តែម្តងគត់ ប៉ុន្តែខ្ញុំបានឃើញប្រពន្ធគាត់ជាញឹកញាប់នៅអង្គភាពសម្លៀកបំពាក់ដែលខ្ញុំធ្វើការព្រោះបងប្អូនរបស់គាត់ឈ្មោះ ខាន់ ជាប្រធានកាន់កាប់កន្លែងនោះ ។ ពេលនោះ បងលីន កំពុងតែមានផ្ទៃពោះ ។ នៅចុងឆ្នាំ១៩៧៦ ខាន់ ប្រាប់ខ្ញុំថាអង្គការផ្លាស់ បងឡុងឌី ទៅកន្លែងមួយទៀត ។ ក្រោយនោះបន្តិចខ្ញុំឃើញ បងលីន ប៉ុន្តែបន្ទាប់មកគាត់ក៏បាត់ខ្លួនដែរ ។ បន្ទាប់មកទៀតដល់វេន ខាន់ ដែលមានអាយុ៤០ឆ្នាំ និងកំពុងតែមានផ្ទៃពោះ ។

ក្រោយមក អង្គការផ្លាស់ខ្ញុំចេញពីអង្គភាពដេរសម្លៀកបំពាក់ ដោយចោទថាខ្ញុំជាប់ទាក់ទងនឹងបងប្អូនមាននិន្នាការក្បត់ ។ អង្គការចាត់ឲ្យខ្ញុំធ្វើការនៅសហករណ៍ គឺដាំបន្លែ ជីកប្រឡាយ និងស្ទូងស្រូវ ។

ខ្ញុំមានអារម្មណ៍ថា បងឡុងឌី ពិតជាត្រូវអង្គការចាប់ខ្លួន ។ មុននេះ បងឈួនកុច ដែលធ្វើការនៅមន្ទីរឧស្សាហកម្មនៅផ្សារចាស់ បានប្រាប់ខ្ញុំថា បងឈួនហ៊ីង ត្រូវអង្គការចាប់ខ្លួន ហើយប្រាប់ខ្ញុំកុំឲ្យបារម្ភខ្លាំងពេក ។ ពេលខ្ញុំធ្វើការនៅសហករណ៍ ខ្ញុំជួបអ៊ីស្រីម្នាក់ ។ អ៊ីស្រីនោះប្រាប់ខ្ញុំថា គាត់បានឃើញ បងឈួងកុច និងប្រពន្ធនៅមន្ទីរឃុំឃាំង ។ អ្នកទាំងពីរមានកូនប្រុសតូចមួយ ប៉ុន្តែយើងមិនដែលទទួលពត៌មានអ្វីបន្ថែមទៀតទេ ។

ខ្ញុំរស់នៅក្នុងសភាពភ័យខ្លាចគ្រប់ពេល ។ ខ្ញុំគិតថាថ្ងៃណាមួយខ្ញុំពិតជាត្រូវអង្គការចាប់ខ្លួនដែរជាមិនខាន ។ អង្គការតែងតែតាមដានខ្សែរយៈ ។ ឥឡូវនេះពេលដែលខ្ញុំឃើញប្រវត្តិរូបដែលប្អូនយកមកនេះទើបខ្ញុំដឹងថាបង ឈួងហ៊ីង និង បងឡុងឌី នៅទួលស្លែង ។ ខ្ញុំសោកសៅណាស់ពេលនេះ ហើយក៏មិនចង់បានចម្លើយអ្វីពីរឿងបងប្រុសខ្ញុំទាំងពីរនាក់នេះដែរ ។ ◆◆◆

# យ័ង ស៊ីវឡាយ
# យោធា វរសេនាធំ-១

*(បទសម្ភាសន៍ជាមួយប្អូនស្រីឈ្មោះ ឃួង ហេ្គចម៉ុង អាយុ៥៥ឆ្នាំ នៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម)*

ក្នុងចំណោមបងប្អូនខ្ញុំទាំងប្អូននាក់ មានតែខ្ញុំម្នាក់ទេដែលនៅរស់ ។ នៅក្នុងរបបសង្គមរាស្ត្រនិយម បងប្រុសខ្ញុំឈ្មោះ សុងឡាយ បានស្លាប់ដោយសារជំងឺបេះដូង ។ ក្រោយម្តាយខ្ញុំទទួលមរណភាព ប្អូនប្រុសពៅខ្ញុំឈ្មោះ សាយឡាយ ត្រូវអ្នកផ្សេងយកទៅចិញ្ចឹម តាំងពីពេលវាអាយុបានពីរខែ ។ កាលណោះ ខ្ញុំទើបតែអាយុ៥ឆ្នាំ មិនអាចមើលថែប្អូនបានទេ ។ ពេលដែល សាយឡាយ ធំឡើងក៏ត្រូវខ្មែរក្រហមបាញ់សម្លាប់ចោល ។

នៅឆ្នាំ១៩៧២ មេបញ្ជាការយោធាស្រុកក្រូចឆ្មារបានហៅ ស៊ីវឡាយ ឲ្យចូលរួមមិទ្ទីងរបស់ខ្មែរក្រហមដែលធ្វើនៅភូមិជារៀងរាល់ថ្ងៃ ។ ស៊ីវឡាយ ទៅចូលបានបីដងដែរ ក្រោយមកអង្គការមកយកបងខ្ញុំទៅ ។ កាលណោះ ស៊ីវឡាយ កំពុងគ្រុនទើបសុំអង្គការថាចាំខ្លួនជាសះស្បើយសិនទើបទៅចូលរួមបដិវត្តន៍ពេលក្រោយ តែអង្គការថាគាត់ត្រូវតែចូលឥឡូវនេះមិនអាច



យ័ង ស៊ីវឡាយ (រូបខាងស្តាំ) ថតប្រហែលក្នុងឆ្នាំ១៩៦៧

ប្រកែកបានទេ ។ ឪពុកខ្ញុំយំសោកបោកខ្លួន ។ គាត់និយាយថា អង្គការគួរតែទុកឲ្យ ស៊ីវឡាយ នៅព្យាបាលខ្លួនសិន ។ ខ្មែរក្រហម ប្រាប់ពុកថាកុំធ្វើដូចជាធ្ងន់ធ្ងរពេក យុវជនទាំងអស់សុទ្ធតែចូល តាមកងទាំងអស់ ។ ដូច្នេះយុវជនប្អូននាក់លើក ស៊ីវឡាយ ដាក់ អង្រឹង ហើយសែងចុះដណ្តើរយកទៅ ។

ក្រោយមក ស៊ីវឡាយ បានផ្ញើសំបុត្រមួយមកផ្ទះថា គាត់បានគ្រាន់បើហើយ សុំកុំឲ្យបារម្ភអី ។ នៅឆ្នាំ១៩៧៣ឬ៧៤ អង្គការបានផ្លាស់ ស៊ីវឡាយ ទៅខេត្តព្រៃវែងធ្វើកងទ័ព ។ ស៊ីឡាយ បានផ្ញើសំបុត្រពីរច្បាប់មកផ្ទះ ដើម្បីផ្តល់ដំណឹងថាគាត់ កំពុងតែធ្វើការនៅរោងចក្រដ-១នៅ ភ្នំពេញ ។ រោងចក្រ ដ-១ ប្រហែលជារោងចក្រតម្បាញហើយបើតាមខ្ញុំគិត ។ ស៊ីវឡាយ ប្រាប់ថា គាត់រស់នៅទីនោះសុខសប្បាយទេ ។ ក្រោយពីនោះ យើងមិនដែលបានដំណឹងអ្វីទៀតទាល់តែសោះ ។ ◆◆◆


អ៊ុំ សារុន ថតនៅចំការដូង

# អ៊ុំ សារុន ហៅ រិទ្ធិ
# យុទ្ធជនក្រសួងពាណិជ្ជកម្ម

*(បទសម្ភាសន៍ជាមួយបងប្អូនជីដូនមួយឈ្មោះ ឃឹម សម្បត្តិ អាយុ៥៧ឆ្នាំ និង ឈឹម ចាន់ធី អាយុ៣៧ឆ្នាំ នៅស្រុកកងមាស ខេត្តកំពង់ចាម)*

**ឃឹម សម្បត្តិ៖** រិទ្ធិ ជាអ្នករៀនសូត្រចេះដឹងគ្រាន់បើដែរ ។ គាត់រៀនបានប្រមាណ៨-៩ឆ្នាំដែរ ។ រិទ្ធិ ចូលរួមបដិវត្តន៍ នៅឆ្នាំ១៩៧០ តាមព្រះបន្ទូលរបស់សម្តេចឪដែលអំពាវនាវឲ្យ ប្រជាជនចូលព្រៃសង្គ្រោះប្រទេសជាតិ ។

ដំបូងគាត់ជាសមាជិកក្រុមសិល្បៈស្រុក ក្រោយមកអង្គការ លើកគាត់ឲ្យធ្វើការថ្នាក់តំបន់ ។ អង្គការស្រឡាញ់រាប់អាន រិទ្ធិ ណាស់ ទើបក្រោយមកនាំគាត់ទៅធ្វើជានិរសារប្រចាំភូមិភាគ និងឲ្យគាត់ធ្វើការនៅកន្លែងសម្តែងសិល្បៈ ។

ពេល រិទ្ធិ មកលេងផ្ទះ គាត់ជិះម៉ូតូសេអិលពណ៌ក្រហម ។ ឪពុកម្តាយនិងបងប្អូនសាច់ញាតិតែងតែសួរនាំគាត់អំពីការងារ របស់គាត់ប៉ុន្តែគាត់មិនដែលរំពុកទេ ។ រិទ្ធិ និយាយថា ចង់មក មើលកូនៗ ហើយថាអង្គការបានដាក់កិច្ចការសំខាន់មួយឲ្យគាត់ តាមរកគិញសម្ងាត់ ។ គាត់មានម៉ាស៊ីនថតផ្ទាល់ខ្លួនសម្រាប់ថត និងផ្តិតរូបដោយខ្លួនឯង ។

រិទ្ធិ និងខ្ញុំបែកគ្នានៅឆ្នាំ១៩៧៤ ។ ខ្ញុំគឺជាសាច់ញាតិតែ ម្នាក់គត់របស់ រិទ្ធិ ដែលបានដើរលេងជាមួយគាត់ពេលដែលគាត់ មកលេងជាលើកចុងក្រោយ ។ រិទ្ធិ និយាយថា "ចាប់ពីពេល នេះតទៅយើងលែងបានជួបគ្នាទៀតហើយ" ។ ស្ថានការណ៍ កាន់តែធ្ងន់ធ្ងរឡើងៗ ពេលនោះខ្ញុំកំពុងធ្វើការជាមួយអង្គការ ។

ខ្ញុំនៅតែតាមស៊ើបសួរពីអ្នកដែលធ្លាប់ធ្វើការជាមួយ រិទ្ធិ និងរកគ្រូទាយអំពីដំណឹងរបស់ រិទ្ធិ ។ មានមនុស្សមួយចំនួន និយាយថា រិទ្ធិ នៅរស់ទេ ។ ខ្ញុំថែមទាំងព្រួសួរថាគាត់ធ្លាប់ជាប់គុក ទួលស្លែង តែមិនដឹងថាហេតុម៉េចបានជាអង្គការធ្វើដាក់គាត់ បែបនេះ ។ បុរសម្នាក់ដែលធ្លាប់ធ្វើការជាមួយ រិទ្ធិ និយាយថា គាត់បានឃើញរូបថតរបស់ រិទ្ធិ នៅទួលស្លែង ។ ខ្ញុំមិនដឹងថា គាត់ស្លាប់ពុក៏យ៉ាងម៉េចទេ ។ ប្រហែលជាគាត់គ្រាន់តែបានថត រូបនៅកន្លែងនោះក៏មិនដឹង ។

ខ្ញុំបានចូលរួមការសម្តែងសិល្បៈនៅឆ្នាំ១៩៧០ និងរាំរបាំ "កសិករប្រមូលផល" ។ អង្គការនិយាយថា សិល្បៈជាកត្តាលើក

កម្ពស់វប្បធម៌ ។ នៅឆ្នាំ១៩៧១ ខ្ញុំត្រូវអង្គការបញ្ជូនទៅធ្វើពេទ្យទាហាន ជួយរុំនិងលាងរបួស ។ ដោយសារកាលណោះមានការទម្លាប់គ្រាប់បែកមិនឈប់ឈរ ធ្វើឲ្យខ្ញុំទទួលបានបទពិសោធន៍ល្អៗជាច្រើន ។ អង្គការចាត់ឲ្យខ្ញុំកាន់ការងារនេះ ព្រោះខ្ញុំអាចអានអក្សរបារាំងនៅលើសេចក្តីណែនាំប្រើប្រាស់ថ្នាំពេទ្យ ។ សម័យនោះយើងប្រើទាំងថ្នាំបារាំងនិងថ្នាំផលិតក្នុងស្រុក ។

ខ្ញុំជួបប្តីខ្ញុំពេលគាត់ធ្វើពេទ្យឃុំ ហើយខ្ញុំធ្វើការជាមួយគាត់ ។ មានបុរសជាច្រើននាក់ទៀតដែលចង់បានខ្ញុំដែរ រួមទាំងគណៈស្រុកម្នាក់ដែលមានបុរសមានរូបរាងស្អាតបាត ។ ប្តីខ្ញុំប្រើល្បិច ។ គាត់បានឲ្យឪពុកម្តាយរបស់គាត់មកចរចាជាមួយម្តាយខ្ញុំមុន ហើយអ្នកទាំងអស់គ្នាយល់ព្រមប្រាប់អង្គការថាខ្ញុំមានគូដណ្តឹងហើយ គឺបានភ្ជាប់ពាក្យតាំងពីសម័យមុនមកម្ល៉េះ ។

យើងបានរៀបការនៅឆ្នាំ១៩៧២ ជាពិធីរៀបការគំរូដំបូងបំផុតនៅស្រុកយើង ។ មិនទាន់មានពិធីរៀបការម្តងដប់គូនៅឡើយទេ ។ កាលណោះខ្ញុំអាយុ២១ឆ្នាំ ។ នៅក្នុងពិធីនោះមានម្ហូបអាហារដប់តុ ព្រមទាំងមានស្រាផង ។ អង្គការអនុញ្ញាតឲ្យឪពុកម្តាយទាំងសងខាងចូលរួមដែរ ប៉ុន្តែមិនមានព្រះសង្ឃទេ ។ ខ្មែរក្រហមអនុញ្ញាតឲ្យយើងមកលេងផ្ទះបានពីរបីថ្ងៃដើម្បីទទួលពរជ័យពីញាតិមិត្ត ។

ថ្ងៃមួយប្តីខ្ញុំកំពុងតែបាញ់ចាប ស្រាប់តែចៃដន្យអាក្រក់គាត់បាញ់ចំអ្នកភូមិ ។ ដោយសារតែកំហុសអចេតនានេះ អង្គការបញ្ជូនគាត់ទៅធ្វើទាហាននិងបញ្ជូនទៅសមរភូមិជាច្រើនសានៅអំឡុងឆ្នាំ១៩៧២ ។ ក្រោយមកទៀត ប្តីខ្ញុំបានក្លាយជាប្រធានកងវរសេនាធំ ។

ខ្ញុំឮថាប្តីខ្ញុំនៅច្បាំងជាមួយទព័ចេនឡារយៈពេលជាង ៨ខែ ។ និមិត្តសញ្ញារបស់កងកម្លាំងនោះគឺរូបក្បាលខ្មោច ។ កងទ័ពខ្មែរក្រហមជាច្រើននាក់បានបាត់បង់ជីវិតក្នុងការតស៊ូ ។ ខ្ញុំអស់សង្ឃឹមថាលែងបានជួបប្តីខ្ញុំម្តងទៀតហើយ ប៉ុន្តែនិរសារម្នាក់បានយកសំបុត្រពីប្តីខ្ញុំមកហើយប្រាប់ថាគាត់នៅកងពលលេខ១ នៅទីក្រុងភ្នំពេញ ។

ខ្ញុំតបទៅនិរសារនោះថា ខ្ញុំមិនជឿថាប្តីខ្ញុំនៅរស់ទេ លុះត្រាតែគាត់មកជួបខ្ញុំផ្ទាល់ ។ ខ្ញុំខឹងនៅមិនសុខ សូម្បីតែដឹងថាសំបុត្រនោះគឺប្តីខ្ញុំជាអ្នកសរសេរដោយផ្ទាល់ដៃក៏ដោយ ។ ខ្ញុំយំអត់ឈប់ ។ ម្តាយក្មេកខ្ញុំរំឭកខ្ញុំថា ខ្ញុំមានផ្ទៃពោះចាស់ខែ ដូច្នេះកុំយំច្រើនពេកប្រយ័ត្នខ្វាក់ភ្នែក ។ បីថ្ងៃក្រោយមក ខ្ញុំសម្រាលបានកូនប្រុសមួយ ។



អ៊ុំ សារុន (រូបឆ្វេង) ថតក្នុងទីក្រុងភ្នំពេញ

ប្ដីខ្ញុំមិនបានដឹងថាខ្ញុំសម្រាលកូនទេ ។ ពីរថ្ងៃក្រោយមក មាននិរសារម្នាក់ទៀតនាំសំបុត្រប្ដីខ្ញុំមក ។ គាត់សរសេរថា គាត់នៅរស់ទេ ហើយកំពុងតែប្រយុទ្ធតស៊ូនៅសមរភូមិ កុំឲ្យខ្ញុំរីងរូសពេក ។ រឿងរ៉ាវច្រើនពេកធ្លាក់មកលើខ្ញុំ ទើបខ្ញុំយំមិនឈប់ ។ ចាប់ពីកំណើតកូនប្រុសខ្ញុំមក ខ្ញុំនៅស្គមរហូតមកទល់សព្វថ្ងៃ ព្រោះយំច្រើនពេក ។

កន្លះខែក្រោយមក ប្ដីខ្ញុំមកលេងផ្ទះដោយយកទឹកដោះគោ ថ្នាំពេទ្យ នាឡិកាសីកូដែលគាត់លួចបាន និងកន្ទេលកូនក្មេងមកផង ។ គាត់និយាយថា «យើងបែកគ្នាយូរហើយ អង្គការចង់ឲ្យយើងនៅជុំគ្នានៅភ្នំពេញ» ។ ខ្ញុំយល់ព្រមទៅតាមគាត់ ។ យើងស្នាក់នៅក្បែរធនាគារជាតិ ។ នៅខែកុម្ភៈឆ្នាំ១៩៧៦ អង្គការផ្លាស់ខ្ញុំទៅទៅព្រែកព្នៅ ខេត្តកណ្ដាល ។ ប្រធានកងពលប្រាប់ខ្ញុំថាកុំឲ្យបារម្ភអ្វី ព្រោះប្ដីខ្ញុំនឹងក្លាយជាអ្នកបើកយន្តហោះជាមិនខាន ។ ខ្ញុំមិនជឿអ្នកទាំងនោះទេ ខ្ញុំគិតថាអង្គការបានចាប់ខ្លួនប្ដីខ្ញុំហើយ ។ គាត់ប្រាប់ថាកុំខ្វល់ ព្រោះប៉ុន្មានថ្ងៃទៀតអង្គការពិតជាអនុញ្ញាតឲ្យខ្ញុំទៅជួបប្ដីខ្ញុំជាមិនខាន ។

នៅព្រែកព្នៅ អង្គការផ្ដល់អាហារឲ្យខ្ញុំគ្រប់គ្រាន់ មានគ្រែ មានកម្រាលពូក និងភួយល្អៗដណ្ដប់ ។ ខ្ញុំគ្មានអ្វីនិយាយក្រៅពីសរសើរអំពីស្ថានភាពនៅពេលនោះ ប៉ុន្តែខ្ញុំនៅតែមិនជឿរឿងថាប្ដីខ្ញុំត្រូវអង្គការចាត់ឲ្យបើកយន្តហោះ ។ អារម្មណ៍ខ្ញុំខ្វល់ខ្វាយវិលវល់អំពីបញ្ហានេះ ។ ប្រហែលដប់ថ្ងៃក្រោយមក លេចឮពាក្យចចាមអារ៉ាមថា គ្រួសាររបស់កម្មាភិបាលទាំងអស់ត្រូវចាត់ឲ្យចុះតាមសហករណ៍ ។ ខ្ញុំប្រាប់ខ្លួនឯងថាខ្ញុំមិនដែលខ្លាចស្លាប់ម្ដងណាទេ ព្រោះខ្ញុំបានទទួលបទពិសោធន៍ល្វីងជូរចត់ផ្អែតផ្អូន់ហើយ ។ នៅម៉ោង៧ល្ងាច មានឡានមកដល់ ប្រធានកងប្រាប់ខ្ញុំឲ្យរៀបចំឥវ៉ាន់រួមទាំងមុងភួយនិងប្រដាប់ស្លុងកំដៅផង ។ ដល់ពាក់កណ្ដាលផ្លូវ ស្រាប់តែប្រដាប់ស្លុងកំដៅផ្ទុះបែកប្រាវ ។ នេះជាប្រផ្នូលអាក្រក់អំពីរឿងដែលប្ដីខ្ញុំត្រូវអង្គការយកទៅសម្លាប់ចោល ។

ខ្ញុំត្រូវអង្គការបញ្ជូនឲ្យទៅរស់នៅជាមួយប្ដីប្រពន្ធចំណាស់មួយគូដែលគ្មានកូនចៅ ។ អ្នកទាំងពីរអាណិតអាសូរខ្ញុំណាស់ ព្រោះឃើញខ្ញុំជាស្រីមានកូនតូចនៅជាមួយ ។ ប្ដីប្រពន្ធគាត់ជួយរែកទឹកឲ្យខ្ញុំ ។ មានពេលមួយខ្ញុំកំពុងតែហូបបាយជាមួយគ្រួសារគាត់ ស្រាប់តែចានបាយខ្ញុំធ្លាក់បែក ឲ្យប្រផ្នូលអាក្រក់មួយ



អ៊ុំ សារុន (រូបកណ្ដាល) ថតនៅផ្សារធំថ្មី ក្នុងទីក្រុងភ្នំពេញ

ទៀត ។ ក្រោយមកទៀតខ្ញុំយល់សប្តិថាមានមនុស្សយកកាំបិតមកវះពោះខ្ញុំ ។ ខ្ញុំគិតថាប្តីខ្ញុំត្រូវខ្មែរក្រហមសម្លាប់ហើយ ។

បន្ទាប់ពីនេះ អង្គការបានបញ្ជូនខ្ញុំទៅភូមិមួយនៅស្រុកព្រៃឈរ ។ នៅទីនោះខ្ញុំឈឺមិនលោះពេល ។ ខ្ញុំរស់នៅជាមួយអ៊ំស្រីម្នាក់និងកូនស្រីគាត់ ។ កូនស្រីគាត់ឃើញខ្ញុំមានសុខភាពខ្សោយ ក៏ជួយប្រក់ដំបូលឲ្យខ្ញុំ ចំណែកខ្ញុំគ្រាន់តែឈរពីក្រោមហុចស្លឹកដូងតែប៉ុណ្ណោះ ។ នាងជាប្រធានរោងបាយ ។ នាងបានយកអាហារឲ្យខ្ញុំ និងជួយមើលកូនខ្ញុំពេលខ្ញុំឈឺ ។ គណៈភូមិបានមកប្រាប់ខ្ញុំថា ឲ្យតែខ្ញុំជាសះស្បើយពីរបីថ្ងៃទៀតឲ្យទៅជួបប្តីខ្ញុំ ។

ប៉ុន្តែជំងឺខ្ញុំក្លាយទៅជារ៉ាំរ៉ៃ ។ អង្គការបញ្ជូនខ្ញុំទៅមន្ទីរពេទ្យនៅកំពង់ចាម ។ ក្នុងឆ្នាំ១៩៧៦ ខ្ញុំស្នាក់នៅពេទ្យអស់៨ខែ ។ ខ្មែរក្រហមប្រើថ្នាំល្អៗដែរ ថ្នាំដែលផលិតក្នុងស្រុកដែរ ។ អង្គការចង់សាកល្បងមើលថាតើយើងអានអក្សរលើដបថ្នាំបានអត់ ។ បើយើងជាអ្នករៀនសូត្រយើងពិតជាត្រូវអង្គការយកទៅហើយ ដូច្នេះខ្ញុំធ្វើពុតជាមិនចេះអាន ។

ខ្ញុំនិងប្តីខ្ញុំបែកគ្នានៅខែកុម្ភៈឆ្នាំ១៩៧៦ ។ បានជាខ្ញុំចាំខែឆ្នាំព្រោះកាលណោះកូនប្រុសខ្ញុំអាយុទើបតែ៩ខែ ។ មុនដំបូងអង្គការចាប់គាត់ដាក់គុកក្រូចគរ ខេត្តកំពង់ចាម ដោយចោទថាគាត់កាន់ «សញ្ញាខៀវ» នៅជួរខ្មែរសេរី ប៉ុន្តែខ្ញុំមិនដឹងរឿងនេះទាល់តែសោះ ។ បងប្អូនជីដូនមួយខ្ញុំម្នាក់ប្រាប់ខ្ញុំថាបានឃើញប្តីខ្ញុំជាប់ច្រវាក់ជើងនៅទីនោះ ។ ក្រោយមកមានមនុស្សប្រាប់ថាប្តីខ្ញុំមិនមែនត្រូវអង្គការសម្លាប់ទេ ប៉ុន្តែគាត់ស្លាប់ដោយសារជំងឺគ្រុនចាញ់នៅក្រូចគរ ។ បន្ទាប់មកខ្ញុំឮថាអ្នកទោសទាំងអស់នៅក្រូចគរត្រូវបញ្ជូនទៅគុកទួលស្លែង ឬក៏ត្រូវបាត់ខ្លួនតែម្តង ។

**ឈីម ចាន់ទី៖** នៅរវាងឆ្នាំ១៩៧៣-៧៤ មានការទម្លាក់គ្រាប់បែកនៅភូមិយើង ។ ប្រជាជនជាច្រើនត្រូវពិការដៃជើង ។ ឃើញដូច្នោះ រិទ្ធិ និងមិត្តភក្តិប៉ុន្មាននាក់ នាំគ្នារត់ទៅនៅក្បែរប្រឡាយតូចមួយ ។ ក្រោយមក រិទ្ធិ បានចូលរួមបដិវត្តន៍ ។ ដំបូងគាត់ធ្វើជាមេក្រុមសិល្បករនិងដើរថតរូប ។ ក្រោយមកគាត់ផ្លាស់ទៅក្រសួងពាណិជ្ជកម្មនៅខេត្តក្រចេះ ។

គាត់មកលេងផ្ទះមួយភ្លែតៗបានពីរបីដងដែរ ។ ជួនកាលគាត់ជិះកង់ ជួនកាលជិះម៉ូតូមក ។ គាត់មិននិយាយអ្វីច្រើនទេ គ្រាន់តែច្រៀងចម្រៀងឲ្យបងប្អូនស្តាប់ ។ គាត់សុំមេគោធំមួយយកទៅមន្ទីររបស់គាត់ ប៉ុន្តែខ្ញុំមិនដឹងថាគាត់យកទៅធ្វើអ្វីទេ ។

ខ្ញុំឮថា រិទ្ធិ ស្លាប់ហើយ ។ អ្នកបើកឡានឲ្យ រិទ្ធិ ប្រាប់ម្តាយរបស់រិទ្ធិថា គាត់លែងធ្វើការឲ្យរិទ្ធិទៀតហើយ ព្រោះអង្គការយករិទ្ធិទៅព្រៃ ។ ប្អូនស្រីរបស់រិទ្ធិបានទៅរកគ្រូទាយ អ្នកខ្លះថាគាត់នៅរស់ ខ្លះទៀតថាគាត់ស្លាប់ ។ ប្អូនស្រីរបស់គាត់នៅតែសង្ឃឹមថាបងប្រុសនៅរស់ឯបរទេស ប៉ុន្តែសម្រាប់ខ្ញុំ ខ្ញុំគិតថារិទ្ធិបានបាត់បង់ជីវិតហើយ ។ ◆◆◆

## ចាន់ ស៊ីម
## កខឆព

*(បទសម្ភាសន៍ជាមួយ ចាន់ ហ៊ឹម អាយុ៥៥ឆ្នាំ ត្រូវជាប្អូនប្រុសនៅស្រុកស្អាង ខេត្តកណ្តាល)*

ក្នុងចំណោមបងប្អូនខ្ញុំទាំងបួននាក់ ពីរនាក់បានស្លាប់ក្នុងពេលធ្វើបដិវត្តន៍ ក្នុងនោះមាន បងចាន់ស៊ីម ដែរ ។ ដើមឡើយគាត់ជាកសិករ ក្រោយមកពេលគាត់អាយុបាន១៨ឆ្នាំ គឺនៅឆ្នាំ១៩៧១ គាត់ក៏ចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ គ្មានអ្នកនៅលីវម្នាក់ណាអាចគេចរួចពីជួរកងទ័ពបានទេនៅពេលនោះ ។ នៅឆ្នាំ



ចាន់ ស៊ីម និង ចាន់ហ៊ឹម ថតក្នុងឆ្នាំ១៩៧៣

១៩៧៣ ខ្មែរក្រហមប្រាប់ខ្ញុំថា "មិនយូរមិនឆាប់ឯងពិតជាត្រូវចូលរួមចលនានេះដែរហើយ" ដូច្នេះខ្ញុំបានចូលរួមនឹងគេដែរ ។

មុននេះខ្ញុំធ្លាប់ធ្វើជាងជាងគំនូរនិងជាងថតរូប ប៉ុន្តែមិនសូវស្ទាត់ជំនាញប៉ុន្មានទេ ។ ខ្ញុំរៀនថតរូបតាមអ្នកដទៃ ។ ពេលខ្លះខ្ញុំបានទៅថតរូបតាមរោងការ តែខ្ញុំមិនបានកាន់លុយទេ ។ ខ្ញុំត្រូវតែប្រគល់លុយដែលរកបានឲ្យទៅអង្គការ ។ ក្រោយមកខ្ញុំបានគូររូបទិដ្ឋភាពការប្រជុំនៅស្តាតអូឡាំពិក ។ ខ្ញុំគូររូបតំណាងនិមិត្តរូបជាតិ រូបនារីកម្មាភិបាលកាន់កាំភ្លើងដើរជាក្បួន និងយុទ្ធនារីកំពុងច្បាំងនៅសមរភូមិតាមដងទន្លេមេគង្គ ។

ពេលខ្ញុំចូលបដិវត្តន៍ ខ្ញុំយកម៉ាស៊ីនថតដាក់តាមខ្លួនដែរ ហើយថែមទាំងបានថតរូបជាមួយ បងស៊ីម មួយសន្លឹកទៀតផង ។ កាលណោះគាត់មកលេងផ្ទះ យើងក៏នាំគ្នាទៅវាលស្រែថតរូបមួយសន្លឹកនេះ ។ ខ្ញុំថតរូបនេះទុកជាអនុស្សាវរីយ៍ ព្រោះជីវិតរកស្មានមិនត្រូវ ហើយខ្ញុំមិនសង្ឃឹមថាយើងទាំងពីរនាក់នឹងបានជួបគ្នាញឹកញាប់ទេ ។

នៅប្រហែលឆ្នាំ១៩៧៣ គាត់មកលេងផ្ទះបានប្រហែលបីខែ ព្រោះកាលណោះគាត់ឈឺ ។ ពោះវៀនគាត់មានបញ្ហា ។ ពេលបងស៊ីមឈឺ អង្គការអនុញ្ញាតឲ្យគាត់នៅភូមិ ។ បងស៊ីមបានវះកាត់ហើយក៏ជាសះស្បើយ ។ បន្ទាប់មកអង្គការបញ្ជូនគាត់ទៅកងពលលេខ១១២ ។ គាត់ធ្វើកងទ័ព បន្ទាប់មកធ្វើជាងកាត់សក់ ។ មួយរយៈក្រោយមកខ្ញុំបានធ្វើការជាមួយគាត់ ។ យើងកាត់សក់ឲ្យយុទ្ធជនមកពីមន្ទីរផ្សេងៗជាច្រើន ។ ខ្ញុំថែមទាំងបានជួយផ្តិតរូបថតទៀតផង ។

ក្រោយមកមានជាងកាត់សក់ច្រើននាក់ អង្គការបញ្ជូនខ្ញុំទៅធ្វើការនៅផ្នែកផ្សេងទៀត ។ ខ្ញុំត្រូវចាត់ឲ្យនៅក្រុមដេរខោអាវកងទ័ព ។ ទាហានលន់ណុលចាប់ផ្តើមវាយប្រហារយ៉ាងខ្លាំងក្លាមកលើកងពលខ្ញុំ ។ ឃើញដូច្នោះខ្ញុំក៏សម្រេចចិត្តធ្វើការឲ្យកងពលសេរី (រត់គេចពីខ្មែរក្រហមទៅចូលខាងលន់ណុល) ។ ក្រោយមកខ្ញុំត្រឡប់មកផ្ទះចង់ចូលកងពលចាស់វិញ ប៉ុន្តែខ្ញុំត្រូវខ្មែរក្រហមចាប់ខ្លួនព្រោះខ្ញុំធ្លាប់ធ្វើការឲ្យខាងលន់ណុល ។ ខ្ញុំអត់បាយអត់ទឹក ហើយរត់ទៅកន្លែងមួយទៀត ។ ខ្ញុំត្រូវខ្មែរក្រហមចាប់ខ្លួនម្តងទៀតដោយចោទថាជាទាហានលន់ណុល ។ ខ្ញុំក៏គេចខ្លួនជាលើកទីពីរ ។

បន្ទាប់ពីនោះខ្ញុំបានចូលកងពល៧០៣ ។ ម្តងនេះក្រោយពីឆែកឆេររកអាវុធ ខ្មែរក្រហមព្រមជឿខ្ញុំ ។ ចាប់ពីពេលនោះមកពេលធ្វើការខ្ញុំតែងតែដើរតាមតែមាគ៌ារបស់ខ្មែរក្រហមជានិច្ច ។

ពេលដែលខ្ញុំឃើញ បងស៊ីម ចុងក្រោយគឺនៅភ្នំពេញប្រហែល៦ខែក្រោយថ្ងៃរំដោះឆ្នាំ១៩៧៥ ។ យើងធ្លាប់ធ្វើជាជាងកាត់សក់ទាំងអស់គ្នាបានមួយរយៈដែរ ក្រោយមកខ្ញុំត្រូវអង្គការបញ្ជូនទៅដាំបន្លែ ។ បងស៊ីម ប្រាប់ខ្ញុំថាគាត់ជាប់ចោទថាជាខ្សែបណ្តាញវៀតណាម ប៉ុន្តែតាមពិតគាត់មិនដឹងអ្វីទាល់តែសោះ ។

ខ្ញុំថែមទាំងព្រួយថា បងស៊ីម មានរឿងដោយសារគាត់រិះគន់អ្នកនៅធ្វើការក្នុងកងជាមួយគ្នា ។ បងប្រុសខ្ញុំឆេវឆាវបន្តិច គាត់ជាមនុស្សឃើញខុសថាខុស ឃើញត្រូវថាត្រូវ មិនចេះទប់ទេ ។ គាត់និយាយថា គាត់បានរិះគន់អង្គការពីរឿងឲ្យប្រជាជនហូបចុកមិនគ្រប់គ្រាន់ ហេតុនេះហើយទើបគាត់មានបញ្ហា ។

ថ្ងៃបន្ទាប់ អង្គការបញ្ជូនគាត់ទៅកាន់ការនៅផ្នែកសេដ្ឋកិច្ចមន្ទីរស-២១ ។ គាត់ទទួលខុសត្រូវរកស្រូវ អង្ករ ទឹក និងរបស់ផ្សេងៗទៀតសម្រាប់ផ្គត់ផ្គង់ទីនោះ ។ នៅឆ្នាំ១៩៧៦ ខ្ញុំបានជួបមិត្តភក្តិរបស់បងស៊ីមឈ្មោះ ណាម ពេលទៅប្រជុំនៅស្តាតអូឡាំពិកជាមួយគ្នា ។ ណាម ប្រាប់ថា បងស៊ីម ត្រូវអង្គការបញ្ជូនទៅធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង ។ គាត់ថាអង្គការតែងតែយកអ្នកនៅស-២១ទៅធ្វើការនៅទីនោះ ប៉ុន្តែមិនដែលឃើញអ្នកណាម្នាក់បានត្រឡប់ទៅសមរភូមិវិញទេ ។ ខ្ញុំពិបាកនឹងចាំថ្ងៃខែឲ្យច្បាស់លាស់ណាស់ ព្រោះកាលណោះអត់មានប្រក្រតីទិន ។

នៅជំនាន់ប៉ុលពត មិត្តភក្តិរបស់ បងស៊ីម ត្រូវអង្គការបញ្ជូនទៅប្រទេសចិន ។ ក្រុមគ្រួសាររបស់គាត់បានប្រកាសតាមវិទ្យុអំពីការបាត់ខ្លួនរបស់គាត់ ប៉ុន្តែគាត់បានត្រឡប់មកស្រុកកំណើតវិញ ។ បើបងប្រុសខ្ញុំនៅចិនដែរ ម៉្លេះសមពេលនេះគាត់មកផ្ទះវិញដែរហើយ ប៉ុន្តែតាមមើលទៅបែប បងស៊ីម មិននៅស្រុកចិនទេ គាត់ប្រហែលជានៅសហរដ្ឋអាមេរិកហើយ ។

◆◆◆◆◆

# សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ទួន ឆាន



សាន ឃិន

នាងខ្ញុំឈ្មោះ សាន ឃិន អាយុ៧០ឆ្នាំ រស់នៅភូមិរកា ឃុំរកាជន្ទឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សូមសួររកកូនប្រុសច្បងឈ្មោះ ទួន ឆាន ហៅ ឃឿន ដែលបានចូលបម្រើបដិវត្តន៍កាលពីឆ្នាំ១៩៧៣ ហើយបាត់ខ្លួនរហូតបច្ចុប្បន្ន ។ មុនពេលចូលបដិវត្តន៍ ឆាន បួសជាសង្ឃនៅវត្តស្វាយពោធិនៅក្នុងស្រុកកំណើត ។ បន្ទាប់មក ឆាន ធ្វើដំណើរទៅរៀនបន្តនៅវត្តត្នោតឫស្សីស្រុកនៅខេត្តកំពង់ចាម ។ បីឆ្នាំក្រោយ ពេលដែល ឆាន អាយុ២៥ឆ្នាំ គឺនៅឆ្នាំ១៩៧៣ ឆាន បានសឹកពីបួសហើយចូលបម្រើបដិវត្តន៍ដោយមិនប្រាប់ម្តាយឪពុកឲ្យដឹងឡើយ ។ នៅឆ្នាំ១៩៧៩ ស្រ៊ី នៅក្នុងភូមិជាមួយគ្នាបានប្រាប់ខ្ញុំថា គាត់បានជួប ឆាន នៅខេត្តកំពង់ឆ្នាំង ហើយបានបបួល ឆាន ត្រឡប់មកផ្ទះវិញ ប៉ុន្តែ ឆាន ប្រកែក ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ គ្រួសារខ្ញុំបានទទួលសំបុត្រមួយពី ឆាន សួររកក្រុមគ្រួសារនៅភូមិកំណើត ប៉ុន្តែពេលនោះយើងទាំងអស់គ្នាមិនបានយកចិត្តទុកដាក់នឹងសំបុត្រនោះប៉ុន្មានទេ ព្រោះរវល់តែខ្វាយខ្វល់នឹងឪពុករបស់ ឆាន ដែលមានជំងឺជាទម្ងន់ ។ ក្រោយពេលធ្វើបុណ្យសពឪពុករបស់ ឆាន រួចមក សំបុត្រនោះក៏បាត់រហូត ហើយខ្ញុំក៏មិនបានទទួលដំណឹងអ្វីពី ឆាន ទៀតដែរ ។

បើកូនបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានដឹងដំណឹងអំពី ទួន ឆាន សូមមេត្តាទាក់ទងនាងខ្ញុំនៅភូមិឃុំខាងលើ ឬទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារ ០២៣ ២១០ ៣៥៨ ឬតាមរយៈប្រអប់សំបុត្រ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# លិខិតឆ្លើយតប

កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ លោក ជ្រី ប៊ុនហៀង នៅខេត្តរតនគិរី បានទូរស័ព្ទមកការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រាប់ថា លោកដឹងថាឈ្មោះ ទួន ឆាន ហៅ ឃឿន កំពុងតែរស់នៅខេត្តរតនគិរី ប៉ុន្តែប្រព័ន្ធទូរស័ព្ទបានដាច់មុនពេលដែលខាងមជ្ឈមណ្ឌលយើងបានទទួលពត៌មានលម្អិតពីលោក ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានព្យាយាមទូរស័ព្ទទៅលេខ ០១១ ៩២៩ ៦០០ ដែលលោក ប៊ុនហៀង បានប្រាប់ ប៉ុន្តែលេខនេះគ្មានការប្រើប្រាស់ទេ ។ យើងសង្ឃឹមថាលោក ជ្រី ប៊ុនហៀង ឬ ទួន ឆាន ហៅ ឃឿន នឹងទូរស័ព្ទមកម្តងទៀត ទាក់ទងឈ្មោះ សាន់ កល្យាណ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា តាមលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៩៨ ៣៩៣ ។ សូមអរគុណ ។

## សេចក្តីប្រកាសរកបងប្រុសឈ្មោះ ច្រឹង សឿ និងបងស្រីឈ្មោះ ច្រឹង សួ

នាងខ្ញុំឈ្មោះ ខែក អ៊ិន អាយុ៤៨ឆ្នាំ មានបងប្អូន៦នាក់ ប្រុស៣នាក់ ស្រី៣នាក់ ។ ឪពុកឈ្មោះ ខែក ហួន ស្លាប់ឆ្នាំ២០០៣ ម្តាយឈ្មោះ មាស ស៊ុំ ស្លាប់កាលពី៦ឆ្នាំមុន ។ នាងខ្ញុំសូមសួររកបងប្រុសឈ្មោះ ច្រឹង សឿ និងបងស្រីឈ្មោះ ច្រឹង សួ ដែលបាត់ខ្លួនតាំងពីរបបខ្មែរក្រហម ។

កាលពីចុងឆ្នាំ១៩៧៨ បងប្រុស សឿន បានផ្ញើសំបុត្រមួយមកសួរសុខទុក្ខគ្រួសារ ដោយប្រាប់ថាគាត់កាន់ខាងកងពលនៅមេមត់ ។ ចំណែកបងស្រី សួ មានអ្នកស្គាល់គ្នាជួបនៅឆ្នាំ១៩៧៩ពេលកំពុងរត់ឡើងភ្នំនៅខេត្តមណ្ឌលគិរី ។ តាំងពីពេលនោះមក នាងខ្ញុំបាត់ដំណឹងពីបងទាំងពីររហូតមកដល់សព្វថ្ងៃនេះ ។

ប្រសិនបើបងទាំងពីរបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានស្គាល់ឬបានឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ពត៌មានមកនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។




ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល

DC-Cam Main Office: #66, Preah Sihanouk Blvd, Tonle Basac, Chamkar Morn, Phnom Penh, Cambodia. Tel: (855) 23 211 875, Fax: (855) 23 210 358, Email:dccam@online.com.kh, Homepage: www.dccam.org.